ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

វិទ្យាស្ថានជាតិអប់រំ

# កិច្ចការស្រាវជ្រាវ

# គណិតវិទ្យា

និង



# ឡាប់ ប្រូបាប

Probability




សាស្ត្រាចារ្យបណ្ឌិតណែនាំ : គឹម ចំរើនខុឌ្ឍី

គរុនិស្សិតគណិតវិទ្យាក្រុម៤ ជំនាន់ទី២១

នឹម ស៊ីណែត　　ចឹក អឿន

ជុំ មាន　　ពេញ រាសី

ផល ថិរៈ　　គង់ រី


ឆ្នាំសិក្សា ២០១៥-២០១៦

វក្សាសិទ្ធិ

# អារម្ភកថា

សៀវភៅ **ទោច់** និង **ប្រូបាប** ដែលមិត្តអ្នកសិក្សាកំពុងកាន់ក្នុងដៃនេះ ត្រូវបានរៀបចំឡើងយ៉ាងយកចិត្តទុកដាក់ ដើម្បីជាជំនួយស្មារតីដល់ប្អូនៗសិស្សានុសិស្ស និងមិត្តអ្នកសិក្សាដែលចូលចិត្តសិក្សាផ្នែកគណិតវិទ្យា និងមានបំណងលើកកម្ពស់ វិស័យអប់រំគណិតវិទ្យានៅកម្ពុជាឱ្យមានគុណភាពល្អប្រសើរ។ ក្នុងសៀវភៅនេះ មានរៀបចំចងក្រងជា មេរៀនសង្ខេប រូបមន្ត និងលំហាត់ ដែលទាក់ទងទៅនឹង រូបមន្តនោះដែលធ្វើឱ្យអ្នកសិក្សាងាយយល់ ឆាប់ចេះ និងអនុវត្តន៍បានយ៉ាងល្អប្រសើរ។ យើងខ្ញុំសង្ឃឹមថា សៀវភៅនេះ នឹងក្លាយជាមិត្តដ៏ល្អ សម្រាប់សិស្សានុសិស្ស និងមិត្តអ្នកសិក្សាគ្រប់កាលៈទេសៈ ជាពិសេសអ្នកទាំងអស់គ្នាអាចយកគន្លឹះនៅក្នុងសៀវភៅនេះយកទៅហ្វឹកហាត់ ស្រាវជ្រាវ និងស្វែងយល់ដោយខ្លួនឯងឱ្យបានស៊ីជម្រៅថែមទៀត។

ទោះជាមានការរៀបចំយ៉ាងល្អិតល្អន់យ៉ាងណាក៏ដោយភាពកង្វះខាត និងកំហុសឆ្គងដោយអចេតនា នឹងកើតមានជាមិនខាន ។ ហេតុនេះ រងចាំទទួលការរិះគន់ និងកែលំអរពីសំណាក់លោកគ្រូ អ្នកគ្រូ និងមិត្តអ្នកសិក្សាទាំងអស់ដើម្បីឱ្យសៀវភៅ កាន់តែមានភាពល្អប្រសើរថែមទៀត ។

ជាទីបញ្ចប់ យើងខ្ញុំសូមគោរពជូនពរដល់លោកគ្រូ អ្នកគ្រូ សិក្សានុសិស្ស និងមិត្តអ្នកសិក្សាទាំងអស់ឱ្យមានសុខភាពល្អ និងជោគជ័យគ្រប់ភារកិច្ច ។

ភ្នំពេញ ថ្ងៃទី០៧ ខែកក្កដា ឆ្នាំ២០១៦

រៀបរៀងដោយ គរុនិស្សិតគណិតវិទ្យាជំនាន់ទី២១


**គរុនិស្សិតគណិតវិទ្យាក្រុម៤** **សាស្ត្រាចារ្យបណ្តិតណែនាំ គឹម ចំរើនឧត្តម្មី**

| | | |
|---|---|---|
| នឹម ស៊ីណែត | 0972948735 | sineth321123@gmail.com |
| ចឹក អឿន | 081782156 | samoeurn9@gmail.com |
| ជុំ មាន | 098501644 | chummeanp.v@gmail.com |
| ផល វិរៈ | 086288774 | vireakphalm.@gmail.com |
| គង់ រី | 012422059 & 070397309 | kongrytd@gmail.com |
| ពេញ រាសី | 0965744257 | reaseypenh@gmail.com |

# មាតិកា

**ចំណងជើង** **ទំព័រ**

**១. របាប់**

- សំណុំ ........ ១
- គោលការណ៍រាប់ ........ ៦
- វិភាគបន្សំ ........ ១២
- ទ្រឹស្តីបទទ្វេធា និងពហុធា ........ ២១
- លំហាត់ និងចម្លើយ ........ ៣០

**២. ប្រូបាប**

- លំហសំណាក និង ព្រឹត្តិការណ៍ ........ ៤១
- និយមន័យប្រូបាប ........ ៤៤
- ប្រូបាបមានលក្ខខណ្ឌ ........ ៤៦
- ព្រឹត្តិការណ៍មិនទាក់ទងគ្នា ........ ៤៧
- រូបមន្ត Bayes ........ ៤៩

**៣. បំណែងចែកប្រូបាប**

- អថេរចៃដន្យ និង បំណែងចែកប្រូបាប ........ ៥៣
- បំណែងចែកទ្វេធា ........ ៥៧
- បំណែងចែកធរណីមាត្រ ........ ៥៨
- បំណែងចែក Poisson ........ ៦០
- លំហាត់ និងចម្លើយ ........ ៦៤
- ឯកសារយោង ........ ១១៤

# សេចក្តីផ្តើម

ទ្រឹស្តីប្រូបាបបានចាប់ផ្តើមឡើងនៅក្នុងសតវត្សទី១៧ ឆ្នាំ១៦៥៤ នៅក្នុងប្រទេសបារាំង នៅពេលដែលអ្នកគណិតវិទ្យាបារាំងដ៏អស្ចារ្យ ពីររូបគឺ លោក Blaise Pascal និង Pierre de Fermat បានជួបនឹងបញ្ហាពីរ នៃឱកាសឈ្នះ ឬចាញ់នៅក្នុងការលេងល្បែង ។ បញ្ហាដូចដែលលោក Pascal និង Fermat បានដោះស្រាយ ក៏បានបន្ត ឥទ្ធិពលដល់អ្នកស្រាវជ្រាវក្រោយទៀតដូចជា : លោក Huygens លោក Bernoulli លោក DeMoivre ក្នុងការបង្កើតទ្រឹស្តី គណិតវិទ្យានៃប្រូបាប ។ បច្ចុប្បន្ននេះ ទ្រឹស្តីបទប្រូបាបត្រូវបានបង្កើតឡើងយ៉ាងល្អ ជាមែកធាងមួយនៃគណិតវិទ្យា ដែលរកឃើញការអនុវត្ត នៅគ្រប់ផ្នែកនៃសកម្មភាពសិក្សាក្នុងបទពិសោធន៍ ប្រចាំថ្ងៃដូចជា ការទស្សន៍ទាយ នូវភាពគ្រោះថ្នាក់នៃការព្យាបាល ដោយប្រើថ្នាំពេទ្យថ្មី ការប្រើប្រាស់នៅក្នុងពាណិជ្ជកម្ម ដោយស្មានទុកនូវអ្វីដែលអាចកើតឡើងជាមុន ការទស្សន៍ទាយនូវភាពឈ្នះចាញ់ទុកជាមុននូវការប្រកួតកីឡា ជាពិសេសទ្រឹស្តីប្រូបាបនេះ អាចអនុវត្តបានយ៉ាងល្អនូវការលេងល្បែងស៊ីសងដោយយើងអាចទស្សន៍ទាយទុកជាមុន នូវភាគរយនៃការឈ្នះ ឬចាញ់ ។ ដោយឡែក សៀវភៅប្រូបាបដែលលោកអ្នកកាន់នៅក្នុងដៃនេះ គឺយើងខ្ញុំបានបែងចែកជាបីចំណុចសំខាន់ៗ ។ ចំណុចទី១ គឺនិយាយពី **របាប់** ដែលជាមេរៀនមួយប្រើជាមូលដ្ឋានសំរាប់ការស្វែងរកករណីស្រប និងករណីអាចនៅក្នុងប្រូបាប ។ ចំណុចទី២ និយាយអំពី រូបមន្តទូទៅរបស់មេរៀន**ប្រូបាប** ហើយចំណុចចុងក្រោយគឺបំណែងចែកប្រូបាបនិយាយអំពីការប្រើប្រាស់ប្រូបាបនៅក្នុងជីវភាពរស់នៅប្រចាំថ្ងៃ ។

គ្រប់ទ្រឹស្តីបទ ឬវិធានផ្សេងៗ សុទ្ធតែមានសារៈសំខាន់ណាស់ដែលមិនអាចខ្វះបាន ប៉ុន្តែអាស្រ័យដោយពេលវេលាមានកំណត់ទើបបានជាការស្រាវជ្រាវទាក់ទងនឹងមុខវិជ្ជាប្រូបាបមិនអាចពេញលក្ខណៈ ល្អប្រសើរបានឡើយព្រោះតែទ្រឹស្តីបទមួយចំនួនយើងខ្ញុំមិនបានយកមកសិក្សាឡើយ ក៏ប៉ុន្តែមិនមែនមានន័យថាទ្រឹស្តីទាំងនោះមិនសំខាន់នោះទេ ។ ដូច្នេះចំពោះទ្រឹស្តីបទ ឬវិធាននានាដែលខ្វះខាត យើងខ្ញុំសូមទុកឱកាសឱ្យប្អូនៗជំនាន់ក្រោយអាចសិក្សាស្រាវជ្រាវបន្ថែមទៀតដើម្បីឱ្យមានភាពប្រសើរលូតលាស់ឡើយនូវមុខវិជ្ជាមួយនេះ ។

យើងខ្ញុំសង្ឃឹមថាសៀវភៅប្រូបាបនេះ ពិតជាអាចជួយលើកកម្ពស់គុណភាពក្នុងវិស័យអប់រំគណិតវិទ្យារបស់មិត្តអ្នកស្រាវជ្រាវ និងប្អូនសិស្សានុសិស្ស តាមរយៈការអភិវឌ្ឍសម្ថតភាពក្នុងការដោះស្រាយចំណោទបញ្ហា ។

# មេរៀន

## ១. សំណុំ

### ១.១. សំណុំ និង ធាតុ *(Set and Elements )*

❖ **ឧទាហរណ៍ ៖** នៅក្នុងភូមិមួយមានចំនួនប្រជាជនចំនួន ៥០ គ្រួសារ។

នោះគេបាន - ភូមិមួយហៅថា **សំណុំ** ។

- ចំនួនប្រជាជនចំនួន ៥០គ្រួសារ ហៅថា **ធាតុនៃសំណុំ** ។

**និយមន័យ ៖** សំណុំគឺជាបណ្តុំនៃវត្ថុនានាដែលកំណត់ដោយលក្ខខណ្ឌជាក់លាក់ណាមួយ ។

គេកំណត់យកអក្សរធំ *A,B,C, ...* តាងអោយសំណុំ និង អក្សរតូច *a,b,c, ...* តាងអោយធាតុនៃសំណុំ។

*សម្គាល់ ៖*

- ចំនួនធាតុនៃសំណុំគេកំណត់សរសេរដោយ $n(A), n(B), n(C), ...$
- p ជាធាតុរបស់ *A* កំណត់សរសេរដោយ $p \in A$
- p មិនមែនជាធាតុរបស់ *A* កំណត់សរសេរដោយ $p \notin A$
- សំណុំ *A* និង *B* ជាពីរសំណុំស្មើគ្នា កំណត់សរសេរដោយ $A = B$ លុះត្រាតែគ្រប់ធាតុនៃសំណុំ *A* ជាធាតុនៃសំណុំ *B* និងផ្ទុយមកវិញ ។

### ១.២. សំណុំសកល និង សំណុំទទេ *(Universal set and Empty set )*

**និយមន័យ ៖** សំណុំសកលគឺជាសំណុំនៃធាតុ ដែលជាធាតុនៃគ្រប់សំណុំទាំងអស់ដែលគេជ្រើសរើសយកមកសិក្សា ។ គេកំណត់ដោយ $U$ ។

❖ **ឧទាហរណ៍ ៖** នៅក្នុងថ្នាក់រៀនមួយមានសិស្ស 25 នាក់។ ថ្នាក់រៀនជាសំណុំសកលនៃសំណុំដែលមានធាតុចំនួន 25 ។

**និយមន័យ ៖** សំណុំទទេ គឺជាសំណុំដែលគ្មានធាតុ ។ គេកំណត់សរសេរដោយ $\varnothing$ ។

❖ **ឧទាហរណ៍ ៖** $S = \{x / x$ ជាចំនួនគត់វិជ្ជមាន $, x^2 = 3\}$

ក្នុងករណីនេះគ្មានចំនួនគត់វិជ្ជមានណាដែលផ្ទៀងផ្ទាត់លក្ខណៈខាងលើឡើយ មានន័យថា *S* ជាសំណុំទទេ និង កំណត់សរសេរដោយ $\varnothing$។

### ១.៣.សំណុំរង **(Subset)**

**និយមន័យ ៖** គេថា *A* គឺជាសំណុំរងនៃ *B* រឺ *A* ក្នុង *B* រឺ *A* ជាផ្នែកមួយនៃ *B* រឺ *B* ផ្ទុក *A* លុះត្រាតែគ្រប់

ធាតុ $x$ នៃ $A$ ជារបស់ $B$ ។ គេកំណត់សរសេរដោយ $A\subset B$ រឺ $B\supset A\Leftrightarrow(\forall x\in A\Rightarrow x\in B)$ ។ គេបាន $A=B\Leftrightarrow[(A\subset B)\wedge(B\subset A)]$ រឺ $A=B\Leftrightarrow(\forall x: x\in A\Leftrightarrow x\in B)$ ។

i. $\varnothing\subset A\subset U$ ($U$ ជាសំណុំសកល)

ii. ចំពោះគ្រប់សំណុំ $A$ គេបាន $A\subset A$

iii. បើ $A\subset B$ ហើយ $B\subset C$ នោះគេបាន $A\subset C$

### ១.៤.ដ្យាក្រាមវិន (*Venn diagrams)*

**និយមន័យ ៖** *Venn diagrams* ជារូបភាពតាងឱ្យសំណុំដោយសំណុំចំណុចក្នុងប្លង់ ។ គេតាង សកល $U$ ដោយផ្ទៃកក្នុងនៃចតុកោណកែង ហើយសំណុំដទៃទៀតដោយថាសដែលនៅក្នុងចតុកោណកែង ។




$(a).A\subset B$ (b.) **A** និង **B** ដាច់គ្នា (c). **A** និង **B** មានធាតុរួមគ្នា

- *Venn diagram* (a) គេឱ្យពីរសំណុំ $A, B$ ដែល $A\subset B$
- *Venn diagram* (b) គេឱ្យពីរសំណុំដាច់គ្នា $A$ និង $B$
- *Venn diagram* (c) គេឱ្យពីរសំណុំ $A$ និង $B$ ដែលមានធាតុរួម

### ១.៥.ប្រមាណវិធីលើសំណុំ (*Set Operations)*

#### ១.៥.១. ប្រមាណវិធីប្រជុំ

**និយមន័យ ៖** គេឱ្យពីរសំណុំ $A$ និង $B$ ។ ប្រជុំនៃពីរសំណុំ $A$ និង $B$ កំណត់តាងដោយ $A\cup B$ គឺជាសំណុំនៃធាតុ $x$ ទាំងឡាយណាដែល $x$ ជាធាតុរបស់ $A$ ឬ $x$ ជាធាតុរបស់ $B$ ។

គេកំណត់សរសេរដោយ: $A\cup B=\{x: x\in A\vee x\in B\}$

$\forall x\in A\cup B\Leftrightarrow x\in A\vee x\in B$

*សម្គាល់ ៖*

- $A\cup A=A$
- $A\cup B=B\cup A$
- $(A\cup B)\cup C=A\cup(B\cup C)$
- $A\subset(A\cup B), B\subset(A\cup B)$




$A\cup B$ ជាផ្ទៃកផាត់ពណ៌

### ១.៥.២.ប្រមាណវិធីប្រសព្វ

**និយមន័យ ៖** គេឱ្យពីរសំណុំ $A$ និង $B$ ។ ប្រសព្វនៃពីរសំណុំ $A$ និង $B$ កំណត់តាងដោយ $A\cap B$ គឺជាសំណុំនៃធាតុ $x$ ទាំងឡាយណាដែល $x$ ជាធាតុរបស់ $A$ ***និង*** $x$ ជាធាតុរបស់ $B$ ។

គេកំណត់សរសេរដោយ: $A\cap B=\{x:x\in A\wedge x\in B\}$

*សម្គាល់ ៖* $\forall x\in A\cap B\Leftrightarrow x\in A\wedge x\in B$

- $A\cap A=A$
- $A\cap B=B\cap A$
- $(A\cap B)\cap C=A\cap(B\cap C)$
- $(A\cap B)\subset A,(A\cap B)\subset B$
- $A\cap B=A\Leftrightarrow A\subset B$
- $A\cup(B\cap C)=(A\cup B)\cap(A\cup C)$




$A\cap B$ ជាផ្នែកផាត់ពណ៌

### ១.៥.៣. សំណុំរងបំពេញ

**និយមន័យ ៖** $U$ ជាសកលមួយ និង $A$ ជាផ្នែកមួយនៃសកល $U$។ សំណុំរងបំពេញនៃ $A$ ក្នុង $U$ កំណត់សរសេរដោយ $\bar{A}$ ឬ $A^C$ គឺជាសំណុំធាតុនៃ $x$ ទាំងឡាយរបស់ $U$ ដែលមិនមែនជាធាតុរបស់ $A$ ។

គេកំណត់សរសេរដោយ: $A^C=\bar{A}=\{x:x\in U,x\notin A\}$

*សម្គាល់ ៖*

- $A\cap\bar{A}=\varnothing$
- $A\cup\bar{A}=U$
- $\bar{U}=\varnothing$
- $\bar{\bar{A}}=A$
- $\bar{\varnothing}=A$
- $A\subset B\Leftrightarrow\bar{B}\subset\bar{A}$
- $\overline{A\cap B}=\bar{A}\cup\bar{B}$
- $\overline{A\cup B}=\bar{A}\cap\bar{B}$ ( ***De Morgan's Law)***




$A^C$ ជាផ្នែកផាត់ពណ៌

### ១.៥.៤. ផលសងរវាងពីរសំណុំ ***(Difference Between two set)***

**និយមន័យ ៖** គេឱ្យពីរសំណុំ $A$ និង $B$ ។ ផលសងរវាង $A$ និង $B$ កំណត់សរសេរដោយ $A\setminus B$ គឺជាសំណុំធាតុនៃ $x$ ទាំងឡាយដែល $x$ ជាធាតុរបស់ $A$ និង $x$ មិនមែនជាធាតុរបស់ $B$ ។

គេកំណត់សរសេរដោយ: $A\setminus B=\{x:x\in A\wedge x\notin B\}$

$\forall x\in A\setminus B\Leftrightarrow x\in A\wedge x\notin B$

*សម្គាល់ ៖* $A\setminus B=A\cap\overline{B}$




$A\setminus B$ ជាផ្នែកផាត់ពណ៌

❖ **ឧទាហរណ៍ ៖** គេមានសំណុំពីរ $A=\{1,3,5,7,9\}$ និង $B=\{2,4,5,6,7,8\}$ ហើយសំណុំសកល $U=\{1,2,3,...,15\}$ ។ គេបាន $A\cup B=\{1,2,3,4,5,6,7,8,9\}$ $A\cap B=\{5,7\}$

$A\setminus B=\{1,3,9\}$




$A\cup B$




$A\cap B$




$A\setminus B$




$A^C$

## ១.៦.សំណុំរាប់អស់ និង សំណុំរាប់បាន *(Finite and Countable sets)*

**និយមន័យ ៖** គេថាសំណុំមួយជា *សំណុំរាប់អស់* កាលណាសំណុំនោះ មាន $m$ ធាតុផ្សេងៗគ្នាដែល $m$ ជាចំនួនគត់មិនអវិជ្ជមាន ។ បើមិនដូចនេះទេ គេថាវាជា *សំណុំរាប់មិនអស់* ។

❖ **ឧទាហរណ៍ ៖** គេមាន $M$ ជាចំនួនខែក្នុងរយៈពេលមួយឆ្នាំ ។

$M=\{$ មករា ,កុម្ភៈ ,មិនា ,មេសា ,ឧសភា ,មិថុនា ,កក្កដា ,សីហា ,កញ្ញា ,តុលា ,វិច្ឆិកា ,ធ្នូ $\}$

ដូច្នេះ $M$ ជា *សំណុំរាប់អស់* ។

❖ ឧទាហរណ៍ ៖ គេមានសំណុំ $N=\{2,4,6,...\}$ នោះ $N$ ជា *សំណុំរាប់មិនអស់* ។

**និយមន័យ** ៖ សំណុំមួយជា *សំណុំរាប់បាន* លុះត្រាតែវាជាសំណុំរាប់អស់ ឬ វាអាចសរសេរជាទម្រង់នៃស្វ៊ីតមួយ បើមិនដូចនេះទេវា គឺជា *សំណុំរាប់មិនបាន* ។

❖ **ឧទាហរណ៍** ៖ គេមាន $P=\{x:0\le x\le 1\}$ ជា *សំណុំរាប់អស់* ហើយវាក៏ជា *សំណុំរាប់មិនបានដែរ* ។

## ១.៧. ផលគុណនៃសំណុំ *(Product of set)*

**និយមន័យ** ៖ គេឱ្យពីរសំណុំ $A$ និង$B$ ហៅថាផលគុណនៃសំណុំ រឺផលគុណដេកាតនៃពីរសំណុំ $A$ និង$B$ កំណត់សរសេរដោយ $A\times B$ គឺជាសំណុំនៃគូមានលំដាប់ $(a,b)$ ទាំងអស់ដែល $a\in A$ និង $b\in B$ ។

កំណត់សរសេរដោយ $A\times B=\{(a,b):a\in A\wedge b\in B\}$

❖ **ឧទាហរណ៍** ៖ $A=\{1,2\}$ និង $B=\{a,b,c\}$ នោះ ៖

$$A\times B=\{(1,a),(2,b),(1,c),(2,a),(2,b),(2,c)\}$$

$$B\times A=\{(a,1),(a,2),(b,1),(b,2),(c,1),(c,2)\}$$

$$A\times A=\{(1,1),(1,2),(2,1),(2,2)\}$$

តារាងនៃធាតុរបស់ $A\times B$

| B \ A | $a$ | $B$ | $c$ |
|---|---|---|---|
| 1 | $(1,a)$ | $(1,b)$ | $(1,c)$ |
| 2 | $(2,a)$ | $(2,b)$ | $(2,c)$ |




*សម្គាល់* ៖

- $(A\subset X\wedge B\subset Y)\Rightarrow(A\times B)\subset(X\times Y)$
- $A\times B=\varnothing\Rightarrow(A=\varnothing\vee B=\varnothing)$
- $A\times(B\cup C)=(A\times B)\cup(A\times C)$
- $A\times(B\cap C)=(A\times B)\cap(A\times C)$
- $[(A\ne\varnothing)\wedge(A\times B=A\times C)]\Rightarrow B=C$

# ២.គោលការណ៍រាប់

## ២.១. គោលការណ៍ វិធីបូក

បើយើងរាប់ចំនួនសិស្សក្នុងថ្នាក់មួយ ឬ រាប់កាក់ក្នុងថង់មួយ អ្វីដែលយើងបានធ្វើការផ្ទៀងផ្ទាត់លើមូលដ្ឋានមួយទល់នឹងមួយ រវាងសំណុំវត្ថុដែលត្រូវរាប់ និង សំណុំចំនួន $1,2,3,...,n$ ។បើសំណុំ $A$ ផ្ទៀងផ្ទាត់ជាមួយសំណុំ $\{1,2,3,...,25\}$ យើងអាចសន្និដ្ឋានថា សំណុំ $A$ មាន 25 ធាតុ យើងប្រើសញ្ញាកំណត់ $n(A)=25$ ដើម្បីបង្ហាញថា សំណុំ $A$ មាន 25 ធាតុ ។

❖ **ឧទាហរណ៍ ៖** ក្នុងការសាកសួរសិស្ស 100 នាក់ សិស្ស 35 នាក់ចុះឈ្មោះរៀនគណិតវិទ្យា 52 នាក់ចុះឈ្មោះរៀន កុំព្យូទ័រ និង 18 នាក់ ចុះឈ្មោះរៀនទាំងពីរមុខ ។ តើមានសិស្សប៉ុន្មាននាក់ដែលមិនបានចុះឈ្មោះចូលរៀនមុខវិជ្ជាទាំងពីរ ។




ចម្លើយ ៖ ដំបូងយើងដោះស្រាយដោយប្រើដ្យាក្រាមវិន ៖

តាង $A$ ជាសំណុំសិស្សចុះឈ្មោះរៀនគណិតវិទ្យា

តាង $B$ ជាសំណុំសិស្សចុះឈ្មោះរៀន កុំព្យូទ័រ

តាមសម្មតិកម្ម $n(A)=35, n(B)=52$ និង $n(A\cap B)=18$ ។

តាមដ្យាក្រាមវិន ចំនួនសិស្សរៀនមួយមុខយ៉ាងតិចមានចំនួន $17+18+34=69$ នាក់។ ដោយចំនួនសិស្សសរុបមាន 100 នាក់ ។ នោះចំនួនសិស្សមិនចុះឈ្មោះចូលរៀនមុខវិជ្ជាទាំងពីរគឺ $100-69=31$ នាក់ ។ ដូចនេះ សិស្សដែលមិនចុះឈ្មោះរៀនមុខវិជ្ជាទាំងពីរគឺ 31 នាក់។

បើយើងរាប់ធាតុក្នុងសំណុំនីមួយៗ $A$ និង $B$ យើងឃើញថាមានធាតុខ្លះ យើងរាប់ពីរដង នៅក្នុងសំណុំ $A$ ផង និងក្នុងសំណុំ $B$ ផង គឺធាតុដែលជារបស់ $(A\cap B)$ ។ ដើម្បីរាប់ឱ្យបានជាក់លាក់ ធាតុរបស់ $(A\cup B)$ ឬ ដើម្បីរក $n(A\cup B)$ យើងត្រូវដកធាតុនៅក្នុង $A\cap B$ ពី $n(A)+n(B)$ ចេញ ។

***ទ្រឹស្តីបទ*** : បើ $A$ និង $B$ ជាសំណុំកំណត់ គេបាន $\mathbf{n(A\cup B)=n(A)+n(B)-n(A\cap B)}$

ក្នុងឧទាហរណ៍ខាងលើ យើងបាន : $n(A\cup B)=n(A)+n(B)-n(A\cap B)$

$$=35+52-18$$
$$=69$$

ដូចនេះ សិស្សមិនបានចុះឈ្មោះចូលរៀន មុខវិជ្ជាទាំងពីរ គឺ $100-69=31$ នាក់

ក្នុងករណី $A\cap B=\varnothing$ នោះ $n(A\cap B)=0$

> ទ្រឹស្តីបទ : បើ $A$ និង $B$ ជាសំណុំគ្មានធាតុរួម គេបាន $n(A\cup B)=n(A)+n(B)$

- ឧទាហរណ៍ ៖ នៅវិទ្យាល័យមួយ សិស្ស 800 នាក់ បានចុះឈ្មោះរៀនភាសាអង់គ្លេស និង សិស្ស 500 នាក់ បានចុះឈ្មោះរៀនភាសា បារាំង ហើយសិស្ស 200 នាក់ទៀតបានចុះឈ្មោះរៀនភាសាទាំងពីរ ។

ក. តើមានសិស្សទាំងអស់ប៉ុន្មានអ្នកបានចុះឈ្មោះរៀនភាសា ?

ខ. តើសិស្សប៉ុន្មាននាក់រៀនតែភាសាអង់គ្លេស ?

គ. តើសិស្សប៉ុន្មានអ្នករៀនតែភាសាបារាំង ?

**ចម្លើយ** : តាង $E$ ជាសំណុំសិស្សចុះឈ្មោះរៀនភាសាអង់គ្លេស ។

$F$ ជាសំណុំចសិស្សចុះឈ្មោះរៀនភាសាបារាំង ។

យើងបាន $n(E)=800$ នាក់ , $n(F)=500$ នាក់ និង $n(E\cap F)=200$ នាក់ ។

ក. ចំនួនសិស្សបានចុះឈ្មោះរៀនភាសា :

$$n(E\cup F)=n(E)+n(F)-n(E\cap F)$$
$$=800+500-200$$
$$=1100 \text{ នាក់}$$

ដូចនេះ មានសិស្ស 1100 នាក់ បានចុះឈ្មោះរៀនភាសា ។

ខ. ចំនួនសិស្សរៀនតែភាសាអង់គ្លេស :

ដោយសិស្សរៀនភាសាអង់គ្លេសផង និង ភាសាបារាំងផងមានចំនួន 200 នាក់ នោះចំនួនសិស្សរៀនតែភាសាអង់គ្លេស មាន $800-200=600$ នាក់

ដូចនេះ ចំនួនសិស្សរៀនតែភាសាអង់គ្លេស មាន 600 នាក់ ។

គ. ចំនួនសិស្សរៀនតែភាសាបារាំង :

ចំនួនសិស្សរៀនតែភាសាបារាំងមាន $500-200=300$ នាក់ ។

ដូចនេះ ចំនួនសិស្សរៀនតែភាសាបារាំងមាន 300 នាក់ ។

**លំហាត់គំរូទី១** : គេបោះគ្រាប់ឡុកឡាក់ពីរគ្រាប់ មួយមានពណ៌ស មួយទៀតមានពណ៌ក្រហម ។ រកចំនួនលទ្ធផល ដែលកើតឡើងកាលណាលទ្ធផលមានផលបូកលេខ ស្មើនឹង 5 ឬ 6 ។

**ចម្លើយ** : តាង $A$ ជាព្រឹត្តិការណ៍ដែលផលបូកលេខស្មើនឹង 5 ។ គូចំនួនដែលផលបូកលេខស្មើ 5 មាន $(1,4),(2,3),(3,2),(4,1)$ ។ នោះ $n(A)=4$ ករណី ។

$B$ ជាព្រឹត្តិការណ៍ ដែលផលបូកលេខស្មើនឹង 6 ។ គូចំនួនដែលផលបូកលេខស្មើនឹង 6 មាន $(1,5),(2,4),(3,3),(4,2),(5,1)$ នោះ $n(B)=5$ ករណី ។ យើងឃើញថា $A\cap B=\varnothing \Leftrightarrow n(A\cap B)=0$

ចំនួនករណីដែលផលបូកលេខស្មើនឹង 5 ឬ 6 គឺ $n(A\cup B)=n(A)+n(B)$

$=4+5$

$=9$ ករណី

ដូចនេះ ចំនួនលទ្ធផលដែលកើតឡើងកាលណាផលបូកស្មើនឹង 5 ឬ 6 មាន 9 ករណី ។

**លំហាត់គំរូទី២** : ក្នុងថង់មួយមានបណ្ណ័ 6 សន្លឹក ដែលបង់លេខ 1,2,3,4,5,6 ។ គេចាប់យកបណ្ណ័មួយសន្លឹកដោយចៃដន្យ ។ រកចំនួនលទ្ធផលដែលកើតឡើង កាលណាលេខដែលចាប់បានជា លេខសេស ឬ លេខធំជាង 4 ។

**ចម្លើយ** : តាង $m$ ជាព្រឹត្តិការណ៍ដែលចាប់បានលេខសេស

ចំនួនទាំងនោះមាន 1,3,5

$\Rightarrow n(m)=3$ ករណី

$k$ ជាព្រឹត្តិការណ៍ដែលចាប់បានលេខធំជាង 4 ។

ចំនួនទាំងនោះមាន 5,6

$\Rightarrow n(k)=2$ ករណី

យើងឃើញថា ព្រឹត្តិការណ៍ $m$ និងព្រឹត្តិការណ៍ $k$ មានលទ្ធផលរួមមួយគឺលេខ 5 ។

$\Rightarrow n(m\cap k)=1$

ចំនួនលទ្ធផលដែលកើតឡើងកាលណាលេខចាប់បានជាលេខសេស ឬ លេខធំជាង 4 គឺ

$n(m\cup k)=n(m)+n(k)-n(m\cap k)$

$=3+2-1$

$=4$ ករណី

ដូចនេះ ចំនួនលទ្ធផលដែលកើតឡើងកាលណាលេខចាប់បានជាលេខសេស ឬ លេខធំជាង 4មាន4 ករណី។

## ២.២. គោលការណ៍ប្រមាណវិធីគុណ

ព្រឹត្តិការណ៍ខ្លះអាចកើតឡើងតាមវិធីច្រើនយ៉ាងខុសៗគ្នា ដែលយើងមិនអាចធ្វើបញ្ជីបាន។ យើងត្រូវផ្អែកលើរូបមន្ត និងគោលការណ៍គ្រឹះនៃរាប់។

- **ឧទាហរណ៍ ៖** ក្នុងពិធីជប់លៀងមួយអ្នកចូលរួមអាចជ្រើសរើស ម្ហូបអាហារដូចខាងក្រោម៖
  - អាហារ : នំពុ្ញក ឬ នំប៉័ង
  - ម្ហូប : ការីគោ, ការីត្រី ឬការីមាន់
  - បង្អែម : ការ៉េម ឬ ចេកខ្ទិះ

  តើគេអាចជ្រើសរើសអាហារបានប៉ុន្មានរបៀបខុសៗគ្នា?

ចម្លើយ : យើងត្រូវធ្វើសេចក្តីសម្រេចចិត្ត បីយ៉ាង :

| ជ្រើសរើស អាហារ | ជ្រើសរើស ម្ហូប | ជ្រើសរើស បង្អែម |
|---|---|---|
| ២ ជម្រើស | ៣ ជម្រើស | ២ ជម្រើស |




យើងឃើញថា ចំពោះជម្រើសអាហារ នីមួយៗ យើងអាចជ្រើសរើសម្ហូបបាន បីយ៉ាង និងមានពីរជម្រើសសម្រាប់បង្អែម ។

នោះជម្រើសសរុបមាន $2\times3\times2=12$ ជម្រើសខុសៗគ្នា

ដូចនេះ យើងអាចជ្រើសរើសបាន 12 ជម្រើសខុសៗគ្នា ។

> ***ទ្រឹស្តីបទ*** : យើងមានព្រឹត្តិការណ៍ពីរ $E_1$ និង $E_2$ ។ ព្រឹត្តិការណ៍ទីមួយ $E_1$ កើតឡើង $m_1$ ដងខុសៗគ្នា ។ ក្រោយពី $E_1$ បានកើតឡើង $E_2$ អាចកើតឡើងក្នុង $m_2$ ករណីខុសៗគ្នា ។ ចំនួនរបៀប រឺករណីដែលព្រឹត្តិការណ៍ទាំងពីរកើតឡើងមាន $m_1\times m_2$ ។

*សម្គាល់ :* បើព្រឹត្តិការណ៍ $E_1,E_2,E_3,...,E_n$ ហើយកើតឡើងរៀងគ្នា $m_1,m_2,m_3,...,m_n$ ករណីខុសៗគ្នា ។

នោះចំនួនករណីនៃព្រឹត្តិការណ៍ទាំងអស់មាន : $m_1\times m_2\times m_3\times...\times m_n$ ។

❖ ឧទាហរណ៍ ៖ គេមានផ្លូវបីសម្រាប់ធ្វើដំណើរពីភូមិ $A$ ទៅភូមិ $B$ និងមានផ្លូវពីរសម្រាប់ធ្វើដំណើរពីភូមិ $B$ ទៅភូមិ $C$ ។ តើគេអាចធ្វើដំណើរតាមផ្លូវបានប៉ុន្មានរបៀប ដើម្បីចេញពីភូមិ $A$ ទៅភូមិ $C$ ដោយឆ្លងកាត់តាមភូមិ $B$ ។

**ចម្លើយ** : តាង $1,2,3$ ជាផ្លូវភ្ជាប់ពីភូមិ $A$ ទៅភូមិ $B$ និង $a,b$ ជាផ្លូវភ្ជាប់ពីភូមិ $B$ ទៅភូមិ $C$ ។ ការធ្វើដំណើរពីភូមិ $A$ ទៅភូមិ $B$ មានផ្លូវ $3$ ជម្រើស សម្រាប់ធ្វើដំណើរពីភូមិ $B$ ទៅភូមិ $C$ មានផ្លូវ $2$ ជម្រើស សម្រាប់ធ្វើដំណើរ ។

តាមគោលការណ៍ផលគុណ មានផ្លូវសម្រាប់ធ្វើដំណើរពីភូមិ $A$ ទៅភូមិ $C$ មាន $3\times2=6$ ជម្រើស។




ដូចនេះ គេអាចធ្វើដំណើរបាន 6 របៀបពីភូមិ $A$ ទៅភូមិ $C$ ដោយឆ្លងកាត់តាម ភូមិ $B$ ។

**លំហាត់គំរូទី១** : គេចង់បង្កើតលេខ 4 ខ្ទង់ដោយប្រើលេខ $0,1,2,3,4$ ។ តើមានប៉ុន្មានរបៀបខុសៗគ្នាដើម្បីឱ្យលេខដែលបង្កើតបាននោះធំជាង 2000 ។ ( *បញ្ជាក់* : ចំនួននីមួយៗខាងលើគ្មានតួលេខដែលពីរដងទេ )។

**ចម្លើយ** : រកចំនួនរបៀបដែលអាចបង្កើតបាន : តាង $n$ ជាចំនួនរបៀបដែលអាចបង្កើតបាន ។

ខ្ទង់ទី១ មាន 3 ជម្រើស

ខ្ទង់ទី២ មាន 4 ជម្រើស

ខ្ទង់ទី៣ មាន 3 ជម្រើស

ខ្ទង់ទី៤ មាន 2 ជម្រើស

តាមគោលការណ៍ប្រមាណវិធីគុណ យើងបាន $n=4\times3\times3\times2=72$ របៀប

ដូចនេះ គេអាចបង្កើតបាន 72 របៀបខុសៗគ្នា។

## ៣.វិភាគ បន្សំ *(Combinational Analysis )*

### ៣.១. ហ្វាក់តូរ្យែល (***Factorial***)

ហ្វាក់តូរ្យែលនៃ $n$ (តាងដោយ $n!$ ) គឺជាផលគុណនៃ $n$ ចំនួនគត់វិជ្ជមានដំបូង ( គឺផលគុណចំនួនគត់វិជ្ជាមានបន្តគ្នាពី 1 ដល់ $n$ ) ។

$$n! = 1\times 2\times 3\times \ldots \times n$$
$$= n\times (n-1)\times \ldots \times 2\times 1$$

❖ **ឧទាហរណ៍ ៖** $4! = 4\times 3\times 2\times 1 = 24$

$7! = 7\times 6\times 5\times 4\times 3\times 2\times 1 = 5040$

*សម្គាល់* : $1! = 1$ និង $0! = 1$

❖ **ឧទាហរណ៍ ៖** គណនាផលបូក : $1.1! + 2.2! + 3.3! + \ldots + n.n!$

គេមាន : $(k+1)! = (k+1).k! = k.k! + k!, \forall k \in IN$

$\Rightarrow k.k! = (k+1)! - k!$ ឱ្យតម្លៃ $k = 1, 2, 3, \ldots, n$ យើងបាន :

$$+\begin{cases} 1.1! = 2! - 1! \\ 2.2! = 3! - 2! \\ 3.3! = 4! - 3! \\ \ldots\ldots\ldots\ldots \\ \ldots\ldots\ldots\ldots \\ \ldots\ldots\ldots\ldots \\ n.n! = (n+1)! - n! \end{cases}$$

$$S = (n+1)! - 1!$$

ដូចនេះ $S = (n+1)! - 1$

*ចំណាំ* ៖ $\boldsymbol{n}! = 1\times 2\times 3\times \ldots \times \boldsymbol{n}$

$(2\boldsymbol{n})!! = 2\times 4\times 6\times \ldots \times 2\boldsymbol{n} = 2^{n}.\boldsymbol{n}!$

$(2\boldsymbol{n}-1)!! = 1\times 3\times 5\times \ldots \times (2\boldsymbol{n}-1)$

$\boldsymbol{n}!! = \boldsymbol{n}(\boldsymbol{n}-2)(\boldsymbol{n}-4)\ \ldots$

$\boldsymbol{n}!!! = \boldsymbol{n}(\boldsymbol{n}-3)(\boldsymbol{n}-6)\ldots$

សំគាល់ $-1!! = 0!! = 1$ ***by definition ( Arfken 1985 , page 547)***

❖ **ឧទាហរណ៍ ៖** $5!=5\times4\times3\times2\times1=120$

$5!!=1\times3\times5=15$

$5!!!=5\times2=10$

$8!=5!\times6\times7\times8=40320$

$8!!=8\times6\times4\times2=384$

$8!!!=8\times5\times2=80$

## ៣.២. តំរៀប *(Arrangement)*

### ៣.២.១. *តំរៀបមិនសារឡើងវិញ*

តំរៀប $p$ ធាតុក្នុងចំនោម $n$ ធាតុនៃសំណុំ $E$ គឺជាសំណុំរងនៃ $E$ ដែលមាន $p$ ធាតុខុសៗគ្នា រៀបតាមលំដាប់មួយកំនត់ ។

ចំនួនតំរៀប $p$ ធាតុនៃសំណុំ $E$ ដែលមាន $n$ $(p\le n)$ ធាតុគឺ :

$$\boldsymbol{A_n^p=n(n-1)\ldots(n-p+1)}$$

ឬ $$\boldsymbol{A_n^p=\prod_{k=0}^{p-1}(n-k)=\frac{n!}{(n-p)!}}$$

❖ **ឧទាហរណ៍ ៖** មនុស្សមួយក្រុមមានគ្នា ៤ នាក់។ គេចង់ថតរូបម្តង ៣ នាក់។ តើគេអាចថតរូបបាន ប៉ុន្មានរបៀប ?

✓ **របៀបទី១ ៖**

**ចម្លើយ** : ដោយមនុស្សមានគ្នា ៤នាក់ ហើយគេជ្រើសរើស ៣ នាក់មកធ្វើការតំរៀបថតរូប ។

គេបាន ចំនួនតំរៀបមនុស្ស ៣ នាក់ក្នុងចំនោម មនុស្ស ៤នាក់គឺ $A_3^4=\frac{4!}{(4-3)!}=4!=24$ របៀប

ដូច្នេះ គេអាចថតរូបបាន 24 របៀប ។

✓ **របៀបទី២ ៖**

ក្នុងការជ្រើសមនុស្ស 3 នាក់ក្នុងចំនោមមនុស្ស 4 នាក់ នោះ :

- អ្នកទី១ : មាន 4 ជម្រើស
- អ្នកទី២ : មាន 3ជម្រើស
- អ្នកទី៣ : មាន 2 ជម្រើស

តាមគោលការណ៍ផលគុណ គេបាន $4\times3\times2=24$ ជម្រើស

**ដូចនេះ** គេអាចថតរូបបាន 24 របៀប

### ៣.២.២. *តំរៀប សារឡើងវិញ*

តំរៀបសារឡើងវិញ $k$ ធាតុក្នុងចំនោម $n$ ធាតុគឺ ជាតំរៀបដែលធាតុនីមួយៗ អាចមានវត្តមា $1,2,..$ $...,k$ ដង ។

$$\overline{A}_n^k = n^k$$

❖ **ឧទាហរណ៍** ៖ គេចង់បង្កើតលេខ 3 ខ្ទង់ដែលយកចេញពីលេខ $1,3,5,7,9$ ។ តើគេអាចបង្កើតលេខ 3 ខ្ទង់បានប៉ុន្មានរបៀប (បើលេខដែលប្រើអាចដូចគ្នា) ?

**ចម្លើយ** : ដោយគេបង្កើតលេខ 3 ខ្ទង់យកចេញពី 5 លេខផ្សេងគ្នា ហើយលេខដែលអាចប្រើដូចគ្នានោះ គឺ ជាតំរៀបសារឡើងវិញ ។

គេបាន ចំនួនតំរៀបសារឡើងវិញ 3ធាតុក្នុងចំនោម5គឺ $\overline{A}_5^3 = 5^3 = 125$ របៀប

**ដូចនេះ** គេអាចបង្កើតលេខ3 ខ្ទង់បាន 125 របៀប

### ៣.៣. ចម្លាស់

❖ **ឧទាហរណ៍១** ៖ មនុស្ស ៣ នាក់ ឈរថតរូបជាជួរ ។ តើគេអាចឈរថតរូបបានប៉ុន្មានករណី ?

✓ **របៀបទី១** ៖

**ចម្លើយ** : ចំនួនករណីដែលអាច ឈរថតរូបបាន

- អ្នកឈរទី១ : 3ជម្រើស
- អ្នកឈរទី២ : 2 ជម្រើស
- អ្នកឈរទី៣ : 1 ជម្រើស

តាមគោលការណ៍ផលគុណ $3\times2\times1=6$ ជម្រើស

**ដូចនេះ** របៀបដែលអាចឈរថតរូបបានគឺ 6 ករណី

**ករណីទូទៅ ៖** *ចម្លាស់នៃ $n$ វត្ថុខុសគ្នា ជាតំរៀបមានលំដាប់នៃ $n$ វត្ថុដែលវត្ថុមួយនៅលំដាប់ទី១ វត្ថុមួយទៀតនៅលំដាប់ទី២ បន្តបន្ទាប់ ។*

| |
|---|
| ចំនួនចម្លាស់នៃ $n$ វត្ថុគឺ $\boldsymbol{P}!=\boldsymbol{n}!$ |

✓ **របៀបទី២ ៖** ដោយមនុស្ស ៣ នាក់ឈរថតរូបជាជួរ គឺជាចម្លាស់មនុស្ស ៣ នាក់ជាជួរ

ចំនួនចម្លាស់គឺ $P_3=3!=3\times2\times1=6$ របៀប

**ដូចនេះ** គេអាចឈរថតរូបបាន 6 របៀប

❖ **ឧទាហរណ៍២ ៖** គរុនិស្សិតគណិតវិទ្យាក្រុម $D$ ជំនាន់ទី ២១មួយក្រុមមានគ្នា ៦ នាក់ ។ គ្រូចាត់ឱ្យសរសេរមេរៀនសង្ខេបអំពីប្រូបាប។ ក្នុងក្រុមនេះគេចង់ជ្រើស ៣ នាក់ ដើម្បីឱ្យ ១ នាក់ វាយអត្ថបទ ១នាក់ត្រួតពិនិត្យ និង ១នាក់ទៀត អ្នកនិពន្ធ ។ តើគេអាចជ្រើសរើសបានប៉ុន្មានរបៀប ?

✓ **របៀបទី១ ៖** រកចំនួនរបៀបដែលជ្រើសរើស 3 នាក់ វាយអត្ថបទមួយនាក់ មួយនាក់ ត្រួតពិនិត្យ និង មួយនាក់ទៀត និពន្ធ ។

- ជ្រើសរើសអ្នកទី១ 6 របៀប
- ជ្រើសរើសអ្នកទី២ 5 របៀប
- ជ្រើសរើសអ្នកទី៣ 4 របៀប

តាមគោលការណ៍ផលគុណ គេបាន $6\times5\times4=120$ របៀប

**ដូចនេះ** គេអាចជ្រើសរើសបាន 120 របៀប

**ជាទូទៅ ៖** *ចម្លាស់នៃ $r$ វត្ថុយកចេញពី $n$ វត្ថុគឺជាតម្រៀបមានលំដាប់នៃ $r$ វត្ថុខុសៗគ្នាដែលធាតុនីមួយៗយកចេញពី $n$ ធាតុខុសៗគ្នា $(r\le n)$ ។*

| |
|---|
| ចំនួនចម្លាស់នៃ $r$ វត្ថុយកពី $n$ វត្ថុគឺ $\boldsymbol{P(n,r)=\frac{n!}{(n-r)!}}$ |

✓ **របៀបទី២ ៖** ដោយការជ្រើសរើសមនុស្ស ៣ នាក់, ១នាក់ជាអ្នកវាយអត្ថបទ , ១នាក់ជាអ្នកត្រួតពិនិត្យ និង ១នាក់ទៀត ជាអ្នកនិពន្ធ ដោយជ្រើសរើសចេញពីមនុស្ស ៦នាក់ នោះគឺជាចម្លាស់មនុស្ស ៣នាក់ ក្នុងចំនោម ៦នាក់ ។

ចំនួនចម្លាស់គឺ $P(6,3)=\frac{6!}{(6-3)!}=\frac{6!}{3!}=6\times5\times4=120$ ជម្រើស

**ដូចនេះ** គេអាចជ្រើសរើសបាន 120 របៀប

❖ **ឧទាហរណ៍៣ ៖** គេចង់បង្កើតលេខ 4 ខ្ទង់ ដោយប្រើលេខ $1,3,5,7$ ( ដែលលេខ 4 ខ្ទង់នោះអាចជាលេខដូចគ្នា )។ តើគេអាចបង្កើតលេខ 4 ខ្ទង់ នោះគេបានប៉ុន្មានរបៀប?

✓ **របៀបទី១ ៖** រកចំនួនរបៀបដែលបង្កើតបាន :

ដោយការបង្កើតលេខ 4 ខ្ទង់អាចប្រើលេខដូចគ្នា នោះគេបាន

- ខ្ទង់ទី១ : 4 ជម្រើស
- ខ្ទង់ទី២ : 4 ជម្រើស
- ខ្ទង់ទី៣ : 4 ជម្រើស
- ខ្ទង់ទី៤ : 4 ជម្រើស

តាមគោលការណ៍ផលគុណ គេបាន $4\times4\times4\times4=4^4=256$ របៀប

**ដូចនេះ** គេអាចបង្កើតបាន 4 ខ្ទង់បាន 256 របៀប

**ជាទូទៅ ៖** *ចម្លាស់ច្រំដែលនៃ $n$ វត្ថុ គឺ $P_{n,r}=n^n$ ។*

✓ **របៀបទី២ ៖** ដោយការបង្កើតលេខ 4 ខ្ទង់ អាចប្រើលេខដូចគ្នានោះគឺ ជាចម្លាស់ច្រំដែល នៃ 4 លេខគឺ $P_{4,r}=256$ របៀប

**ដូចនេះ** គេអាចបង្កើតលេខ 4 ខ្ទង់បាន 256 របៀប ។

❖ **ឧទាហរណ៍៤ ៖** គេចង់បង្កើតលេខ 3 ខ្ទង់ដែលជ្រើសរើសចេញពីលេខ $1,2,3,4,5$ ។
តើគេអាចបង្កើតលេខ 3 ខ្ទង់នេះបានប៉ុន្មានរបៀប ?

✓ **របៀបទី១ ៖** ចំនួនលេខ 3 ខ្ទង់ដែលអាចបង្កើតបាន

- ខ្ទង់ទី១ : 5 ជម្រើស
- ខ្ទង់ទី២ : 5 ជម្រើស
- ខ្ទង់ទី៣ : 5 ជម្រើស

តាមគោលការណ៍ផលគុណគេមាន $5\times5\times5=5^3=125$ របៀប

**ជាទូទៅ ៖** *ចម្លាស់ច្រំដែលនៃ $r$ វត្ថុយកចេញពី $n$ វត្ថុគឺជាតម្រៀបមានលំដាប់នៃ $r$ វត្ថុដែល វត្ថុនីមួយៗអាចជាវត្ថុដដែលយក ចេញពី $n$ វត្ថុ ខុសៗគ្នា $(r\le n)$ ។*

| ចំនួនចម្លាស់ច្រំដែល នៃ $r$ វត្ថុយកពី $n$ វត្ថុ គឺ $\boldsymbol{P_{n,r}=n^r}$ |
|---|

✓ របៀបទី២ ៖ ក្នុងការបង្កើតលេខ 3 ខ្ទង់អាចមានលេខដូចគ្នាដែលជ្រើសរើសចេញពី 5 លេខផ្សេងគ្នា នោះគឺជាចម្លាស់ច្រំដែលនៃ3លេខ យកពី 5 លេខគឺ $P_{5,3}=5^3=125$ របៀប

ដូចនេះ គេអាចបង្កើតលេខ 3 ខ្ទង់ បាន125 របៀប

### ៣.៣.១.ចម្លាស់រង់ *(Circle Permutation)*

ចម្លាស់រង់នៃ $n$ ធាតុគឺជាចម្លាស់ នៃ $n$ ធាតុខុសៗគ្នាជារង្វង់ ។

| ចំនួនចម្លាស់រង់នៃ $n$ ធាតុស្មើនឹង $(n-1)!$ |
|---|

❖ ឧទាហរណ៍ ៖ ចូរសរសេរចម្លាស់រង់ $A,B,C,D$

| | | | |
|---|---|---|---|
| *ABCD* | *BACD* | *CABD* | *DABC* |
| *ABDC* | *BADC* | *CADB* | *DACB* |
| *ADBC* | *BCAD* | *CBAD* | *DBAC* |
| *ADCB* | *BCDA* | *CBDA* | *DBCA* |
| *ACBD* | *BDAC* | *CDAB* | *DCAB* |
| *ACDB* | *BDCA* | *CDBA* | *DCBA* |



គិតតែ១ករណី

គេបាន

$$\left.\begin{array}{ll} ABCD & (1) \\ \text{BCDA} & (2) \\ CDAB & (3) \\ \text{DABC} & (4) \end{array}\right\}$$ ៤របៀបខុសៗគ្នា

ដូច្នេះ ចម្លាស់រង់នៃ $A,B,C,D$ គឺ $\frac{4!}{4}=6$ របៀប

### ៣.៣.២.ចម្លាស់បែងចែកបាន *(Permutation with identical objects)*

ចម្លាស់ $n$ វត្ថុដែលក្នុងនោះមានវត្ថុប្រភេទទី១ ប្រភេទទី២ ....ប្រភេទទីk ហើយវត្ថុប្រភេទនីមួយៗមានចំនួន $r_1, r_2, ...r_k$ រៀងគ្នា $(r_1+r_2+...+r_k=n)$ ហៅថាចម្លាស់បែងចែកបាន ។

| ចំនួនចម្លាស់បែងចែកបាន គឺ $\frac{n!}{r_1!r_2!...r_k!}$ |
|---|

**ឧទាហរណ៍ ៖** ចូររកចំនួនចម្លាស់នៃពាក្យថា *STATISTICS* ?

ដោយពាក្យថា *STATISTICS* មាន $n=10$ តួអក្សរ

ហើយក្នុងនោះ $A$ មាន ១ តួអក្សរ

$C$ មាន ១ តួអក្សរ

$S$ មាន ៣ តួអក្សរ

$T$ មាន ៣ តួអក្សរ

$I$ មាន ២ តួអក្សរ

ដូចនេះ ចំនួនចម្លាស់នៃពាក្យថា *STATISTICS* គឺ $\frac{10!}{1!1!3!3!2!}=50400$ របៀប

### ៣.៤. បន្សំ (Combination )

ក្នុង*ចម្លាស់*លំដាប់មានសារៈសំខាន់ណាស់ ។ តម្រៀបដែលមិនគិតលំដាប់ហៅថា ***បន្សំ*** ។

I. **និយមន័យ ៖** *បន្សំជាតម្រៀបមិនគិតលំដាប់ ។*

**ជាទូទៅ ៖** *បន្សំនៃ $k$ ធាតុយកពី $n$ ធាតុគឺជាការយកព្រមគ្នាម្តងយក $k$ ធាតុ យកចេញពី $n$ ធាតុខុសៗគ្នាដោយមិនគិតពីលំដាប់នៃការយកចេញ។*

> ចំនួនបន្សំនៃ $k$ ធាតុយកពី $n$ ធាតុ គឺ $C_n^k=\frac{P(n,k)}{k!}=\frac{n!}{(n-k)!k!}$ $(k\in IN, n\in IN, k\le n)$

II. **លក្ខណៈនៃបន្សំ**

- $C(n,k)=C(n,n-k)$
- $C(n,k)=\frac{n}{k}C(n-1,k-1)$
- $C(n,k+1)=C(n,k)\times\frac{n-k}{k+1}$
- $C(n,k)=C(n-1,k-1)+C(n-1,k)$

❖ **ឧទាហរណ៍ ៖** ក្នុងល្បែងបៀ 52 សន្លឹក។ គេទាញបៀ 5 សន្លឹកដោយចៃដន្យ ។

តើមានប៉ុន្មានរបៀបដើម្បីបាន ៖

ក). បៀ 2 សន្លឹកជាអាត់

ខ). ច្រើនបំផុតមានអាត់ 2 សន្លឹក

គ). តិចបំផុតមានអាត់ 2 សន្លឹក

ឃ). មានអាត់ 1 សន្លឹក និង ស្តេច1 សន្លឹក

**ចម្លើយ**

រកចំនួនរបៀបដើម្បីបាន

ក). បៀ 2 សន្លឹកជាអាត់

បៀ 5 សន្លឹក មានអាត់ 2 សន្លឹកមានន័យថាត្រូវយកបៀ 2 សន្លឹកក្នុងបៀ 4 សន្លឹកជាអាត់ និង បៀ3 សន្លឹកទៀតរើសក្នុងបៀ 48 សន្លឹកទៀតដែលមិនមែនជាអាត់។

**ដូចនេះ** ចំនួនរបៀបដើម្បីទាញបានបៀ 5 សន្លឹកមានអាត់ 2 សន្លឹកគឺ

$$C(4,2)\times C(48,3)=\frac{4!}{2!2!}\times\frac{48!}{45!\times 3!}$$
$$=\frac{4\times3\times2!}{2\times1\times2!}\times\frac{48\times47\times46\times45}{45!\times3\times2\times1}$$
$$=103776 \text{ របៀប}$$

ខ). ច្រើនបំផុតមានអាត់ 2 សន្លឹក

ព្រឹត្តិការណ៍បៀ 2 សន្លឹក មានអាត់យ៉ាងច្រើន 2 សន្លឹកគឺជាព្រឹត្តិការណ៍ហ្វូតបាន បៀ 2 សន្លឹកជាអាត់ និង បៀ 3 សន្លឹក ផ្សេងទៀតមិនមែនជាអាត់ ឬ បៀ1 សន្លឹកជាអាត់ និង បៀ 4 សន្លឹក ផ្សេងទៀតមិនមែនជាអាត់ ឬ បៀ 5 សន្លឹកគ្មានអាត់សោះ ។

**ដូចនេះ** ចំនួនរបៀបដើម្បីបាន អាត់ 2 សន្លឹកយ៉ាងច្រើន តាងដោយ $N$ គឺ

$$N=C(4,2)\times C(48,3)+C(4,1)\times C(48,4)+C(4,0)\times C(48,5)$$
$$=\frac{4!}{2!2!}\times\frac{48!}{45!3!}+\frac{4!}{3!1!}\times\frac{48!}{44!4!}+\frac{4!}{4!0!}\times\frac{48!}{43!5!}$$
$$=103776+778320+1712304=2594400$$

| |
|---|
| $N=2594400$ របៀប |

គ). តិចបំផុតមានអាត់ 2 សន្លឹក

ព្រឹត្តិការណ៍បៀ 2 សន្លឹកដែលយ៉ាងតិចមានអាត់ 2 គឺ បៀ 2 សន្លឹកជាអាត់ និង 3 សន្លឹកផ្សេងទៀតមិនមែនជាអាត់ ឬ បៀ3 សន្លឹកជាអាត់ និង 2 សន្លឹកផ្សេង មិនមែនជាអាត់ ឬ បៀ 4 សន្លឹកជាអាត់ និងបៀ 1 សន្លឹកផ្សេងទៀតមិនមែនជាអាត់។

ដូចនេះ ចំនួនរបៀបយ៉ាងតិចមានអាត់ 2 សន្លឹកតាងដោយ $N$ គឺ:

$$N^{'}=C(4,2)\times C(48,3)+C(4,3)\times C(48,2)+C(4,4)\times C(48,1)$$

$$=\frac{4!}{2!2!}\times\frac{48!}{45!\times 3!}+\frac{4!}{1!3!}\times\frac{48!}{46!\times 2!}+\frac{4!}{4!0!}\times\frac{48!}{47!1!}$$

$$=103776+4512+48$$

$$\boxed{N^{'}=108336}$$

ឃ). មានអាត់ 1 សន្លឹកនិងស្តេច1 សន្លឹក

- មាន $C(4,1)$ របៀបដែលទាញបានបៀអាត់ 1 សន្លឹក
- មាន $C(4,1)$ របៀបដែលទាញបានបៀស្តេច 1 សន្លឹក
- មាន $C(44,3)$ របៀបដែលទាញបានបៀ 3 សន្លឹកដែលមិនមែនជាអាត់ និងស្តេច ។

ដូចនេះ ចំនួនរបៀបដែលហូតបានបៀអាត់1 សន្លឹក និងស្តេច1 សន្លឹក តាងដោយ $N^{''}$ គឺ

$$N^{''}=C(4,1)\times C(4,1)\times C(44,3)$$

$$=4\times 4\times\frac{44!}{41!3!}=211904$$

$$\boxed{N^{''}=211904 \text{ របៀប}}$$

## ៤.ទ្រឹស្តីទ្វេធា និងពហុធា *(The Binomai Theorem)*

### ៤.១. ទ្រឹស្តីបទទ្វេធា

#### ៤.១.១ ទ្វេធា *(Binomial )*

**និយមន័យ** *ទ្វេធា (binomial) គឺជាពហុធាដែលមានពីរតួ ។* មានន័យថា ជាកន្សោមពីជគណិតមានពីរតួផ្សេងពីគ្នា ។

**ឧទាហរណ៍១ ៖** $2x+4y, cx^3-ay, 1-x, v+u$ ជាកន្សោមពីជគណិតដែលហៅថា *ទ្វេធា* ។

#### ៤.១.២.មេគុណទ្វេធា ( Binomial Coefficient )

**និយមន័យ ៖** មេគុណទ្វេធា $\boldsymbol{C(n,m)=C_m^n=C_n^m={}^nC_m={}_nC_m=C_{n,m}=\binom{n}{m},(m\le n)}$ ជាចំនួននៃវិធីជ្រើសរើស m វត្ថុចេញពី n វត្ថុផ្សេងៗគ្នាដោយគ្មានទាក់ទងនឹងលំដាប់។



*Andreas Von Ettingshausen*
(1796 – 1878)

កំណាត់សរសេរ៖ $\binom{n}{m}=\dfrac{n!}{m!(n-m)!},(\forall m\le n)$ ។

**ចំណាំ៖**

$n!=1\times 2\times\cdots\times n$

$0!=1!=1$

***សម្គាល់ ៖*** $\binom{n}{m}$ *ត្រូវបានណែនាំឱ្យស្គាល់ដោយគណិតវិទូ និងរូបវិទូអាល្លឺម៉ង់* **Andreas Von Ettingshausen** *(1796 – 1878) នៅឆ្នាំ1826 ។*

**ឧទាហរណ៍ ៖** **ក**. ចំពោះ 5 ធាតុ នៃសំនុំ $S=\{a,b,c,d,e\}$ គឺមានសំនុំរង *(subsets)* ដែល $n=\binom{5}{3}=\frac{5!}{2!3!}=10$ សំនុំរង ដែលមាន 3ធាតុប្រាកដផ្សេងៗគ្នារួមមាន៖

$\{a,b,c\},\{a,b,d\},\{a,b,e\},\{a,c,d\},\{a,c,e\},$

$\{b,c,d\},\{a,c,e\},\{b,d,e\},\{b,c,d\},\{c,d,e\}.$

**ខ**. គេមានវត្ថុ 8 ផ្សេងៗគ្នា បន្ទាប់មកចាប់ផ្តើមទុកវត្ថុនេះក្នុងថតតុ 3 ( ថតទី I , ថតទី II , ថតទី III ) ។ ថតទី I ដាក់វត្ថុ 3 ថតទី II ដាក់វត្ថុ 1 ថតទី III ដាក់វត្ថុ 4 ។ តើគេអាចទុកវត្ថុទាំងនេះបានប៉ុន្មានរបៀប ?

ការទុកវត្ថុនេះជាបីដំណាក់កាល គឺ៖

- រើសវត្ថុ 3 ទុកក្នុងថតទី I បាន $\binom{8}{3}=\frac{8!}{5!3!}=56$ របៀប
- រើសវត្ថុ 1 ទុកក្នុងថតទី II បាន $\binom{5}{1}=\frac{5!}{1!4!}=5$ របៀប
- រើសវត្ថុ 4 ទុកក្នុងថតទី III បាន $\binom{4}{4}=\frac{4!}{0!4!}=1$ របៀប

ដូច្នេះ គេអាចទុកវត្ថុទាំង៖ក្នុងថតតុ 3 បាន $56\times5\times1=280$ របៀប ។



*Blaise Pascal*
(1623 – 1662)

***សម្គាល់៖*** *មេគុណទ្វេធាអាចរកបានដែរតាមរយៈត្រីកោណប៉ាស្កាល់(Pascal triangle) ដែលត្រូវហៅតាមឈ្មោះ* ***Blaise Pascal (1623-1662)*** *ជាអ្នកគណិតវិទូ រូបវិទូ សាសនាវិទ្យា និងទស្សនវិជ្ជា ជនជាតិបារាំង នៅពេលអាយុ 20ឆ្នាំបានបង្កើតម៉ាស៊ីនបូក លេខដំបូងគេបង្អស់។* ខាងក្រោមនេះជាតារាងត្រីកោណប៉ាស្កាល់ (Pascal's Triangle) ៖

| ស្វ័យគុណនៃ n | មេគុណទ្វេធានៃ $(a+b)^n$ |
|---|---|
| 0 | 1 |
| 1 | 1 1 |
| 2 | 1 2 1 |
| 3 | 1 3 3 1 |
| 4 | 1 4 6 4 1 |
| 5 | 1 5 10 10 5 1 |
| … | 1 ...................................................................... 1 |
| n-1 | 1 ............................ $C_{n-1}^{k-2}$ $C_{n-1}^{k-1}$ $C_{n-1}^{k}$ ................ 1 |
| $n$ | 1 ............ $C_n^{k-2}$ $C_n^{k-1}$ $C_n^{k}$ ... ......... $C_n^{n-1}$ 1 |

**ជាទូទៅ៖** $\binom{n+1}{k}=\binom{n}{k}+\binom{n}{k-1}$

### ៤.១.៣. លក្ខណៈមេគុណទ្វេធា ( Properties of binomial coefficient )

1. $\binom{n}{m}, m \le n$ គឺជាចំនួនគត់វិជ្ជមាន
2. $\binom{n}{m} = \frac{n!}{m!(n-m)!} = \binom{n}{n-m}$
3. $\binom{n}{0} = \binom{n}{n} = 1$ និង $\binom{n}{1} = n$
4. $\binom{n+1}{m} = \binom{n}{m} + \binom{n}{m-1}$ ( ត្រីកោណប៉ាស្កាល់ )
5. $\binom{n}{0} + \binom{n}{1} + \cdots + \binom{n}{n} = 2^n$
6. $\binom{2n}{n} = \binom{n}{0}^2 + \binom{n}{1}^2 + \cdots + \binom{n}{n}^2$
7. $\binom{n}{0} - \binom{n}{1} + \cdots + (-1)^n \binom{n}{n} = 0 \quad , n \ge 1$
8. បើ $m, n$ ជាចំនួនគត់ ហើយគឺ $m > n$ នោះ $\binom{n}{m} = 0$

ឧទាហរណ៍២ ៖

$$A = \frac{\binom{100}{98} + \binom{1000}{998}}{\binom{1000}{2} + \binom{100}{2}} + \frac{\binom{20}{4}}{\binom{18}{3} + \binom{18}{4} + \binom{19}{3}}$$

$$= \frac{\binom{100}{2} + \binom{1000}{2}}{\binom{1000}{2} + \binom{100}{2}} + \frac{\binom{20}{4}}{\binom{19}{4} + \binom{19}{3}}$$

ពីព្រោះ $\binom{100}{98} = \binom{100}{100-98} = \binom{100}{2}$ និង $\binom{18}{3} + \binom{18}{4} = \binom{19}{4}$

ដូច្នេះ $A = 1 + \frac{\binom{20}{4}}{\binom{20}{4}} = 2$

## ៤.២.៤ ទ្រឹស្តីបទទ្វេធា(The Binomial Theorem)

❖ **ទម្រង់ទាំងបីនៃទ្រឹស្តីបទទ្វេធា ៖**

**ក.** *ទម្រង់ទី១* $(a+b)^2 = a^2 + 2ab + b^2$

**ខ.** *ទម្រង់ទី២* $(a-b)^2 = a^2 - 2ab + b^2$

**គ.** *ទម្រង់ទី៣* $(a+b)(a-b) = a^2 - b^2$

ទម្រង់ទាំងបីនៃរូបមន្តខាងលើគឺអនុវត្តន៍គ្រប់តម្លៃពិត (real numbers) និងចំនួនកុំផ្លិច (complex numbers) $a,b$ ។ ចំពោះ ***ទម្រង់ទី២*** ការពិតទៅជាវិបាកនៃ ***ទម្រង់ទី១*** ដោយគ្រាន់តែជំនួស $b$ ដោយ $-b$ ។

➢ **រូបមន្តទូទៅនៃទម្រង់ទី១ ៖** សម្រាប់តម្លៃ $n=1,2,\cdots$ និងគ្រប់ចំនួនពិត ឬចំនួនកុំផ្លិច $a,b$ $(a \neq b)$ នោះយើងបានរូបមន្តទូទៅ $(\boldsymbol{a}+\boldsymbol{b})^n = \boldsymbol{a}^n + \binom{\boldsymbol{n}}{1}\boldsymbol{a}^{n-1}\boldsymbol{b} + \cdots + \binom{\boldsymbol{n}}{\boldsymbol{n}-1}\boldsymbol{a}\boldsymbol{b}^{n-1} + \boldsymbol{b}^n$

ជាមួយគ្នានេះដែរយើងអាចសរសេរជានិមិត្តសញ្ញាផលបូកគឺ៖ $(\boldsymbol{a}+\boldsymbol{b})^n = \sum_{k=0}^{n}\binom{\boldsymbol{n}}{\boldsymbol{k}}\boldsymbol{a}^{n-k}\boldsymbol{b}^k$

➢ **រូបមន្តទូទៅនៃទម្រង់ទី២ ៖** សម្រាប់រូបមន្តទូទៅនៃទម្រង់នេះគឺយើងគ្រាន់តែប្តូរ $b$ ទៅ $-b$ នោះយើងបាន $(\boldsymbol{a}-\boldsymbol{b})^n = \sum_{k=0}^{n}\binom{\boldsymbol{n}}{\boldsymbol{k}}(-1)^k\boldsymbol{a}^{n-k}\boldsymbol{b}^k$ ជាការស្រេច។



*Isaac Newton*
$(1642-1726)$

➢ **រូបមន្តទូទៅនៃទម្រង់ទី៣ ៖** សម្រាប់តម្លៃ $n=1,2,\cdots$ និងគ្រប់ចំនួនពិត ឬចំនួនកុំផ្លិច $a,b$ $(a \neq b)$ នោះ យើងបានរូបមន្តទូទៅជា $a^{n+1} - b^{n+1} = (a-b)(a^n + a^{n-1}b + \cdots + ab^{n-1} + b^n)$ មួយគ្នានេះដែរយើងអាចសរសេរជានិមិត្តសញ្ញាផលបូកគឺ៖ $\dfrac{\boldsymbol{a}^{n+1} - \boldsymbol{b}^{n+1}}{\boldsymbol{a}-\boldsymbol{b}} = \boldsymbol{a}^n + \boldsymbol{a}^{n-1}\boldsymbol{b} + \cdots + \boldsymbol{a}\boldsymbol{b}^{n-1} + \boldsymbol{b}^n = \sum_{k=0}^{n}\boldsymbol{b}^k\boldsymbol{a}^{n-k}$

***សម្គាល់៖*** *សម្រាប់រូបមន្តទូទៅទម្រង់ទី1 នៅពេលដែល $a=1$, $b=x$ នោះជា ករណីពិសេសនៃទ្រឹស្តីបទទ្វេធាដែលគេហៅថា ទ្វេធាញូតុន***(Newton Binomial)*** ដែលយកតាមឈ្មោះ **Isaac Newton (1642-1726)** ជាអ្នកគណិតវិទូ និងរូបវិទូ ជនជាតិ អង់គ្លេស បានរយើញនូវអាយុ 24 ឆ្នាំជាទម្រង់ទូទៅមានហេតុដើមទាញចេញពីរូបមន្តទូទៅនៃស៊េរី ។*

ខាងក្រោមនេះជាទ្វេធាញូតុន ៖

$$(1+x)^n = 1+\binom{n}{1}x+\cdots+\binom{n}{n-1}x^{n-1}+x^n = \sum_{k=0}^{n}\binom{n}{k}x^k$$

**ឧទាហរណ៍៣ ៖ ក.** ចូរគណនា $I_n = \int_0^1 (1+x)^n dx \,;\forall x = 0,1,2,\cdots$

**ខ.** ទាញបង្ហាញថា $1+\frac{\binom{n}{1}}{2}+\frac{\binom{n}{2}}{3}+\cdots+\frac{1}{n+1}=\frac{2^{n+1}-1}{n+1}$ ។

**ចម្លើយ ៖ ក.** គណនា $I_n = \int_0^1 (1+x)^n dx \,;\forall n = 0,1,2,\cdots$

យើងតាង $u = 1+x \Rightarrow du = dx$ បើ $x=0 \Rightarrow u=1$ និង $x=1 \Rightarrow u=2$

នោះ $I_n = \int_0^1 (1+x)^n dx = \int_1^2 u^n du$

$$= \left[\frac{u^{n+1}}{n+1}\right]_1^2$$

$$= \frac{2^{n+1}}{n+1} - \frac{1}{n+1}$$

ដូចនេះ $I_n = \frac{2^{n+1}-1}{n+1}$ ។

**ខ.** ទាញថា $1+\frac{\binom{n}{1}}{2}+\frac{\binom{n}{2}}{3}+\cdots+\frac{1}{n+1}=\frac{2^{n+1}-1}{n+1}$

យើងដឹងថាទ្វេធាញូតុន $(1+x)^n = \sum_{k=0}^{n}\binom{n}{k}x^k$ នោះ

$$I_n = \int_0^1 (1+x)^n dx$$

$$= \int_0^1 \left(1+\binom{n}{1}x+\binom{n}{2}x^2+\cdots+x^n\right)dx$$

$$= \left[x+\frac{\binom{n}{1}}{2}x^2+\frac{\binom{n}{2}}{3}x^3+\cdots+\frac{x^{n+1}}{n+1}\right]_0^1$$

នាំឱ្យ $I_n = 1+\frac{\binom{n}{1}}{2}+\frac{\binom{n}{2}}{3}+\cdots+\frac{1}{n+1}$

តែ $I_n = \frac{2^{n+1}-1}{n+1}$

ដូចនេះ $I_n = 1+\frac{\binom{n}{1}}{2}+\frac{\binom{n}{2}}{3}+\cdots+\frac{1}{n+1}=\frac{2^{n+1}-1}{n+1}$

### ៤.៣.ទ្រឹស្តីបទពហុធា (The Polynomial Theorem / Multinomial Theorem)

#### ៤.៣.១.ពហុធា (Multinomial)

***និយមន័យ*** ៖ តាមគណៈកម្មាធិការជាតិភាសាខ្មែរ (គ.ជ.ភ.ខ) ដែលបច្ចុប្បន្នជាក្រុមប្រឹក្សាជាតិភាសាខ្មែរ(ក.ជ.ភ.ខ) បានអនុម័តនូវពាក្យ " កន្សោមពីជគណិតមានផលបូកតួជាច្រើន ដែលតួ នីមួយៗ គឺជាផលគុណចំនួនថេរមួយ និងអថេរមួយ ឬច្រើន។បើសិនមានអថេរ $x$ មួយ នោះទម្រង់ ទូទៅកំណត់ដោយ $a_0+a_1x+a_2x^2+\cdots+a_nx^n$ ដែល $a_i;i\in\overline{0,n}$ ជាចំនួនថេរ " ។ ចំនែកឯពាក្យ "កន្សោមពីជគណិតជាផលបូកនៃពីរតួ ឬច្រើនតួ" ។

**ឧទាហរណ៍៖** $x^2-2xy+y^2, 3x^3-xy+2xy^2-y^2, 1+x-2x^2+3x^3-x^4$ ជាពហុធា។

#### ៤.៣.២.មេគុណពហុធា (Multinomial Coefficient )

**និយមន័យ** ៖ មេគុណពហុធា $\binom{n_1+n_2+\cdots+n_k=n}{n_1,n_2,\cdots,n_k}=C(n;n_1,n_2,\cdots,n_k)=(n_1,n_2,\cdots,n_k)!$ ជាចំនួនរបៀបនៃរើសវត្ថុ $n_1$ នៃប្រភេទទី1 បន្ទាប់មកវត្ថុ $n_2$ ជាប្រភេទទី2 រហូតដល់វត្ថុ $n_k$ ជាប្រភេទទី $k$ ចេញពីការប្រមូលផ្តុំវត្ថុ $n$ ផ្សេងៗគ្នាដោយឥតគិតលំដាប់ ដែលផ្ទៀងផ្ទាត់ $\sum_{i=1}^{k}n_i=n$ ។

កំណត់សរសេរ៖ $$\binom{n}{n_1,n_2,\cdots,n_k}=\frac{n!}{n_1!n_2!\cdots n_k!}$$ ។

- **ឧទាហរណ៍៤** ៖ សម្រាប់សំណុំ $\{a,a,b,c\}$ ដែលប៉ារ៉ាម៉ែត្រ $n=4,k=3,n_1=2,n_2=1,n_3=1$។ ដូច្នោះគឺមាន $\binom{4}{2,1,1}=\frac{4!}{2!1!1!}=12$ របៀប ដែលបង្ហាញដូចខាងក្រោម៖

  *aabc, aacb, abac, abca, acab, acba,*
  *baac, baca, bcaa, caab, caba, cbaa.*

- **ឧទាហរណ៍៥** ៖ ចំនួនរបៀបរើសវត្ថុ ២, បន្ទាប់មកវត្ថុ១, បន្ទាប់មកវត្ថុ១ទៀត ចេញពីសំណុំ $\Omega=\{a,b,c,d\}$ *(មានន័យថាជារូបមន្តចំលាស់សារឡើងវិញនៃ៤ធាតុ)* គឺមាន $\binom{4}{2,1,1}=\frac{4!}{2!1!1!}=12$ របៀប។ យើងបាននូវរបៀបដូចខាងក្រោម(របាររបន្ទាត់ព្រួយឈរ ($\uparrow$) បង្ហាញលំដាប់នៃការរើស៖

  $\uparrow ab\uparrow c\uparrow d\uparrow,\ \uparrow ab\uparrow d\uparrow c\uparrow,\ \uparrow ac\uparrow b\uparrow d\uparrow,\ \uparrow ac\uparrow d\uparrow b\uparrow,$
  $\uparrow ad\uparrow b\uparrow c\uparrow,\ \uparrow ad\uparrow c\uparrow b\uparrow,\ \uparrow bc\uparrow a\uparrow d\uparrow,\ \uparrow bc\uparrow d\uparrow a\uparrow,$
  $\uparrow bd\uparrow a\uparrow c\uparrow,\ \uparrow bd\uparrow c\uparrow a\uparrow,\ \uparrow cd\uparrow a\uparrow b\uparrow,\ \uparrow cd\uparrow b\uparrow a\uparrow.$

❖ ឧទាហរណ៍៣ ៖ ចំនួននៃវិធីរៀប ៥ធាតុនៃអក្សរ ៣ធាតុនៃអក្សរ និង៤ធាតុនៃអក្សរ គឺ $\binom{12}{5,3,4}=\frac{12!}{5!3!4!}=27720$ របៀប។

❖ ឧទាហរណ៍៦ ៖ មេគុណនៃកន្សោម $x_1^2x_2^3x_3^4$ នៅក្នុងពហុធាគឺ $(x_1+x_2+x_3)^9$

$$\binom{9}{2,3,4}=\frac{9!}{2!3!4!}=1260$$ ។

**ករណីពិសេស៖** *នៅពេលដែល* $k=2$ *នោះមេគុណពហុធាគឺ* $\binom{n}{n_1,n_2}=\binom{n}{n_1}=\binom{n}{n_2},\forall n=n_1+n_2$

❖ ឧទាហរណ៍៧៖ $\binom{5}{2,3}=\binom{5}{2}=\binom{5}{3}=\frac{5!}{2!3!}=10$ ។

*នៅពេលដែល* $k=n,n_1=n_2=\cdots=n_k=1$ *នោះ* $\binom{n}{1,1,\cdots,1}=n!$

ឧទាហរណ៍៖ $\binom{4}{1,1,1,1}=\frac{4!}{1!1!1!1!}=4!=24$ ។

### ៤.៣.២.ទ្រឹស្តីបទពហុធា *(Multinomial Theorem)*

**និយមន័យ ៖** គ្រប់ចំនួនពិត ( Real numbers ) $x_1,x_2,\cdots,x_m$ និងចំនួនគត់ធម្មជាតិ( Natural numbers ) $n,\alpha,k_1,k_2,\cdots,k_m$ នោះយើងបានរូបមន្តទូទៅនៃ $(x_1+x_2+\cdots+x_m)^n=X_m^n$ ដែល

$$\boldsymbol{X_m^n}=\sum_{k_1+k_2+\cdots+k_m=n}\binom{\boldsymbol{n}}{\boldsymbol{k_1,k_2,\cdots,k_m}}\prod_{1\le\alpha\le m}\boldsymbol{x_\alpha}^{k_\alpha}$$ ។

**ចំណាំ៖** $n$ ជាចំនួនស្វ័យគុណ និង $m$ ជាចំនួនតួ។

( បកស្រាយរូបមន្តនៃទ្រឹស្តីបទនេះនូវផ្នែកលំហាត់ និងចម្លើយ )

❖ ឧទាហរណ៍៨ ៖ ចូរពន្លាត់កន្សោម $X_3^4=(x_1+x_2+x_3)^4$

***ជំហានទី១៖*** យក $\binom{4}{k_1,k_2,k_3}$ ពីព្រោះកន្សោម $X_3^4$ មានស្វ័យគុណ4និងមាន3តួគឺ $x_1,x_2,x_3$

***ជំហានទី២៖*** រកគ្រប់សំណុំតម្លៃចំនួនគត់វិជ្ជមានដែល $k_1+k_2+k_3=4$ ; $\forall k_1,k_2,k_3\le 4$ យើងបានសំណុំតម្លៃ $(k_1,k_2,k_3)$ គឺមាន $5\times3=15$

**ចម្លើយ** រួមមាន ៖

$(0,0,4),(0,4,0),(0,1,3),(0,3,1),(0,2,2),(1,1,2),(1,2,1),(1,3,0),(1,0,3),(2,2,0),(2,0,2),(2,1,1),(3,1,0),(3,0,1),(4,0,0)$ ។

**ជំហានទី៣៖** យកសំណុំតម្លៃខាងលើយកទៅជំនួសចូលកន្សោម $\binom{4}{k_1,k_2,k_3}x_1^{k_1}x_2^{k_2}x_3^{k_3}$

$$\bullet(0,0,4)\to\binom{4}{0,0,4}x_1^0x_2^0x_3^4=\frac{4!}{0!0!4!}x_3^4=x_3^4$$

$$\bullet(0,4,0)\to\binom{4}{0,4,0}x_1^0x_2^4x_3^0=\frac{4!}{4!0!0!}x_2^4=x_2^4$$

$$\bullet(0,1,3)\to\binom{4}{0,1,3}x_1^0x_2^1x_3^3=\frac{4!}{0!1!3!}x_2x_3^3=4x_2x_3^3$$

$$\bullet(0,3,1)\to\binom{4}{0,3,1}x_1^0x_2^3x_3^1=\frac{4!}{0!3!1!}x_2^3x_3=4x_2^3x_3$$

$$\bullet(0,2,2)\to\binom{4}{0,2,2}x_1^0x_2^2x_3^2=\frac{4!}{0!2!2!}x_2^2x_3^2=6x_2^2x_3^2$$

$$\bullet(1,1,2)\to\binom{4}{1,1,2}x_1^1x_2^1x_3^2=\frac{4!}{1!1!2!}x_1x_2^2x_3^2=12x_1x_2^2x_3^2$$

$$\bullet(1,2,1)\to\binom{4}{1,2,1}x_1^1x_2^2x_3^1=\frac{4!}{1!2!1!}x_1x_2^2x_3=12x_1x_2^2x_3$$

$$\bullet(1,3,0)\to\binom{4}{1,3,0}x_1^1x_2^3x_3^0=\frac{4!}{1!3!0!}x_1x_2^3=4x_1x_2^3$$

$$\bullet(1,0,3)\to\binom{4}{1,0,3}x_1^1x_2^0x_3^3=\frac{4!}{1!0!3!}x_1x_3^3=4x_1x_3^3$$

$$\bullet(2,2,0)\to\binom{4}{2,2,0}x_1^2x_2^2x_3^0=\frac{4!}{2!2!0!}x_1^2x_2^2=6x_1^2x_2^2$$

$$\bullet(2,0,2)\to\binom{4}{2,0,2}x_1^2x_2^0x_3^2=\frac{4!}{2!0!2!}x_1^2x_3^2=6x_2^2x_3^2$$

$$\bullet(2,1,1)\to\binom{4}{2,1,1}x_1^2x_2^1x_3^1=\frac{4!}{2!1!1!}x_1^2x_2x_3=12x_1^2x_2x_3$$

$$\bullet(3,1,0)\to\binom{4}{3,1,0}x_1^3x_2^1x_3^0=\frac{4!}{3!1!0!}x_1^3x_2=4x_1^3x_2$$

$$\bullet(3,0,1)\to\binom{4}{3,0,1}x_1^3x_2^0x_3^1=\frac{4!}{3!0!1!}x_1^3x_3=4x_1^3x_3$$

$$\bullet(4,0,0)\to\binom{4}{4,0,0}x_1^4x_2^0x_3^0=\frac{4!}{4!0!0!}x_1^4=x_1^4$$

**ជំហានទី៤៖** យកតួនីមួយៗបូកបញ្ចូលគ្នាដោយគោរពតាមរូបមន្តខាងលើ យើងបាន៖

$$X_3^4=x_1^4+x_2^4+x_3^4+12x_1^2x_2x_3+12x_1x_2^2x_3+12x_1x_2x_3^2+6x_1^2x_2^2+6x_1^2x_3^2+6x_2^2x_3^2$$
$$+4x_1^3x_2+4x_1^3x_3+4x_2^3x_1+4x_2^3x_3+4x_3^3x_1+4x_3^3x_2\,.$$

### ៤.៣.៣.ផលបូកនៃមេគុណពហុធា (Sum of multinomial coefficients)

យើងដឹងរួចមកហើយនូវរូបមន្តទូទៅនៃស្វ័យគុណទី $n$ របស់ពហុធា $(x_1+x_2+\cdots+x_m)$ ដែលតាង ដោយ $\boldsymbol{X_m^n}=\sum_{k_1+k_2+\cdots+k_m=n}\binom{n}{k_1,k_2,\cdots,k_m}\prod_{1\le\alpha\le m}x_\alpha^{k_\alpha}$ ប៉ុន្តែនៅពេលករណី $x_1=x_2=\cdots=x_m=1$ នោះរូបមន្តទៅជា $1_m^n=m^n=\sum_{k_1+k_2+\cdots+k_m=n}\binom{n}{k_1,k_2,\cdots,k_m}$ ពីព្រោះ $\prod_{1\le\alpha\le m}x_\alpha^{k_\alpha}=1,\forall 1\le\alpha\le m$ ។

*ដូច្នោះ* ផលបូកមេគុណពហុធាទាំងអស់គឺ $m^n$ ដែល $m$ ជាចំនួនគត់ និង $n$ ជាចំនួនស្វ័យគុណ។

- **ឧទាហរណ៍៩ ៖** តាមរូបមន្តទ្វេធា $(a+b)^n=\sum_{k=0}^{n}\binom{n}{k}a^{n-k}b^k$ នៅពេលដែល $a=b=1$ នោះរូបមន្ត ទ្វេធាទៅជា $2^n=\sum_{k=0}^{n}\binom{n}{k}$ ។
- **ឧទាហរណ៍១០ ៖** ចំពោះឧទាហរណ៍៨ នៃពហុធា $(x_1+x_2+x_3)^4$ ដោយយកតម្លៃ $x_1=x_2=x_3=1$ នោះ

  $1_3^4=3^4=1+1+1+12+12+12+6+6+6+4+4+4+4+4+4=81$ ឬ

  $3^4=\sum_{k_1+k_2+k_3=4}\binom{4}{k_1,k_2,k_3}$ ដែល $k_1+k_2+k_3=4;\forall k_1,k_2,k_3\le 4$ មាន១៥ចម្លើយ។

## ផ្នែក លំហាត់ និង ចម្លើយ

**១.**គេឱ្យសំណុំសកល $U=\{a,b,c,d,e,f,g\}$ ហើយ $A=\{a,b,c,d,e\}$ ;$B=\{a,c,e,g\}$ និង $C=\{b,e,f,g\}$ ។

ចូររក
1). $A\cap B$
2). $B\cap C$
3). $A\setminus B$
4). $(A\setminus B)^C$
5). $(A\Delta B)$
6). $(B\Delta C)$
7). $(A\cap B)\Delta(A\cap C)$
8). $A\times B$
9). $(A\cap B)\times(B\cap C)$
10). $(A\Delta B)\times(B\Delta C)$

**ចម្លើយ**

១). រក $A\cap B$

ដោយ $A\cap B=\{x:x\in A\wedge x\in B\}$
$=\{a,c,e\}$

២). $B\cap C=\{x:x\in B\wedge x\in C\}$
$=\{e,g\}$

៣). $A\setminus B=\{x:x\in A\wedge x\notin B\}$
$=\{b,d\}$

៤). $(A\setminus B)^C=\{a,c,e,f,g\}$

៥). $A\Delta B=\{x:x\in A\wedge x\notin B\}\vee\{x\in B\wedge x\notin A\}$
$=(A\setminus B)\cup(B\setminus A)$
$=\{b,d\}\cup\{g\}=\{b,d,g\}$

៦). $(B\Delta C)=\{x:(x\in B\wedge x\notin C)\vee(x\in C\wedge x\notin B)\}$
$=(B\setminus C)\cup(C\setminus B)$
$=\{a,c\}\cup\{b,f\}$
$=\{a,b,c,f\}$

៧). $(A\cap B)\Delta(A\cap C)=[(A\cap B)\setminus(A\cap C)]\cup[(A\cap C)\setminus(A\cap B)]$
$=\{a,c\}\cup\{g\}=\{a,c,g\}$

៨). $A\times B=\{(a,b):a\in A\wedge b\in B\}$

$=\{(a,a);(a,c);(a,e);(a,g);(b,a);(b,c);(b,e);(b,g);(c,a);$
$(c,c);(c,e);(c,g);(d,a);(d,c);(d,e);(d,g);(e,a);(e,c);$
$(e,e);(e,g)\}$

៩). $(A\cap B)\times(B\cap C)=\{(a,e);(a,g);(c,e);(c,g);(e,e);(e,g)\}$

១០). $(A\Delta B)\times(B\Delta C)=\{(b,g);(d,g);(g,g)\}$ ។

**២**. ក្រុមហ៊ុនអាកាសចរណ៍ មួយនៃព្រះរាជាណាចក្រកម្ពុជា បានបើកជើងហោះហើរ បីជើង ពីក្រុងភ្នំពេញទៅ ខេត្តសៀមរាប និង ពីសៀមរាបទៅជប៉ុន ប្រាំជើង ។
តើគេអាចធ្វើដំណើរបានប៉ុន្មាន របៀបពីទីក្រុងភ្នំពេញ ទៅប្រទេសជប៉ុន តាមជើងហោះហើរនេះ?

**ចម្លើយ**

រករបៀបនៃការធ្វើដំណើរពីទីក្រុងភ្នំពេញទៅ ប្រទេសជប៉ុន ៖

*របៀបទី ១*




តាមគោលការណ៍របាប់ ចំនួនរបៀបនៃការធ្វើដំណើរពីភ្នំពេញ ទៅប្រទេសជប៉ុន
មាន $3\times5=15$ របៀប

ដូចនេះ គេអាចធ្វើដំណើរពីភ្នំពេញទៅជប៉ុនបាន 15 របៀប។

*របៀបទី២*

តាង $A_i$ ជាការធ្វើដំណើរពីទីក្រុងភ្នំពេញទៅខេត្តសៀមរាប ដែល $i=1,2,3$

$B_j$ ជាការធ្វើដំណើរពីខេត្តសៀមរាបទៅប្រទេសជប៉ុន ដែល $j=1,2,3,4,5$

យើងបានដ្យាក្រាម ដូចខាងក្រោម ៖




តាមដ្យាក្រាមខាងលើ យើងឃើញថាចំនួនរបៀបនៃការធ្វើដំណើរពីទីក្រុងភ្នំពេញ ទៅប្រទេសជប៉ុន មាន 15 របៀប។

**៣.** ក្នុងការសាកសួរសិស្ស ២០០នាក់ គេបានឃើញថា សិស្ស ៧០នាក់រៀនភាសាបារាំង ៤០ នាក់ រៀនភាសាជប៉ុន ៧៥នាក់ រៀនភាសាអង់គ្លេស ១០នាក់ រៀនភាសាបារាំង និងជប៉ុន ៣០នាក់ រៀនភាសាបារាំង និង អង់គ្លេស ១៥នាក់ រៀនភាសាជប៉ុន និង អង់គ្លេស ហើយសិស្ស ៧០នាក់ មិនបានរៀនភាសាណាមួយសោះ ។

ក. តើសិស្សប៉ុន្មាននាក់បានរៀនពីរភាសា ?

ខ. តើសិស្សប៉ុន្មាននាក់បានរៀនភាសាអង់គ្លេស មិនរៀនភាសាជទៃ?

គ. តើសិស្សប៉ុន្មាននាក់រៀនភាសាអង់គ្លេស និង មិនរៀនភាសាបារាំង?

**ចម្លើយ**

តាង $E$ ជាសំណុំសិស្សរៀនភាសាអង់គ្លេស $n(E)=75$ នាក់

$F$ ជាសំណុំសិស្សរៀនភាសាបារាំង $n(F)=70$ នាក់

$J$ ជាសំណុំសិស្សរៀនភាសាជប៉ុន $n(J)=40$ នាក់




ដ្យាក្រាមវិន

តាមដ្យាក្រាមវិន $n(E\cap F\cap J)=0$ នាក់

$n(E\cap J)=15$ នាក់

$n(E\cap F)=30$ នាក់

$n(F\cap J)=10$ នាក់

ក. ចំនួនសិស្សរៀនពីរភាសា

ចំនួនសិស្សរៀនពីរភាសា = $n(E\cap J)+n(E\cap F)+n(F\cap J)=15+30+10=55$ នាក់

ដូចនេះ ចំនួនសិស្សរៀនពីរភាសា មាន 55 នាក់។

ខ. ចំនួនសិស្សរៀនភាសាអង់គ្លេស មិនរៀនភាសាជទៃទៀត

ចំនួនសិស្សរៀនតែភាសាអង់គ្លេស $=n(E)=n(E\cap F)-n(E\cap J)=75-30-15=30$ នាក់

ដូចនេះ ចំនួនសិស្សរៀនតែភាសាអង់គ្លេស មិនរៀនភាសាជទៃ មាន 30 នាក់

គ. ចំនួនសិស្សរៀនភាសាអង់គ្លេស មិនរៀនភាសាបារាំង ៖

សិស្សរៀនភាសាអង់គ្លេស មិនរៀនភាសាបារាំង $= n(E) - n(E \cap F) = 75 - 30 = 45$ នាក់

ដូចនេះ សិស្សរៀនភាសាអង់គ្លេស មិនរៀនភាសាបារាំង មាន 45 នាក់។

**៤.** តាមការសាកសួរពត៌មានពីប្រជាជនចំនួន ១០០នាក់ បានឱ្យដឹងថាមានប្រជាជនចំនួន ៥៨ នាក់ ចូលចិត្តអានទស្សនាវដ្ដីអង្គរធំ , ៥៦នាក់ ចូលចិត្តអានទស្សនាវដ្ដី ប្រជាប្រិយ និង២៦នាក់ ចូលចិត្តអានទស្សនាវដ្ដីអង្គរធំ និង ប្រជាប្រិយ ។

ក. តើមានប្រជាជនប៉ុន្មាននាក់ដែលចូលចិត្តអានទស្សនាវដ្ដីអង្គរធំមួយប៉ុណ្ណោះ ?

ខ. តើមានប្រជាជនប៉ុន្មាននាក់ដែលចូលចិត្តអានទស្សនាវដ្ដីប្រជាប្រិយមួយប៉ុណ្ណោះ ?

គ. តើមានប្រជាជនប៉ុន្មាននាក់ដែលចូលចិត្តអានទស្សនាវដ្ដីយ៉ាងតិចមួយ ?

ឃ. តើមានប្រជាជនប៉ុន្មាននាក់ដែលចូលចិត្តអានទស្សនាវដ្ដី ?

**ចម្លើយ**

តាង $U$ ជាសំណុំសកលនៃប្រជាជនទាំងអស់

$A$ ជាសំណុំនៃប្រជាជនដែលចូលចិត្តអានទស្សនាវដ្ដីអង្គរធំ

$B$ សំណុំនៃប្រជាជនដែលចូលចិត្តអានទស្សនាវដ្ដីប្រជាប្រិយ

គេបាន $n(U) = 100$ , $n(A) = 58$ , $n(B) = 56$ , $n(A \cap B) = 26$




ក. រកចំនួនប្រជាជនដែលចូលចិត្តអានតែទស្សនាវដ្ដីអង្គរធំ

យើងមាន $n(A \cap \overline{B}) = n(A) - n(A \cap B)$

$= 58 - 26 = 32$ នាក់

ខ. រកចំនួនប្រជាជនដែលចូលចិត្តអានតែទស្សនាវដ្ដីប្រជាប្រិយ

យើងមាន $n(\overline{A} \cap B) = n(B) - n(A \cap B)$

$= 56 - 26 = 30$ នាក់

គ. រកចំនួនប្រជាជនដែលចូលចិត្តអានទស្សនាវដ្ដីយ៉ាងតិចមួយ

$n(A \cup B) = n(A) + n(B) - n(A \cap B)$

$= 58 + 56 - 26 = 88$

ឃ. រកចំនួនប្រជាជនដែលមិនចូលចិត្តអានទស្សនាវដ្ដី

យើងមាន $n(U)=n(A\cup B)+n\left(\overline{A}\cap\overline{B}\right)$

$$\Rightarrow n\left(\overline{A}\cap\overline{B}\right)=n(U)-n(A\cup B)$$

$=100-88=12$ នាក់

**៥.** ក្នុងពិធីរៀបអាពាហ៍ពិពាហ៍មួយ កូនកំលោះក្រមុំ ៣គូចង់ថតរូបជាមួយគ្នា អង្គុយជាជួរលើកៅអី ៦ដោយឱ្យកូនកំលោះក្រមុំមួយគូៗត្រូវអង្គុយជាប់គ្នា ។

តើគេអាចអង្គុយថតរបៀបនេះបានប៉ុន្មានរបៀប ?

**ចម្លើយ**

រកចំនួនរបៀបដែលកូនកំលោះក្រមុំ អង្គុយជាប់ៗគ្នាថតរូប ៖

កៅអីមួយគូៗ គេអាចរៀបបាន ២ របៀបនោះកៅអី ៣គូ គេអាចរៀបបាន $2^3=8$ របៀប

ដោយកូនកំលោះក្រមុំទាំង ៣គូអង្គុយជាប់ៗគ្នា គេប្រើកៅអីបីគូ សម្រាប់អង្គុយ គឺ

$3!=3\times2\times1=6$ របៀប

តាមគោលការណ៍រាប់ចំនួនរបៀបដែលកូនកំលោះក្រមុំអង្គុយជាប់ៗគ្នាថតមាន $8\times6=48$ របៀប

ដូចនេះ កូនកំលោះក្រមុំអង្គុយជាប់គ្នាថតរូប បាន 48 របៀប ។

**៦.** គេតម្រៀបទៀនពណ៌ក្រហម ៣ដើម ទៀនពណ៌ស ២ដើម និង ទៀនពណ៌លឿង ២ដើម ។

តើគេអាចតម្រៀបទៀនទាំងនោះឱ្យឆ្លាស់ពណ៌គ្នាបានប៉ុន្មានរបៀប ?

**ចម្លើយ**

គេតម្រៀបទៀនចំនួន ៧ដើម ដែលក្នុងនោះមានទៀន ពណ៌ក្រហម ៣ដើម ទៀនពណ៌ស ២ ដើម និង ទៀនពណ៌លឿង ២ដើមគឺជាចម្លាស់បែងចែកបាន ។

ដូចនេះ ចំនួនរបៀបដែលអាចបែងចែកបានគឺ $\frac{7!}{3!2!2!}=210$ របៀប

**៧.** ចូរកំណត់ចម្លាស់រង់នៃមនុស្ស ១០នាក់ក្នុងករណីដែល ៖

*i.* លោក A&B នៅជិតគ្នា

*ii.* លោក A&B នៅទល់មុខគ្នា

**ចម្លើយ**

*i.* លោក A&B នៅជិតគ្នា

គេបាន ចម្លាស់នៃមនុស្ស ១០នាក់ ដោយដឹងថាលោក A&B នៅជាប់គ្នា នោះគឺជាចម្លាស់រង់នៃមនុស្ស 9 នាក់គឺ $(9-1)!=8!$ ហើយ ចម្លាស់លោក $A,B$ មាន 2 របៀបទៀត

ដូច្នេះ ចម្លាស់រង់ដែល លោក A&B នៅជិតគ្នា គឺ $2\times 8!=80640$ របៀប

*ii.* លោក $A\&B$ នៅទល់មុខគ្នា

ដោយ $A\&B$ នៅទល់មុខគ្នា នោះយើងអោយនឹង $A\&B$

នាំឱ្យ មនុស្សដែលនៅសល់គឺ 8

គេបាន ចម្លាស់គឺ 8!

**៨.** គេចង់បង្កើតគណៈកម្មាធិការ សហាគមន៍មួយដែលមាន សមាជិក ៥នាក់ ដោយជ្រើសរើសក្នុងចំណោមនិស្សិតគំរូ ៩នាក់ ។

តើគេអាចបង្កើតគណៈកម្មាធិការបែបនេះបានប៉ុន្មានរបៀប?

**ចម្លើយ**

រករបៀបបង្កើតគណៈកម្មាធិការនេះ

ដោយនិស្សិតទាំងអស់ ៩នាក់ យើងជ្រើសរើសយក ៥នាក់ គេបានរបៀបបង្កើតគណៈកម្មាធិការនេះ

គឺ $C(9,5)=\dfrac{9!}{(9-5)!5!}=\dfrac{9\times 8\times 7\times 6\times 5!}{5!\times 4\times 3\times 2\times 1}=126$ របៀប។

**៩.** និស្សិតគំរូមួយក្រុមមានប្រុស ៨នាក់និង ស្រី ៦នាក់ ។គេចង់បង្កើតគណៈកម្មាការសមាគមន៍និស្សិតមួយដែលមានសមាជិក ៧នាក់ ក្នុងនោះ ស្រី ៣នាក់ ដោយជ្រើសរើសចេញពីនិស្សិតគំរូទាំងនេះ ។ តើគេអាចបង្កើតគណៈកម្មាការនេះ បានប៉ុន្មានរបៀប ?

**ចម្លើយ**

រករបៀបបង្កើតគណៈកម្មាការនេះ

ដោយសមាជិកគណៈកម្មាការនេះមានស្រី ៣នាក់ និងត្រូវមានប្រុស ៤នាក់។ គេមាន $C(8,4)$ របៀបដើម្បីជ្រើសរើសនិស្សិត ប្រុស និង $C(6,3)$ របៀប ដើម្បីជ្រើសរើសនិស្សិតស្រី ។ គេបានចំនួនរបៀបបង្កើតគណៈកម្មាការនេះ គឺ $C(8,4)\times C(6,3)=\frac{8!}{4!\times 4!}\times\frac{6!}{3!\times 3!}=1400$ របៀប

**ដូចនេះ** របៀបបង្កើតគណៈកម្មាការនេះគឺ 1400 របៀប ។

**១០.**មនុស្សមួយក្រុមមានគ្នា 5នាក់ដែលត្រូវជាមិត្តិភក្តិនិងគ្នាមានឈ្មោះ ក ខ គ ឃ និង ង។ អ្នកទាំង 5រៀបគ្នាជាបន្ទាត់ត្រង់ដើម្បីថត។តើគេអាចមានប៉ុន្មានករណីដែលអាចឈរថតបើ៖

**ក.** គ្មានលក្ខខណ្ឌអ្វីទាំងអស់។

**ខ.** បុគ្គលដែលឈ្មោះ ក និង ខ ឈរនៅជិតគ្នា។

**គ.** បុគ្គលដែលឈ្មោះ ក និង ខ ឈរនៅចុងសងខាងបន្ទាត់។

**ចម្លើយ**

រកករណីដែលអាចឈរថតបើ៖

**ក.** គ្មានលក្ខខណ្ឌអ្វីទាំងអស់

| | | | | |
|---|---|---|---|---|
| ទី 1 | ទី 2 | ទី 3 | ទី 4 | ទី 5 |

ដោយប្រើគោលការណ៍ប្រមាណវិធីគុណ

- កន្លែងទី 1 ៖ មាន 5ជំរើស
- កន្លែងទី 2 ៖ មាន 4ជំរើស
- កន្លែងទី 3 ៖ មាន 3ជំរើស

- កន្លែងទី 4 ៖ មាន 2ជំរើស
- កន្លែងទី 5 ៖ មាន 1ជំរើស

នោះគេបានជំរើសសរុបគឺ $5\times4\times3\times2\times1=120$ជំរើស

**ខ.** បុគ្គលដែលឈ្មោះ ក និង ខ ឈរនៅជិតគ្នា

| | | | | |
|---|---|---|---|---|
| ក | ខ | | | |
| | | ទី 1 | ទី 2 | ទី 3 |

ដោយ ក និង ខ ឈរនៅជិតគ្នានោះយើងចាត់ទុកថាតែម្នាក់។ ដូចនេះយើងបាន 4កន្លែងសម្រាប់ថត។ ដោយប្រើគោលការណ៍ប្រមាណវិធីគុណ៖

- កន្លែងទី 1 ៖ មាន 4ជំរើស
- កន្លែងទី 2 ៖ មាន 3ជំរើស
- កន្លែងទី 1 ៖ មាន 2ជំរើស
- កន្លែងទី 2 ៖ មាន 1ជំរើស

នោះគេបានជំរើសសរុបគឺ $4\times3\times2\times1=24$ ជំរើស។ ប៉ុន្តែកន្លែងទី 1មាន2ជំរើសផ្សេងគ្នា ដូចនេះ ជំរើសសរុបគឺ $24\times2=48$ជំរើស

**គ.** បុគ្គលដែលឈ្មោះ ក និង ខ ឈរនៅចុងសងខាងបន្ទាត់

| | | | | |
|---|---|---|---|---|
| ក | | | | ខ |
| | ទី 1 | ទី 2 | ទី 3 | |

ដោយ ក និង ខ ឈរនៅចុងសងខាងបន្ទាត់នោះយើងនៅសល់ 3កន្លែងសម្រាប់ថត។ ដោយប្រើគោលការណ៍ប្រមាណវិធីគុណ៖

- កន្លែងទី 1 ៖ មាន 3ជំរើស
- កន្លែងទី 2 ៖ មាន 2ជំរើស
- កន្លែងទី 1 ៖ មាន 1ជំរើស

នោះគេបានជំរើសសរុប $3\times2\times1=6$ ជំរើស ។ប៉ុន្តែ កន្លែង ក និង ខ អាចផ្លាស់ប្តូរកន្លែងគ្នាបាន

**ដូចនេះ** ជំរើសសរុបគឺ $6\times2=12$ ជំរើស ។

**១១**. បង្ហាញថា សម្រាប់ចំនួនមិនអវិជ្ជមាន $m$ និងចំនួនគត់វិជ្ជមាន $n$ នោះយើងទទួលបានរូបមន្ត ពហុធាដែលមានផលបូក $m$ តួ នៅពេលដែលពន្លាតពហុធា $(x_1+x_2+...+x_n)^n$ គឺ

$$\sum_{k_1+k_2+...+k_m=n}\binom{n}{k_1,k_2,k_3,...,k_m}\prod_{1\le t\le m}X_t^{k_t} \text{ ដែល } \binom{n}{k_1,k_2,k_3,...,k_m}=\frac{n!}{k_1!k_2!...k_m!}$$

ចម្លើយ

យើងមាន $(x_1+x_2+...+x_m)^n=\sum_{k_1+k_2+...+k_m=n}\binom{n}{k_1,k_2,k_3,...,k_m}\prod_{1\le t\le m}X_t^{k_t} \qquad (i)$

- បើ $m=1$ នោះរូបមន្ត $(i)$ គឺ $x_1^n=\sum_{k_1=n}\binom{n}{k_1}\prod_{1\le t\le 1}x_t^t=x_1^n$ ពិត
- បើ $m=m$ នោះរូបមន្ត $(i)$ក៏ពិតដែរ
- បើ $m=m+1$ នោះយើងបាន

$$(x_1+x_2+...+x_m+x_{m+1})^n=\left[x_1+x_2+...+(x_m+x_{m+1})\right]^n$$

$$=\sum_{k_1+k_2+...+k_m+\lambda=n}\binom{n}{k_1,k_2,k_3,...,k_m,\lambda}x_1^{k_1}x_2^{k_2}...x_{m-1}^{k_{m-1}}(x_m+x_{m+1})^{\lambda}$$

ដែល $n=k_1+k_2+...+k_{m-1}+\lambda$

យើងមានទ្រឹស្តីបទទ្វេធា $(a+b)^n=\sum_{k=0}^{n}C_n^k a^{n-k}b^k$

ដោយ $\binom{n}{k_1,k_2}=\binom{n}{k_1}=\binom{n}{k_2}$ គ្រប់ $n=k_1+k_2$

ដូចនេះ $(x_1+x_2+...+x_m+x_{m+1})^n=\sum_{k_1+k_2+...+k_m+\lambda=n}\binom{n}{k_1,k_2,k_3,...,k_m,\lambda}x_1^{k_1}x_2^{k_2}\cdots x_{m-1}^{k_{m-1}}\times A$

ដែល $A=\sum_{k_m+k_{m+1}=\lambda}\binom{\lambda}{k_m,k_{m+1}}x_m^{k_m}x_{m+1}^{k_{m+1}}$ , $(\lambda=k_m+k_{m+1})$

$$=\sum_{k_1+k_2+...+k_{m-1}+k_m+k_{m+1}=n}\binom{n}{k_1,k_2,k_3,....,k_{m-1},k_m,k_{m+1}}x_1^{k_1}x_2^{k_2}...x_{m-1}^{k_{m-1}}x_m^{k_m}x_{m+1}^{k_{m+1}}$$

ពីព្រោះ $\binom{n}{k_1,k_2,...,k_{m-1},\lambda}\times\binom{\lambda}{k_m,k_{m+1}}=\frac{n!}{k_1!k_2!...k_{m-1}!\lambda!}\times\frac{\lambda!}{k_m!k_{m+1}!}$

$$=\frac{n!}{k_1!k_2!...k_{m-1}!k_m!k_{m+1}!}$$

$$=\binom{n}{k_1,k_2,...,k_m,k_{m+1}}$$

ដូច្នេះការស្រាយបញ្ជាក់គឺត្រឹមត្រូវ ។

**១២**. ប្រសិនបើ $x$ ជាចំនួនពិតនិង $k$ ជាចំនួនគត់មិនអវិជ្ជមាន នោះ

គេតាង $\binom{x}{k}=\frac{x(x-1)(x-2)...(x-k+1)}{k!}$ ។ ចូរគណនា $A=\frac{\binom{\frac{1}{2}}{2015}.4^{2015}}{C(4030,2015)}$

**ចម្លើយ**

តាមរូបមន្ត $C(2n,n)=\frac{2^n(2n-1)!}{n!}=\frac{2^n(2n-1)(2n-3)...3.1}{n!}$

នោះ $C(4030,2015)=\frac{2^{2015}(4030-1)(4030-3)...3.1}{2015!}=\frac{2^{2015}(4029)(4027)...3.1}{2015!}$

និង $\binom{\frac{1}{2}}{2015}=\frac{\frac{1}{2}\left(\frac{1}{2}-1\right)\left(\frac{1}{2}-2\right)...\left(\frac{1}{2}-2015+1\right)}{2015!}=\frac{\frac{1}{2}\left(-\frac{1}{2}\right)\left(-\frac{3}{2}\right)...\left(-\frac{4027}{2}\right)}{2015!}$

$$=\frac{\frac{1}{2}.\left(-\frac{1}{2}\right)^{2014}.1.3.5\ ...\ 4027}{2015!}=\frac{1.3.5\ ...\ 4027}{2^{2015}.2015!}$$

នាំឱ្យ $A=\frac{\binom{\frac{1}{2}}{2015}.4^{2015}}{C(4030,2015)}=\frac{1.3.5...4027.2^{4030}}{2^{2015}2015!}\times\frac{2015!}{2^{2015}.4029.4027...3.1}=\frac{1}{4029}$

ដូចនេះ $A=\frac{1}{4029}$

# ប្រូបាប

## ១. លំហសំណាក និង ព្រឹត្តិការណ៍

### ១.១ ពិសោធន៍ចៃដន្យ វិញ្ញាសា

- ពិសោធន៍ចៃដន្យ ជាពិសោធន៍មួយដែលធ្វើដោយមិនបានដឹងលទ្ធផលទុកមុន ។
- វិញ្ញាសា ជាពិសោធន៍មួយដែលគេកំណត់ធ្វើដោយជាក់លាក់ ក្នុងពិសោធន៍ចៃដន្យមួយ ។

**ឧទាហរណ៍** ៖ គេបោះកាក់មួយពីរដង ។

- ពិសោធន៍ចៃដន្យ គឺ សកម្មភាពបោះកាក់ ។
- វិញ្ញាសា គឺ ការបោះកាក់មួយពីរដង ។

### ១.២ លំហសំណាក

លំហសំណាក ឬសំណុំសំណាក ជាសំណុំលទ្ធផលទាំងអស់ដែលអាចកើតឡើងក្នុងវិញ្ញាសាមួយ នៃពិសោធន៍ចៃដន្យ ។

**ឧទាហរណ៍** ៖ គ្រាប់ឡុកឡាក់មួយត្រូវបានបោះចំនួនមួយលើក ។

សំណុំលទ្ធផលដែលអាចកើតឡើងមាន $\{1,2,3,4,5,6\}$ គេបាន លំហសំណាក $S=\{1,2,3,4,5,6\}$ ។

**លំហាត់គំរូទី១** ៖ ក្នុងថង់មួយមានឃ្លី ៨គ្រាប់ ចុះពីលេខ ១ដល់ លេខ៨ ។គេចាប់យកឃ្លីមួយដោយចៃដន្យ ។

ក. តើសកម្មភាពមួយណាជាពិសោធន៍ចៃដន្យ មួយណាជាវិញ្ញាសា ?

ខ. ចូរសរសេរលំហសំណាក ។

**ចម្លើយ**

ក. - ពិសោធន៍ចៃដន្យ គឺ សកម្មភាពចាប់ពីឃ្លីក្នុងថង់ ។

- វិញ្ញាសា គឺ ការចាប់យកឃ្លីមួយពីក្នុងថង់ ។

ខ. លំហសំណាក

ករណីដែលអាចកើតឡើងមានចាប់បានលេខ $1,2,3,4,5,6,7,8$ ។

ដូចនេះ $S=\{1,2,3,4,5,6,7,8\}$ ។

**១.៣ ព្រឹត្តការណ៍**

ក. *ព្រឹត្តការណ៍*

**និយមន័យ ៖** ព្រឹត្តការណ៍ ជាសំណុំរងនៃលំហសំណាក ឬ ជាសំណុំលទ្ធផលដែលកើតឡើងស្របតាមបំណងប្រាថ្នាចង់បាន ។

**ឧទាហរណ៍ ៖** កាក់មួយត្រូវបានបោះ ២ដង ។ តើមានប៉ុន្មានករណីដែលខាងរូប $H$ កើតឡើងមួយគត់?

លទ្ធផលដែលស្របតាមបំណងប្រាថ្នា គឺ មុខ $H$ មានតែមួយគត់ មាន $(HT);(TH)$ ។

ដូចនេះ មាន ២ករណីគឺ $(HT)$ និង $(TH)$ ។

ខ.*ព្រឹត្តិការណ៍សមាស*

គេមានព្រឹត្តិការណ៍ $A$ និង $B$ ក្នុងលំហសំណាក $S$ ។

គេបាន ៖

១). **ព្រឹត្តិការណ៍ផលគុណនៃ** $A$ **និង** $B$ ($A\cap B$) ជាព្រឹត្តិការណ៍កើតឡើងនៃគ្រប់លទ្ធផល ដែលលទ្ធផលនៅក្នុង $A$ ផង និងក្នុង $B$ ផង ។

២). **ព្រឹត្តិការណ៍ផលបូកនៃ** $A$ **និង** $B$ ($A\cup B$) ជាព្រឹត្តិការណ៍កើតឡើងនៃគ្រប់លទ្ធផលដែលជាលទ្ធផលនៅក្នុង $A$ ឬ $B$ ឬ ទាំងពីរព្រឹត្តិការណ៍ ។

៣). **ព្រឹត្តិការណ៍បំពេញគ្នា ឬព្រឹត្តិកាណ៍ផ្ទុយគ្នា** បើ $A'$ ជាព្រឹត្តិការណ៍បំពេញនៃព្រឹត្តិការណ៍ $A$ នោះ $A'$ ជាព្រឹត្តិការណ៍នៃគ្រប់លទ្ធផលនៅក្នុងលំហសំណាក $S$ ដែលមិននៅក្នុង $A$ ។

៤). ព្រឹត្តិការណ៍មិនចុះសំរុងគ្នា បើព្រឹត្តិការណ៍ $A$ និង $B$ គ្មានធាតុរួម នោះព្រឹត្តិការណ៍ $A$ និង ព្រឹត្តិការណ៍ $B$ ជាព្រឹត្តិការណ៍មិនចុះសំរុងគ្នា កំណត់សរសេរដោយ $A\cap B=\varnothing$ ។

**លំហាត់គំរូទី២ ៖** គេបោះគ្រាប់ឡុកឡាក់មួយគ្រាប់ ។ តាង $A$ ជាព្រឹត្តិការណ៍ដែលគ្រាប់ឡុកឡាក់ចេញលេខគូ និង $B$ ជាព្រឹត្តិការណ៍ដែលឡុកឡាក់ចេញលេខ ជាពហុគុណនៃ ៣ និង $C$ ជាព្រឹត្តិការណ៍ដែលឡុកឡាក់ចេញលេខតូចជាង ឬស្មើនឹង ២ ។

ចូរកំណត់ ៖

ក. លំហសំណាក និង ព្រឹត្តិការណ៍ $A, B, C$

ខ. ព្រឹត្តិការណ៍ផលគុណ $A\cap B$ ; $A\cap C$ ; $B\cap C$

គ. ព្រឹត្តិការណ៍ផលបូក $A\cup B$ ; $B\cup C$

ឃ. ព្រឹត្តិការណ៍បំពេញនៃព្រឹត្តិការណ៍ $A, B, C$

ង. តើព្រឹត្តិការណ៍ណាជាព្រឹត្តិការណ៍មិនចុះសំរុងគ្នា

**ចម្លើយ**

ក. លំហសំណាក និង ព្រឹត្តិការណ៍ $A, B, C$

គេបោះគ្រាប់ឡុកឡាក់មួយគ្រាប់ លទ្ធផលអាចកើតឡើងមានលេខ $1, 2, 3, 4, 5, 6$ ។

- លំហសំណាក $S = \{1, 2, 3, 4, 5, 6\}$
- ព្រឹត្តិការណ៍ $A = \{2, 4, 6\}$
- ព្រឹត្តិការណ៍ $B = \{3, 6\}$
- ព្រឹត្តិការណ៍ $C = \{1, 2\}$

ខ. ព្រឹត្តិការណ៍ផលគុណ

$A\cap B = \{6\}$

$A\cap C = \{2\}$

$B\cap C = \varnothing$

គ. ព្រឹត្តិការណ៍ផលបូក

$A\cup B = \{2, 3, 4, 6\}$

$B\cup C = \{1, 2, 3, 6\}$

ឃ. ព្រឹត្តិការណ៍បំពេញនៃព្រឹត្តិការណ៍ $A, B, C$

$\overline{A} = \{1, 3, 5\}$

$\overline{B} = \{1, 2, 4, 5\}$

$\overline{C} = \{3, 4, 5, 6\}$

ង. ព្រឹត្តិការណ៍មិនចុះសំរុងគ្នា

ដោយ $B\cap C = \varnothing$

ដូចនេះ ព្រឹត្តិការណ៍ $B$ និង $C$ មិនចុះសំរុងគ្នា ។

## ២. និយមន័យប្រូបាប

**១.និយមន័យ** ប្រូបាបនៃព្រឹត្តិការណ៍ $A$ តាងដោយ $P(A)$ គឺជាផលចែករវាងចំនួនករណីស្របតាមព្រឹត្តិការណ៍ $A$ និងព្រឹត្តិការណ៍ដែលអាចទាំងអស់នៅក្នុងវិញ្ញាសាមួយ ។

$$P(A)=\frac{\text{ចំនួនករណីស្រប}}{\text{ចំនួនករណីអាច}}=\frac{n(\mathrm{A})}{n(\mathrm{S})}$$

**២. លក្ខណ:**

ក. ចំពោះរាល់ព្រឹត្តិការណ៍ $A;\ 0\le P(A)\le 1$

ខ. ប្រូបាបនៃព្រឹត្តិការណ៍ដែលមិនអាចកើតមាន $P(\varnothing)=0$

គ. ប្រូបាបនៃព្រឹត្តិការណ៍ទាំងអស់ $P(S)=1$

**ឧទាហរណ៍៖** គេបោះឡុកឡាក់មួយគ្រាប់ ។ រកប្រូបាប ៖

ក. ឡុកឡាក់ចេញលេខគូ

ខ. ឡុកឡាក់ចេញលេខធំជាង ៦ ។

**ចម្លើយ**

រកប្រូបាប

ក). ឡុកឡាក់ចេញលេខគូ

ករណីអាចបោះឡុកឡាក់មួយគ្រាប់ គឺ $S=\{1,2,3,4,5,6\}$ ។

គេបាន $n(S)=6$

តាង $A$ ជាព្រឹត្តិការណ៍ឡុកឡាក់ចេញលេខគូ

គេបាន $A=\{2,4,6\}$ ចំនួនករណីស្រប $n(A)=3$

នាំឱ្យ $P(A)=\dfrac{n(A)}{n(S)}$

$$P(A)=\frac{3}{6}=0.5$$

ដូចនេះ $P(A)=0.5$

ខ). ឡុកឡាក់ចេញលេខធំជាង៦

តាង $B$ ព្រឹត្តិការណ៍ឡុកឡាក់ចេញលេខធំជាង ៦

ដោយព្រឹត្តិការណ៍ឡុកឡាក់ចេញលេខធំជាង ៦ ជាករណីមិនអាចកើតមាន គេបាន $n(B)=0$

នាំឱ្យ $P(A)=\dfrac{n(B)}{n(S)}=\dfrac{0}{6}=0$

ដូចនេះ $P(B)=0$ ។

៣. ការគណនាប្រូបាបនៃ $A\cup B$

ក). បើ $A$ និង $B$ ជាព្រឹត្តិការណ៍ពីរនៃវិញ្ញាសាតែមួយនោះ

គេបាន $\boxed{P(A\cup B)=P(A)+P(B)-P(A\cap B)}$

ខ). បើ $A$ និង $B$ ជាព្រឹត្តិការណ៍មិនចុះសំរុងគ្នានោះ

គេបាន $\boxed{P(A\cup B)=P(A)+P(B)}$

គ). បើ $A$ ជាព្រឹត្តិការណ៍នៃវិញ្ញាសាមួយហើយ $A'$ ជាព្រឹត្តិការណ៍ផ្ទុយពី $A$ នោះ

គេបាន $\boxed{P(A)+P(A')=1}$

**ឧទាហរណ៍៖** គេហូតបៀមួយសន្លឹកចេញពីក្នុងបៀមួយហ៊ូដែលមាន ៥២សន្លឹកដោយចៃដន្យ ។ រកប្រូបាប ដើម្បីឱ្យបៀដែលគេហូតនោះជាសន្លឹកអាត់ឬ សន្លឹកពណ៌ខ្មៅ ។

**ចម្លើយ**

រកប្រូបាបដើម្បីឱ្យបៀដែលគេហូតនោះជាសន្លឹក អាត់ ឬ សន្លឹកពណ៌ខ្មៅ

តាង $A$ ព្រឹត្តិការណ៍ហូតបានបៀសន្លឹកអាត់

តាង $B$ ព្រឹត្តិការណ៍ ចុះសំរុងគ្នាព្រោះ

$A\cap B=\{$ ជាសន្លឹកអាត់ពណ៌ខ្មៅ $\}$

$A\cup B=\{$ ជាសន្លឹកអាត់ឬ សន្លឹកពណ៌ខ្មៅ $\}$

គេបាន $P(A)=\frac{4}{52}$ ; $P(B)=\frac{26}{52}$ ; $P(A\cap B)=\frac{2}{52}$

នោះ $P(A\cup B)=P(A)+P(B)-P(A\cap B)$

$$=\frac{4}{52}+\frac{26}{52}-\frac{2}{52}=\frac{7}{13}$$

ដូចនេះ $P(A\cup B)=\frac{7}{13}$ ។

## ៣. ប្រូបាបមានលក្ខខណ្ឌ (Conditional Probability)

**និយមន័យ** ៖ ប្រូបាបនៃព្រឹត្តិការណ៍ $B$ ដែលនឹងកើតឡើងកាលណា ព្រឹត្តិការណ៍ $A$ បានកើតឡើងហើយ ហៅថា ប្រូបាប មានលក្ខខណ្ឌ ហើយតាងដោយ $P(B/A)$ ។

ចំពោះគ្រប់ព្រឹត្តិការណ៍ $A$ និង $B$ ដែល $P(A)\neq 0$ គេបាន $\boldsymbol{P(\mathrm{B}/A)=\frac{P(A\cap B)}{P(A)}}$ ។

សម្គាល់ ៖

១. $\boldsymbol{P(A/B)=\frac{P(A\cap B)}{P(B)}}$ ; $\boldsymbol{P(B)}\neq 0$

២. $\boldsymbol{P(A\cap B)=P(A)\times P(B/A)=P(B)\times P(A/B)}$

**ឧទាហរណ៍៖** តាមការស្ទាបស្ទង់ពីភាពគាប់ចិត្ត និង ការងាររបស់ខ្លួនទៅលើមនុស្សមួយក្រុមមានគ្នា ២០០ នាក់អោយទិន្នន័យដូចខាងក្រោម ៖

| | គាប់ចិត្ត | មិនគាប់ចិត្ត | សរុប |
|---|---|---|---|
| គ្រូបង្រៀន | ៥០ | ៧៥ | ១២៥ |
| មេធាវី | ៤០ | ៣៥ | ៧៥ |
| សរុប | ៩០ | ១១០ | ២០០ |

បើមនុស្សម្នាក់ត្រូវបានគេជ្រើសរើសពីក្រុមមនុស្សនេះ ដោយចៃដន្យ ។ បើកាលណាមនុស្សដែលជ្រើសរើសនោះជាគ្រូបង្រៀន , រកប្រូបាបដែលគាត់ជាអ្នកគាប់ចិត្ត នឹងការងាររបស់ខ្លួន ។

**ចម្លើយ**

តាង $A$ ជាព្រឹត្តិការណ៍ដែមនុស្សជ្រើសរើសបានមកជា អ្នកគាប់ចិត្ត

$B$ ជាព្រឹត្តិការណ៍ដែមនុស្សជ្រើសរើសបានមកជាគ្រូបង្រៀន

គេបាន $P(A/B)=\frac{P(A\cap B)}{P(B)}$

តាមតារាង យើងឃើញថា $P(A\cap B)=\frac{50}{200}=0.25$ និង $P(B)=\frac{125}{200}=0.625$

ដូចនេះ $P(A/B)=\frac{0.25}{0.625}=0.4$

## ៤. ព្រឹត្តិការណ៍មិនទាក់ទងគ្នា (Independent Events)

**និយមន័យ៖** $A$ និង $B$ ជាព្រឹត្តិការណ៍ដែលមានប្រូបាបមិនសូន្យ ។

១. គេថាព្រឹត្តិការណ៍ $A$ និង $B$ ជាព្រឹត្តិការណ៍មិនទាក់ទងគ្នា កាលណាព្រឹត្តិការណ៍ទាំងពីរផ្ទៀងផ្ទាត់លក្ខខណ្ឌណាមួយខាងក្រោម ៖

- $\boldsymbol{P(A\cap B)=P(A).P(B)}$
- $\boldsymbol{P(A/B)=P(A)}$
- $\boldsymbol{P(B/\mathrm{A})=P(B)}$

២. គេថាព្រឹត្តិការណ៍ $A$ និង $B$ ជាព្រឹត្តិការណ៍ទាក់ទងគ្នា កាលណា $\boldsymbol{P(A\cap B)\neq P(A).P(B)}$

**ជាទូទៅ ៖** *បើព្រឹត្តិការណ៍ $A_1,A_2,\ldots,A_n$ អាចកើតឡើង ។ បើ $A_1,A_2,\ldots,A_n$ ជាព្រឹត្តិការណ៍មិនទាក់ទងគ្នា នោះគេបាន ៖* $\boldsymbol{P(A_1\cap A_2\cap\ldots\cap A_n)=P(A_1).P(A_2).\ldots.\mathrm{P}(A_n)}$ ។

**ឧទាហរណ៍១៖** ថង់មួយមានប៊ូលស ៤ចុះលេខ $1,1,2$ និង $3$ និង ប៊ូលខ្មៅ ៦ចុះលេខ $1,1,1,2,3$ និង $4$ ។ គេចាប់យកប៊ូលមួយពីក្នុងថង់ដោយចៃដន្យ ។

តាងព្រឹត្តិការណ៍ $A$ : ប៊ូលយកចេញពណ៌ស

$B$ : ប៊ូលយកចេញមានលេខ ១

$C$ : ប៊ូលយកចេញមានលេខ ៤

យើងឃើញថាប៊ូលទាំងអស់មាន១០ ក្នុងនោះមានប៊ូលស ចំនួន៤ ហើយប៊ូលចុះលេខ 1 មានចំនួន៥ និង ប៊ូលពណ៌សចុះលេខ 1 មាន ២ ។

គេបាន $P(A)=\frac{4}{10}$ , $P(B)=\frac{5}{10}$ និង $P(A\cap B)=\frac{2}{10}$

ដោយ $P(A).P(B)=\frac{4}{10}\times\frac{5}{10}=\frac{20}{100}=\frac{2}{10}=P(A\cap B)$

បើ $P(A\cap B)=P(A).P(B)$ នោះគេថាព្រឹត្តិការណ៍ $A$ និង $B$ ព្រឹត្តិការណ៍មិនទាក់ទងគ្នា ។

បើ $A$ និង $B$ ព្រឹត្តិការណ៍មិនទាក់ទងគ្នានោះគេបាន ៖

$$P(A/B)=\frac{P(A\cap B)}{P(B)}=\frac{P(A)\times P(B)}{P(B)}=P(A)$$

$$P(B/A)=\frac{P(A\cap B)}{P(A)}=\frac{P(A)\times P(B)}{P(A)}=P(B)$$

យើងឃើញថា $P(C)=\frac{1}{10}$ និង $P(A\cap C)=0$ (ព្រោះ $A\cap C=\varnothing$ )

ដោយ $P(A)\times P(C)=\frac{4}{10}\times\frac{1}{10}=\frac{1}{25}\neq P(A\cap C)$ គេថាព្រឹត្តិការណ៍ $A$ និង $C$ ជាព្រឹត្តិការណ៍ទាក់ទងគ្នា។

**ឧទាហរណ៍២៖** គេដកបៀ៣សន្លឹកបន្តបន្ទាប់គ្នា ដោយមិនដាក់ទៅវិញពីបៀមួយហ៊្វ ៥២សន្លឹក ។ រកប្រូបាប ដែលព្រឹត្តិការណ៍ $A_1\cap A_2\cap A_3$ កើតឡើងដែល $A_1$ ជាព្រឹត្តិការណ៍ដែលសន្លឹកទី១ ជាអាត់ពណ៌ក្រហម $A_2$ សន្លឹកទី២ជាសន្លឹក ១០ ឬ កម្លោះ និង $A_3$ សន្លឹកទី៣ ធំជាង ៣និង តូចជាង៧។

**ចម្លើយ**

យើងកំណត់ព្រឹត្តិការណ៍

- $A_1$ អាត់ពណ៌ក្រហម $P(A_1)=\frac{2}{52}$
- $A_2$ សន្លឹក ១០ឬ កម្លោះ $P(A_2)=\frac{8}{51}$
- $A_3$ សន្លឹកធំជាង៣ ប៉ុន្តែតូចជាង ៧ $P(A_3)=\frac{12}{50}$

គេបាន $P(A_1\cap A_2\cap A_3)=P(A_1).P(A_2).P(A_3)$

$$=\frac{2}{52}\times\frac{8}{51}\times\frac{12}{50}=\frac{8}{5525}$$

## ៥. ទ្រឹស្ដីបទ បាយេស ( *Bayes's Theorem* )

១. ទ្រឹស្ដីបទប្រូបាបសរុប (***The theorem of total Probability***)

ការបែងចែកលំហាសំណាក ជាការជ្រើសរើសនៃព្រឹត្តិការណ៍ $A_1, A_2, \ldots, A_n$ គឺនិយាយបានថាជាការបែងចែកនៃលំហាសំណាក $S$ ប្រសិនបើ ៖

$i.\ A_1 \cup A_2 \cup \ldots \cup A_n = S$

$ii.\ A_i \cap A_j = \varnothing$ គ្រប់ $i, j$

$iii. A_i \neq \varnothing \ ,\forall i$ ដែល $1 \leq i \leq n$

*គំនិតសំខាន់គឺការបែងចែកអ្វីមួយជាការជ្រើសរើសមិនមែនសំណុំទទេ ហើយមិនមែនសំណុំរងធំដដែលៗ នៃលំហាសំណាក ដែលជាការប្រជុំនៃលំហាសំណាកខ្លួនវា* ។ និយមន័យ គឺបង្ហាញដ្យាក្រាមខាងក្រោម ៖




បើ B ព្រឹត្តិការណ៍ដែលកើតព្រមគ្នា ជាមួយលំហាសំណាក $S$ នោះយើងអាចបញ្ជាក់ B ជាប្រជុំនៃសំណុំរង ពោលគឺ ៖ $B = (B \cap A_1) \cup (B \cap A_2) \cup (B \cap A_3) \cup \ldots \cup (B \cap A_n)$ ។

និយមន័យនេះគឺបង្ហាញដោយដ្យាក្រាមខាងក្រោម ដែលព្រឹត្តិការណ៍ B មួយក្នុង $S$ គឺតំណាងដោយតំបន់ពណ៌ក្រហម ៖



ព្រឹត្តិការណ៍ដែលនៅក្នុងវង់ក្រចក $(B\cap A_1),(B\cap A_2),\ldots,(B\cap A_n)$ ជាព្រឹត្តិការណ៍មិនចុះសំរុងគ្នាទៅវិញទៅមក នោះយើងបាន ៖

$\boldsymbol{P(B\cap A_i)=P(B/A_i)P(A_i)}$ , $\forall \boldsymbol{i}:1\le \boldsymbol{i}\le \boldsymbol{n}$

ដូច្នេះ ប្រូបាប $\boldsymbol{P(B)=P(B/A_1)P(A_1)+P(B/A_2)P(A_2)+\ldots+P(B/A_n)P(A_n)}$

$$=\sum_{i=1}^{n}\boldsymbol{P(B/A_i)P(A_i)}$$

ទាំងនេះជាប្រូបាបនៃទ្រឹស្តីប្រូបាបសរុប ។

## ២. ទ្រឹស្តីបទបាយ៉េស

ទ្រឹស្តីបទបាយ៉េសនេះ ត្រូវបានដាក់ប្រើប្រាស់ជាសាធារណៈនៅឆ្នាំ ១៧៦៤ ដោយលោកជាអាចារ្យខាងសាសនាប្រូតេស្តង់ និង ជាគណិតវិទូជនជាតិ អង់គ្លេស ។ ទ្រឹស្តីបទនេះចាប់ផ្តើមទៅលើការពិចារណា នៃប្រូបាបមានលក្ខខណ្ឌមួយគឺ ៖ $\boldsymbol{P(A/B)=\dfrac{P(A\cap B)}{P(B)}=\dfrac{P(A\cap B)}{\sum_{i=1}^{n}P(B/A_i)P(A_i)}}$

នៅក្នុងការប្រើទ្រឹស្តីបទប្រូបាបសរុបខាងលើ ប៉ុន្តែឥឡូវយើងបំបែក $P(A\cap B)=P(B/A)\times P(A)$ ដូចនេះ $P(A/B)=\dfrac{P(B/A).P(A)}{\sum_{i=1}^{n}P(B/A_i).P(A_i)}$ គឺពិតគ្រប់ព្រឹត្តិការណ៍ $A$ និង ជំនួស $A$ ដោយ $A_i$ ផងដែរ ដែលបានមកនេះហៅថា ទ្រឹស្តីបទបាយ៉េស គឺ $\boldsymbol{P(A_i/B)=\dfrac{P(B/A_i)P(A_i)}{\sum_{i=1}^{n}P(B/A_i)P(A_i)}}$

- ករណីពិសេសនៃព្រឹត្តិការណ៍បាយ៉េស ៖

ក្នុងរូបមន្តនេះគេកំណត់ថា ក្នុងលំហសំណាកគឺបែងចែកព្រឹត្តិការណ៍ $A$ និងព្រឹត្តិការណ៍បំពេញនៃ $A$ និង $A'$ នោះរូបមន្តបាយ៉េសគឺ $P(A/B)=\dfrac{P(B/A).P(A)}{P(B/A).P(A)+P(B/A').P(A')}$

**លំហាត់គំរូទី១** ៖ នៅក្នុងតំបន់មួយមានរោងចក្រជាច្រើន តែមានតែ ៣រោងចក្រប៉ុណ្ណោះផលិតមី ។ រោចក្រទី១ ផលិតបាន ៣០% រោងចក្រទី២ ផលិតបាន ២៥% និងរោងចក្រទី៣ ផលិតបាន ៤៥%។ រោងចក្រទាំងបីផលិតបាននៃផលិតផលមីសរុប ដែលបានស្តុកក្នុងរោងឃ្លាំងមួយ ។ ដោយអត្រាមីខូចគុណភាព របស់រោងចក្រនីមួយៗរៀងគ្នា ១% , ២% , ១.៥% ។ កម្មកររោងចក្រយកមីមួយកញ្ចប់ពីក្នុងឃ្លាំង ។

ក). រកប្រូបាប ដើម្បីឱ្យគាត់យកបានមីដែលខូចគុណភាព ។

ខ). ឧបមាថា គាត់យកបានមីខូចគុណភាព ។គណនាប្រូបាប ដើម្បីឱ្យមីនេះជាផលិតផលរបស់ រោងចក្រទី៣ ។

**ចម្លើយ**

យើងតាងព្រឹត្តិការណ៍ដូចខាងក្រោម ៖

$A_1$ ជាព្រឹត្តិការណ៍យកបានផលិតផលរបស់រោងចក្រទី១

$A_2$ ជាព្រឹត្តិការណ៍យកបានផលិតផលរបស់រោងចក្រទី២

$A_3$ ជាព្រឹត្តិការណ៍យកបានផលិតផលរបស់រោងចក្រទី៣

$B$ ជាព្រឹត្តិការណ៍យកបានផលិតផលខូចគុណភាព

ក). រកប្រូបាបដើម្បីឱ្យគាត់យកបានមីខូចគុណភាព

តាមរូបមន្តប្រូបាបសរុប : $P(B)=P(B/A_1).P(A_1)+P(B/A_2).P(A_2)+P(B/A_3).P(A_3)$

ដោយ $P(A_1)=30\%=0.3$ , $P(A_2)=25\%=0.25$ , $P(A_3)=45\%=0.45$

; $P(B/A_1)=1\%=0.01$ , $P(B/A_2)=2\%=0.02$ , $P(B/A_3)=1.5\%=0.015$

នោះ $P(B)=0.3\times0.01+0.25\times0.02+0.45\times0.015=0.01475$ ឬ $P(B)=1.475\%$

**ដូចនេះ** $P(B)=1.475\%$

ខ). រកប្រូបាបដើម្បីឱ្យផលិតផលខូចនេះជារបស់រោងចក្រទី៣

តាមរូបមន្ត Bayes

គេបាន $P(A_3/B)=\dfrac{P(B/A_3).P(A_3)}{P(B)}$

$$=\frac{0.015\times0.45}{0.0175}=0.4576=45.76\%$$

**ដូចនេះ** $P(A_3/B)=45.76\%$

លំហាត់គំរូទី២ ៖ ក្រុមហ៊ុនកុំព្យូទ័រ Reasey ទិញ software Microsoft word 2016 ពីក្រុមហ៊ុនផ្គត់ផ្គង់បី គឺ ក្រុមហ៊ុន Microsoft , Hall Electronic , និង Schuller sales ។ ក្រុមហ៊ុនទិញ software ៦០% ពីក្រុមហ៊ុន Microsoft , ៣០% ពីក្រុមហ៊ុន Hall Electronic និង ១០% ពីក្រុមហ៊ុន Schuller sales ។ ក្រុមហ៊ុនបានដឹងថា ២.៥% នៃSoftware ទិញពី Microsoft គឺខូច , ៨% នៃ Software ទិញពី Hall Electronic គឺខូច និង៥%នៃ Software ទិញពី Schuller salesគឺខូច ។ពេលគេដឹក software មកដល់ក្រុមហ៊ុន Reasey គឺប្រធានក្រុមហ៊ុនមានឱ្យអ្នកបច្ចេកទេសមកពិនិត្យមើល ។ ចូររកប្រូបាបដែល software ខូចនោះផលិតដោយក្រុមហ៊ុន Microsoft ។

ចម្លើយ

តាង $A_1$ ជាព្រឹត្តិការណ៍ Software ទិញពីក្រុមហ៊ុន Microsoft

$A_2$ ជាព្រឹត្តិការណ៍ Software ទិញពីក្រុមហ៊ុន Hall Electronic

$A_3$ ជាព្រឹត្តិការណ៍ Software ទិញពីក្រុមហ៊ុន Schuller Sales

$B$ ជាព្រឹត្តិការណ៍ Software ខូច

តាមសម្មតិកម្ម យើងបាន

$P(A_1)=60\%=0.6$ , $P(A_2)=30\%=0.3$ , $\mathrm{P}(A_3)=10\%=0.1$ និង $P(B/A_1)=2.5\%=0.025$ , $P(B/A_2)=8\%=0.08$ , $P(B/A_3)=5\%=0.05$ នោះប្រូបាប ដែល Software ខូចនោះផលិតដោយក្រុមហ៊ុន Microsoft គឺ

$$P(A_1/B)=\frac{P(B/A_1).P(A_1)}{P(B/A_1).P(A_1)+P(B/A_2).P(A_2)+P(B/A_3).P(A_3)}$$

$$=\frac{0.6\times0.025}{0.6\times0.025+0.3\times0.08+0.1\times0.05}=0.3409$$

ដូចនេះ $P(A_1/B)=34.09\%$

**ដោយសារតែជំពូកនេះ និងជំពូកបន្ទាប់មានទំនាក់ទំនងគ្នា ដូច្នេះហើយ យើងខ្ញុំបានយកលំហាត់ទាំងពីរជំពូកទៅរួមបញ្ចូលគ្នាៗ សូមមើលលំហាត់នូវជំពូកបន្ទាប់ !**

# ចំណែងចែកប្រូបាប

## ១.អថេរចៃដន្យ និងចំណែងចែកប្រូបាប

### ១.១ អថេរចៃដន្យ (Random Variables)

**អថេរចៃដន្យ**គឺជាតំលៃលេខ តាងអោយលទ្ធផលនៃការពិសោធន៍ ។ គេតាងអថេរចៃដន្យដោយអក្សរធំ $X$ ហើយតម្លៃរបស់វាដោយអក្សរតូច $x$ ប្រូបាបរបស់វា តាងដោយ $P\{X=x\}$ រឺ $P(X=x)$ ដែល $P(X=x)>0$ ចំពោះគ្រប់តម្លៃ $x$ ហើយ $\sum_{\forall x} P(X=x)=1$ ។

**ឧទាហរណ៍១៖** ចូរពិនិត្យការពិសោធន៍ចៃដន្យមួយ ដែលក្នុងនោះកាក់មួយត្រូវបានគេបោះបីដង ។ យក $X$ ជាចំនួនមុខកាក់ដែលចេញ (គឺ $X$ ជាអថេរចៃដន្យតាងចំនួនមុខដែលកាក់ចេញ)

$H$ តាងអោយផ្នែកខាងមុខ *(Head)* និង $T$ តាងអោយផ្នែកខាងខ្នង (*Tail*)

គេបានលំហសំណាកនៃការពិសោធន៍នេះគឺ $TTT, TTH, THT, HTT, HHT, HTH, THH, HHH$ ។

ដូចនេះតម្លៃ $X$ (ចំនួនមុខ $H$ ដែលចេញ ) គឺ $X=0,1,2,3$ ។ តាមនិយមន័យយើងឃើញថា $X$ តាងអោយតម្លៃនៃលទ្ធផលនៃការពិសោធន៍ចៃដន្យ ដោយកំណត់យកតម្លៃគត់ ដូចនេះវាជាអថេរចៃដន្យ**ដាច់** ហើយក្រៅពីនេះ វាជាអថេរចៃដន្យ **ជាប់** ។

**ឧទាហរណ៍ ៖** កម្ពស់សិស្ស អាយុកាលប្រើប្រាស់របស់អំពូលភ្លើង គឺជា**អថេរចៃដន្យជាប់ ។**

### ១.២. ចំណែងចែកប្រូបាបនៃអថេរចៃដន្យដាច់

* ចំណែងចែកប្រូបាបនៃអថេរចៃដន្យមួយ គឺជាបញ្ជីសរុបនៃលទ្ធផលទាំងអស់នៃការពិសោធន៍ដែលភ្ជាប់ជាមួយនឹង ប្រូបាបរបស់វា ។
* ចំពោះ ឧទាហរណ៍១ខាងលើ គេបានបំណែងចែកប្រូបាបនៃអថេរចៃដន្យ $X$ ដូចខាងក្រោម ៖

| ចំនួនមុខ(H) $X$ | ប្រូបាបនៃលទ្ធផល $P(X=x)$ |
|---|---|
| 0 | $1/8=0.125$ |
| 1 | $3/8=0.375$ |
| 2 | $3/8=0.375$ |
| 3 | $1/8=0.125$ |
| | $\sum_{x=0}^{3} P(X=x)=1$ |

ឧទាហរណ៍៣៖ ក្នុងប្រអប់មួយមានឃ្លីពណ៌ស ៤០% ហើយក្រៅពីនេះពណ៌ខ្មៅ ។ គំរូមួយដែលគេមានឃ្លីបីគ្រាប់ត្រូវបានគេជ្រើសយកចេញពីក្នុងប្រអប់នេះ។ ចូររកចំណែងចែកប្រូបាបនៃឃ្លីពណ៌ស។

**ចម្លើយ**

យក $X$ តាងអោយចំនួនឃ្លីពណ៌ស នៅក្នុងគំរូ ។ ដូចនេះតម្លៃអាចនៃ $X$ គឺ ៖ $X = 0,1,2,3$ ហើយលំហគំរូមានដូចខាងក្រោម

$S_1 = WWW$

$S_2 = WWB$

$S_3 = WBW$

$S_4 = BWW$

$S_5 = BBW$

$S_6 = BWB$

$S_7 = WBB$

$S_8 = BBB$

ដែល $W = White$ ពណ៌ស និង $B = Black$ ពណ៌ខ្មៅ

ប្រូបាបនៃឃ្លីពណ៌ស $= 0.40$ ហើយ

ប្រូបាបនៃឃ្លីពណ៌ខ្មៅ $= 0.60$

ករណី

$$X = 0 \quad P(X = 0) = P(S_8) = (0.60)(0.60)(0.60) = 0.216$$

$$X = 1 \quad P(X = 1) = P(S_5) + P(S_6) + P(S_7) = 3(0.40)(0.60)^2 = 0.432$$

$$X = 2 \quad P(X = 2) = P(S_2) + P(S_3) + P(S_4) = 3(0.40)^2(0.60) = 0.288$$

$$X = 3 \quad P(X = 3) = P(S_1) = (0.40)(0.40)(0.40) = 0.064$$

ដូចនេះ ចំណែងចែកប្រូបាបនៃអថេរចៃដន្យ $X$ គឺ

| ចំនួនឃ្លីស (X) ក្នុងគំរូ | បំណែងចែកប្រូបាប $P(X = x)$ |
|---|---|
| 0 | 0.216 |
| 1 | 0.432 |
| 2 | 0.288 |
| 3 | 0.064 |

**១.៣. សង្ឃឹមគណិត (Expectation):** $E(X)=\mu$ ( $Mu$ )

តាង $\mu = \boldsymbol{E(X)} = \sum_{\forall x}[\boldsymbol{x.P(X=x)}]$ ដែល

$E(X)=\mu$ គឺជាសង្ឃឹមគណិត រឺ មធ្យមនៃអថេរចៃដន្យ $X$

$X$ ជាអថេរចៃដន្យ ហើយ $x$ ជាតម្លៃនៃ $X$

$P(X=x)$ ជាប្រូបាបនៃអថេរចៃដន្យ $X$

**ឧទាហរណ៍ ៖** $X$ ជាអថេរចៃដន្យមួយដែលមានបំណែងចែក ប្រូបាបដូចខាងក្រោម

| $X$ | $-2$ | $-1$ | $0$ | $1$ | $2$ |
|---|---|---|---|---|---|
| $P(X=x)$ | 0.3 | 0.1 | 0.15 | 0.4 | 0.05 |

ចូររកសង្ឃឹមគណិតនៃ $X$ ។

**ចម្លើយ**

$$E(X)=\sum_{\forall x} x.P(X=x)=(-2)(0.3)+(-1)(0.1)+(0)(0.15)+(1)(0.4)+(2)(0.05)=-0.2$$

**លក្ខណៈ (Properties)**

- $E(a)=a$ , $a$ គឺជាចំនួនថេរ
- $E(aX)=aE(X)$ , $a$ គឺជាចំនួនថេរ
- $E(aX+b)=aE(X)+b$ ; $a,b$ គឺជាចំនួនថេរ
- $E[f_1(X)+f_2(X)]=E[f_1(X)]+E[f_2(X)]$

**១.៤. វ៉ារ្យង់ (Variance)** : $\sigma^2$ , $Var(X)$

វ៉ារ្យង់នៃចំណែកចែកប្រូបាប គឺជាចំនួនមួយដែលបង្ហាញអោយឃើញអំពីទំហំពង្រាយនេះ ហើយត្រូវបានគណនាតាមរូបមន្ត ៖

$$\sigma^2 = \boldsymbol{Var(X)} = \sum_{\forall x}[\boldsymbol{x-E(X)}]^2 \boldsymbol{.P(X=x)}$$

**សំគាល់ ៖** *វ៉ារ្យង់គឺជាមធ្យមនៃការេនៃគំលាតរបស់អថេរចៃដន្យ $X$ ពីមធ្យម $E(X)$ របស់វា។*

ជាមួយ $\mu=E(X)$ នោះគេបាន $Var(X)=E(X-\mu)^2$

ឬ $Var(X)=E(X^2)-\mu^2$

ឬ $Var(X)=E(X^2)-E^2(X)$

ហើយ $E(X^2)$ គណនាតាមរូបមន្ត $\boldsymbol{E(X^2)=\sum_{\forall x} x^2.P(X=x)}$

ចំពោះឧទាហរណ៍ខាងលើ យើងបាន

| $X$ | $-2$ | $-1$ | $0$ | $1$ | $2$ |
|---|---|---|---|---|---|
| $x-\mu$ | $(-2+0.2)$ | $(-1+0.2)$ | $(0+0.2)$ | $(1+0.2)$ | $(2+0.2)$ |
| $(x-\mu)^2$ | 3.24 | 0.64 | 0.04 | 1.44 | 4.84 |
| $P(X=x)$ | 0.3 | 0.1 | 0.15 | 0.4 | 0.05 |
| $(x-\mu)^2 P(X=x)$ | 0.972 | 0.064 | 0.006 | 0.576 | 0.242 |

យើងបាន $\sigma^2 = Var(X) = 0.972+0.064+0.006+0.576+0.242 = 1.86$

### ១.៤. គំលាតគំរូ *(Standard Deviation)*

រូបមន្ត $\boxed{\sigma = \sqrt{\sigma^2}}$

ចំពោះឧទាហរណ៍ខាងលើ យើងបាន $\sigma = \sqrt{\sigma^2} = \sqrt{1.86} = 1.36$ ។

## ២. បំណែងចែកទ្វេធា *(Binomial Distribution)*

### ២.១. លទ្ធផលអាច *(Possible Outcomes)*

ពិសោធន៍ទ្វេធាមួយជាពិសោធន៍ដែលមានលក្ខណៈដូចតទៅ ៖

- ☆ **ពិសោធន៍មានការសាកល្បងដដែលៗ**
- ☆ **ការសាកល្បងម្តងៗលេចចេញជាលទ្ធផលមួយដែលអាចបែងចែកជាពីរករណីស្របតាមបំណង *(success)* រឺមិនស្របតាមបំណង *(Failure)***
- ☆ **ប្រូបាបនៃការជោគជ័យ p មានតម្លៃថេរចំពោះពិសោធន៍មួយលើកៗ ។**
- ☆ **ការសាកល្បងមិនទាក់ទងគ្នា**

ឧបមា យើងតាងលទ្ធផល ជោគជ័យ $S\,(Success)$ និង បរាជ័យដោយ $F(Failure)$ ។

ហើយ : $p$ តាងអោយ ប្រូបាប ជោគជ័យ $S$

: $q$ តាងអោយ ប្រូបាប បរាជ័យ $F$ ដែល $q=1-p$

និង : $x$ ជាអថេរចៃដន្យ ហៅថាអថេរចៃដន្យទ្វេធា

**ដូចនេះ** បំណែងចែកទ្វេធា នៃ $x$ គឺ

$$\boldsymbol{P(x,n,p)=\binom{n}{x}p^{x}q^{n-x}} \text{ សំរាប់ } x=0,1,\ 2,\ldots,n$$

**ឧទាហរណ៍ទី១៖** រកប្រូបាបនៃការទទួលបានលេខ2 បីដង ប្រសិនបើគ្រាប់ឡុកឡាក់ធម្មតាមួយត្រូវបានបោះ 5 ដង ។

**ចម្លើយ**

ប្រូបាបនៃការស្របតាមបំណងមួយលើការសាកល្បង 5 ដង មិនទាក់ទងគ្នា ស្មើ$\frac{1}{6}$ និងប្រូបាបនៃការមិនស្របតាមបំនងស្មើ $\frac{5}{6}$ ។ លទ្ធផលពីរដែលគេត្រូវចាត់ទុកជាការស្របតាមបំណងនៅទីនេះ ។

ដូចនេះ $P\left(3,4,\frac{1}{6}\right)=\binom{5}{3}\left(\frac{1}{6}\right)^{3}\left(\frac{5}{6}\right)^{2}=\frac{5!}{3!2!}\times\frac{5^{2}}{6^{2}}=0.032$

**ឧទាហរណ៍ទី២៖** ក្នុងឃ្លាំងមួយដែលមានទំនិញ 1000ឯកតា មាន100 ខូចគុណភាពឯកតា ។ គំរូមួយដែលមាន ទំនិញ 10ឯកតា ត្រូវបានគេជ្រើសរើសចេញពីឃ្លាំងនេះ ដោយដាក់ចូលវិញ ។

រកប្រូបាបដែលក្នុងគំរូនេះមានទំនិញខូចមួយឯកតា ? មានយ៉ាងច្រើនមួយ ?

**ចម្លើយ**

យើងឃើញថា $n=10$ , $P=\frac{100}{1000}=0.10 \Rightarrow q=1-0.10=0.90$

ហើយ $x$ ជាអថេរចៃដន្យទ្វេធា ព្រោះយើងមានតែពីរករណីគឺទំនិញល្អ និងខូច ដូចនេះគេបាន ៖

- ប្រូបាបមានទំនិញខូចមួយឯកតានៅក្នុងគំរូនេះគឺ

$$P(1,10,0.10)=\binom{10}{1}(0.10)^1(0.90)^9=0.3874$$

- ប្រូបាបយ៉ាងច្រើនមានទំនិញខូចមួយឯកតានៅក្នុងគំរូនេះគឺ

$$P(0,10,0.10)+b(1,10,0.10)=\binom{10}{0}(0.10)^0(0.90)^{10}+\binom{10}{1}(0.10)^1(0.90)^9$$

$$=0.3487+0.3874=0.7361$$

**២.២. សង្ឃឹមគណិតនៃអថេរចៃដន្យទ្វេធា**

❖ បើ $X$ ជាអថេរចៃដន្យទ្វេធា គេបាន $\boxed{E(X)=np}$ ដែល $n$ គឺជាចំនួនពិសោធន៍ និង $p$ គឺជាប្រូបាបជោគជ័យ ។

ចំពោះ ឧទាហរណ៍ទី២ ខាងលើ យើងបាន $\mu=E(X)=np=(10)(0.10)=1$ ។

**២.៣. វ៉ារ្យង់**

❖ បើ $X$ ជាអថេរចៃដន្យទ្វេធា គេបាន

$$\boxed{\sigma^2=Var(X)=np(1-p)}$$

ចំពោះ ឧទាហរណ៍ទី២ខាងលើ យើងបាន

$$\sigma^2=Var(X)=np(1-p)=(10)(0.10)(0.90)=0.90$$

**២.៤. គំលាតគំរូ** (Standard Deviation)

❖ បើ $X$ ជាអថេរចៃដន្យទ្វេធា គេបាន $\boxed{\sigma=\sqrt{\sigma^2}}$

ចំពោះឧទាហរណ៍ទី២ ខាងលើគេបាន $\sigma=\sqrt{\sigma^2}=\sqrt{0.90}=0.94487$

## ៣. បំណែងចែកធរណីមាត្រ *(Geometric Distribution)*

### ៣.១. ពិសោធន៍ឯករាជ្យ *(Independent Trials)*

ចូរពិនិត្យការពិសោធន៍ឯករាជ្យជាច្រើនសារ ការពិសោធន៍នីមួយៗ មានប្រូបាប $p$ ដែលឱ្យលទ្ធផលជោគជ័យ ហើយ $q$ ជាប្រូបាបដែលឱ្យលទ្ធផលបរាជ័យ $(q=1-p)$ ។ យក $X$ ជាអថេរចៃដន្យ នៃចំនួនពិសោធន៍រហូតដល់ គេទទួលបាន លទ្ធផលជោគជ័យលើកទីមួយនៅពិសោធន៍លើកចុងក្រោយ ។

$P(X=1)=p$ , ( ជោគជ័យលើកទី១ លើការពិសោធន៍លើកទី១ ) $=p$

$P(X=2)=qp$ , (ជោគជ័យលើកទី១ លើការពិសោធន៍លើកទី២ ) $=qp$

$P(X=3)=q^2p$ ,(ជោគជ័យលើកទី១ លើការពិសោធន៍លើកទី៣ ) $=q^2p$

.........................................................................

$P(X=x)=q^{x-1}p$ , (ជោគជ័យលើកទី១ លើការពិសោធន៍លើកទី $x$ ) $=q^{x-1}p$

យើងឃើញថា $X$ ជាចំនួនសរុបនៃការពិសោធន៍ ហើយមាន $(X-1)$ ជាចំនួនលទ្ធផល បរាជ័យមុនពេល ទទួលលទ្ធផលជោគជ័យលើកទី១ ករណីនេះ គេថា $X$ មានបំណែងចែកធរណីមាត្រ ហើយគេបាន រូបមន្ត :

$$\boldsymbol{P(X=x)=q^{x-1}p} \quad , \quad x=1,\ 2,\ldots$$

**៣.២. សង្ឃឹមគណិត**

$$\mu=\frac{1}{\boldsymbol{p}}$$

**៣.៣. វ៉ារ្យង់**

$$\sigma^2=\boldsymbol{Var(X)}=\frac{\boldsymbol{q}}{\boldsymbol{p}^2}$$

**ឧទាហរណ៍៣៖** ដោយដឹងថា ប្រូបាបនៃកូនស្រីស្មើ $\frac{1}{2}$ ។ ឧបមាគូស្នេហ៍ ដៃទើបរៀបការរួច ចង់ដឹងថា តើពួកគេត្រូវមានកូនប៉ុន្មាននាក់ ដែលមានប្រូបាប យ៉ាងហោចណាស់ 0.95 ទើបពួកគេបានកូនស្រីម្នាក់ ?

**ចម្លើយ**

ដោយចង់បានកូនស្រីតែមួយហើយជាស្រីពៅ ហើយកូនច្បងទាំងអស់ជាកូនប្រុស ដូចនេះ កូនដែលកើតមកនេះ មានបំណែងចែកធរណីមាត្រ ហើយប្រូបាបដែលពួកគេមានកូនចំនួន $X$ គឺ

$$P(X=x)=\left(\frac{1}{2}\right)^{x-1}\left(\frac{1}{2}\right)=\left(\frac{1}{2}\right)^x$$

ប្រូបាបដែលមានកូន $m$ នាក់ ឬ តិចជាងនេះ

$$P(\text{ កូន } m \text{ នាក់ឬ តិចជាង})=\sum_{x=1}^{m}\left(\frac{1}{2}\right)^x$$

ដូចនេះបើ :

☆ $x=1:\ P($ កូន ១នាក់ រឺតិចជាង $)=\sum_{x=1}^{1}\left(\frac{1}{2}\right)^{x}=0.50$

☆ $x=2:\ P($ កូន ២នាក់ រឺតិចជាង $)=\sum_{x=1}^{2}\left(\frac{1}{2}\right)^{x}=0.50+0.25=0.75$

☆ $x=3:\ P($ កូន ៣នាក់ រឺតិចជាង $)=\sum_{x=1}^{3}\left(\frac{1}{2}\right)^{x}=0.50+0.25+0.125=0.875$

☆ $x=4:\ P($ កូន ៤នាក់ រឺតិចជាង $)=\sum_{x=1}^{4}\left(\frac{1}{2}\right)^{x}=0.50+0.25+0.125+0.0625=0.9375$

☆ $x=5:\ P($ កូន ៥នាក់ រឺតិចជាង $)=\sum_{x=1}^{5}\left(\frac{1}{2}\right)^{x}=0.50+0.25+0.125+0.0625+0.0313=0.9688$

☆ $x=6:\ P($ កូន ៥នាក់ រឺតិចជាង $)=\sum_{x=1}^{6}\left(\frac{1}{2}\right)^{x}=0.50+0.25+0.125+0.0625+0.0313+0.0156$

$$=0.9844$$

យើងរៀបប្រូបាបទាំងនេះក្នុងតារាងដូចខាងក្រោម :

| $M$ | 1 | 2 | 3 | 4 | 5 | 6 |
|---|---|---|---|---|---|---|
| *Probability* | 0.5 | 0.75 | 0.87 | 0.94 | 0.97 | 0.98 |

យើងឃើញថា កូន៥នាក់ ឬ តិចជាង ផ្តល់ប្រូបាប 0.97 ។ ក្នុងករណីនេះមានន័យថា ប្តីប្រពន្ធខាងលើ នឹងទទួលបានជោគជ័យ (កូនស្រីពៅ) នៅលើកទី៥ ។

## ៤. បំណែងចែក *Poisson (Poisson Distribution)*

ពិសោធន៍ព័រសុងជាពិសោធន៍មានលក្ខណៈដូចតទៅ ៖

☆ ចំនួននៃលទ្ធផលកើតឡើងក្នុងចន្លោះពេលមួយ(តំបន់ជាក់លាក់មួយ) មិនអាស្រ័យគ្នានឹងចំនួនដែលកើតឡើងក្នុងចន្លោះពេល (តំបន់ដាច់គ្នាណាមួយ) ផ្សេងទៀតទេ ។

☆ ប្រូបាបដែលលទ្ធផលច្រើនជាងមួយនឹងកើតឡើងក្នុងចន្លោះពេលខ្លី ឬតំបន់តូចអាចចោលបាន (ស្មើសូន្យ) ។

ឧទាហរណ៍ ដូចជា :

- ✓ ចំនួនអតិថិជនចូលមកបរិភោគអាហារថ្ងៃត្រង់ក្នុងភោជនីយដ្ឋានមួយក្នុងចន្លោះម៉ោង $10:00am - 11:00\ am$ ។
- ✓ ចំនួនគ្រោះថ្នាក់នៅក្នុងរោងចក្រ កើតឡើងក្នុង មួយសប្តាហ៍ ។
- ✓ ចំនួនការហៅទូរសព្ទ័ ភ្ជាប់បណ្តាញកើតឡើងក្នុងមួយនាទី ។
- ✓ ចំនួនទំនិញ ខូចគុណភាពក្នុងការបញ្ជូនទៅក្រៅ ។
- ✓ ចំនួនអតិថិជនឈរ រង់ចាំគិតលុយនៅ Super Market ។ល។

បើ $X$ តាងអោយចំនួនជោគជ័យកើតឡើងនៅក្នុងលក្ខណៈបែបនេះ ដូចករណីឧទាហរណ៍ ខាងលើ នោះគេថា $X$ មានបំណែងចែក Poisson ហើយប្រូបាប កំណត់ដោយ ៖

$$\boldsymbol{P(X) = \frac{e^{-\mu}.\mu^{x}}{x!}}$$

ដែល $\mu$ $(Mu)$ : គឺជាមធ្យមនព្វន្តនៃចំនួនជោគជ័យកើតឡើង នៅក្នុងចន្លោះពេលណាមួយ ។

$e$ : ជាគោឡូការីតនេពែ $e = 2.71828.....$

$x$ : គឺជាប្រូបាបដែលត្រូវគណនាសំរាប់តំលៃ $x$ ដាក់លាក់មួយ ។

☆ **មធ្យម** $(\mu)$ នៃចំនួនជោគជ័យអាចគណនាតាមលក្ខណៈ ***Poisson :***

$$\boldsymbol{E(X) = \mu}$$

ដែល $n$ គឺជាចំនួននៃការពិសោធន៍ ហើយ $p$ គឺជាប្រូបាបជោគជ័យ ។

☆ **វ៉ារ្យង់** $\sigma$ នៃបំណែងចែក Poisson

$$\sigma^2 = \mu$$

**សម្គាល់ ៖** *នៅពេលដែលប្រូបាបជោគជ័យ p តិចជាង* 0.05 *ហើយចំនួនពិសោធន៍* **n** *ធំ ( Ex :* $\mathbf{n} = 100$ *ឬច្រើនជាង ) ការគណនាតាមបំណែងចែកប្រូបាបទ្វេធាមានការលំបាក ដូច្នេះ គេប្រើបំណែងចែក Poisson ។*

**ឧទាហរណ៍១ ៖** ក្នុងកសិដ្ឋានចិញ្ចឹមសត្វមួយកន្លែងបែងចែកតំបន់ៗដោយមួយតំបន់ដាក់សត្វ 500 ក្បាល ។ ប្រូបាបដែលសត្វមួយក្បាលមានជំងឺស្មើ 0.002 ។ រកប្រូបាបដែល តំបន់មួយ មានសត្វ 2 ក្បាល មានជំងឺ ?

**ចម្លើយ**

យើងយក $X$ ជាអថេរចៃដន្យតាងអោយចំនួនសត្វដែលឈឺ ក្នុងតំបន់មួយហើយ $X$ អាចមានតម្លៃ $X = 0, 1, 2, 3, ...$ ។ ដោយ $n$ មានចំនួនធំគឺ $n = 500$ ហើយប្រូបាបកាន់តែតូច $p = 0.002$ ។ ដូច្នេះ យើងអនុវត្ត បំណែងចែក Poisson នៃអថេរចៃដន្យ $X$ ដែល :

មធ្យម $\mu = np = 500(0.002) = 1$ និង វ៉ារ្យង់ $\sigma^2 = \mu = np = 1$ ។

ករណីនេះ $X = 2 \Rightarrow$ $\boxed{P(X) = \frac{e^{-\mu}.\mu^x}{x!} = \frac{e^1.1^2}{2!} = 0.184}$

**សំគាល់** : *យើងអាចគណនាប្រូបាបនេះតាមបំណែងចែកទ្វេធា តែយើងជួបប្រទះការលំបាកក្នុងការគណនា* : $n = 500$ , $p = 0.002$ , $q = 1 - p = 1 - 0.002 = 0.998$

$$P(X = 2) = C_n^r \times q^{n-x} p^x = \frac{n!}{r!(n-r)!} \times q^{n-x} p^x = \frac{500!}{2!(500-2)!}(0.998)^{498}(0.002)^2 = 0.184$$

**ឧទាហរណ៍២៖** សៀវភៅមួយក្បាលមាន ៥០០ទំព័រ មានបោះពុម្ពខុស ៧៥០កំហុស ។

1) តើជាមធ្យមមានការបោះពុម្ពខុសប៉ុន្មាន?
2) រកប្រូបាប ដែលទំព័រទី៤២៧
   a. គ្មានការបោះពុម្ពខុស
   b. មានការបោះពុម្ពខុស ៤
   c. មានការបោះពុម្ពខុសច្រើនជាមធ្យម ។

3). រកប្រូបាប ដែលទំព័រទី៤២៧ និង៤២៨ គ្មានការបោះពុម្ពខុស ។

**ចម្លើយ**

ក្នុងករណីនេះ យើងពិនិត្យឃើញថា ចំនួនកំហុស 750 កំហុស កើតឡើងនៅក្នុងផ្ទៃនៃក្រដាសសៀវភៅ ដែលមាន 500 ( $n = 500$ ) ទំព័រ ដូចនេះ បើយើងតាង $X$ ជាចំនួនកំហុសដែលកើតឡើងក្នុងការបោះពុម្ព ពេលនេះ $X$ មានបំណែងចែក Poisson ( អថេរចៃដន្យ Poisson ) ។

1). កំហុសជាមធ្យមនៅលើមួយទំព័រ

$$\mu = \frac{750}{500} = 1.5$$

**គួរកត់សំគាល់ថា** $\mu = np = 1.5 \Rightarrow p = \frac{\mu}{n} = \frac{1.5}{500} = 0.003$ *ករណីនេះ p តូចណាស់ ។*

2). យក $x$ ជាចំនួនកំហុសដែលកើតឡើងក្នុងការបោះពុម្ព ដូចនេះ $x = 0\ ,\ 1\ ,\ 2\ ,\ .\ .\ .\ ,\ 750$ ប្រូបាប ដែលទំព័រទី ៤២៧ :

a. គ្មានការបោះពុម្ពខុស បានន័យថា $x = 0$

$$P(X) = \frac{e^{-\mu}\mu^{x}}{x!} = \frac{e^{-1.5}(1.5)^{0}}{0!} = 0.2231$$

b. មានការបោះពុម្ពខុស ៤ បានន័យថា $x = 4$

$$P(X) = \frac{e^{-\mu}\mu^{x}}{x!} = \frac{e^{-1.5}(1.5)^{4}}{4!} = 0.0471$$

c. មានការបោះពុម្ពខុសច្រើនជាមធ្យម :

ក្នុងករណីនេះយើងរកប្រូបាបដែលមានកំហុសតិចជាងមធ្យម វាជាការងាយស្រួលជាង :

$$P(X < \mu) = P(X = 0) + P(X = 1) = \frac{e^{-1.5}(1.5)^{0}}{0!} + \frac{e^{-1.5}(1.5)^{1}}{1!} = 0.2231 + 0.3347 = 0.5578$$

ប្រូបាបដែលមានកំហុសច្រើនជាងមធ្យម គឺ

$$P(X > \mu) = 1 - P(X < \mu) = 1 - 0.5578 = 0.4422$$

3). រកប្រូបាប ដែលទំព័រទី ៤២៧ និង ៤២៨ គ្មានការបោះពុម្ពខុស

ករណីនេះ យើងតាង $\mu_1$ កំហុសជាមធ្យមនៅលើពីរទំព័រ ៤២៧ និង៤២៨ មានន័យថា ៧៥០ កំហុសកើតឡើងនៅលើសៀវភៅមួយក្បាលមាន $\frac{500}{2} = 250$ ទំព័រ

គឺយើងគួបពីរទំព័រធ្វើតែមួយទំព័រ ។

ហេតុនេះ $\mu_1 = 2\mu = 2(1.5) = 3.0$ ឬ $\mu_1 = \frac{750}{250} = 3.0$ ហើយ $x$ យកតំលៃ $0, 1, 2, . . . , 750$

$$P(X) = \frac{e^{-\mu_1}\mu_1^{\ x}}{x!} = \frac{e^{-3}(3)^{0}}{0!} = 0.0498$$

## ផ្នែកលំហាត់ និងចម្លើយ

**១**. ប្រអប់មួយមានសំបុត្រ ២០ ដែលសំបុត្រ ១៨ សរសេរថាចាញ់ និងសំបុត្រ ២ សរសេរថាឈ្នះ ។ សំបុត្រមួយត្រូវបានគេចាប់ចេញពីប្រអប់ដោយចៃដន្យ ។ រកប្រូបាបដើម្បីឱ្យគេចាប់បានសំបុត្រឈ្នះ ។

**ចម្លើយ**

រកប្រូបាបដើម្បីឱ្យគេចាប់បានសំបុត្រឈ្នះ

តាង $A$ ជាព្រឹត្តិការណ៍ចាប់បានសំបុត្រឈ្នះ

- ចំនួនករណីស្រប $n(A)=C_2^1=2$ ព្រោះសំបុត្រឈ្នះ ២ចាប់យក ១
- ចំនួនករណីអាច $n(S)=C_2^1=20$

នាំឱ្យ $P(A)=\dfrac{n(A)}{n(S)}=\dfrac{2}{20}=\dfrac{1}{10}$

ដូចនេះ $P(A)=\dfrac{1}{10}$ ។

**២**. បៀមួយសន្លឹកត្រូវបានគេចាប់យកចេញពីក្នុងហ្វៀបៀដែលមាន ៥២សន្លឹកដោយចៃដន្យ ។

ក. រកប្រូបាបដែលគេចាប់យកសន្លឹកការ៉ូ

ខ. រកប្រូបាបដែលគេចាប់យកបានសន្លឹក ៦

គ. រកប្រូបាបដែលគេចាប់យកបានសន្លឹក ៦ការ៉ូ ។

**ចម្លើយ**

**ក**. រកប្រូបាបដែលគេចាប់បានសន្លឹកការ៉ូ

*Note* បៀទាំងអស់មាន៥២សន្លឹកហើយចែកជា ៤ទឹក

- ការ៉ូ ១៣សន្លឹក
- កឺ ១៣សន្លឹក
- ជួង ១៣សន្លឹក
- ភិច ១៣សន្លឹក

តាង $A$ ជាព្រឹត្តិការណ៍ចាប់បានសន្លឹកការ៉ូ

ចំនួនករណីស្រប $n(A)=C^{1}_{13}=13$ ព្រោះសន្លឹកការ៉ូ ១៣ហើយគេចាប់យក ១

ចំនួយករណីអាច $n(S)=C^{1}_{52}=52$

នាំឱ្យ $P(A)=\dfrac{13}{52}$

ដូចនេះ $P(A)=\dfrac{13}{52}$ ។

**ខ**. រកប្រូបាបដែលគេចាប់បានសន្លឹក ៦

ចំនួនករណីស្រប $n(B)=C^{1}_{4}=4$

នាំឱ្យ $P(B)=\dfrac{4}{52}=\dfrac{1}{13}$

ដូចនេះ $P(B)=\dfrac{1}{13}$

**គ**. រកប្រូបាបដែលចាប់បានសន្លឹក ៦ការ៉ូ

តាង $C$ ជាព្រឹត្តិការណ៍ចាប់បានសន្លឹក ៦ការ៉ូ

ចំនួនករណីស្រប $n(C)=C^{1}_{1}=1$

នាំឱ្យ $P(C)=\dfrac{1}{52}$

ដូចនេះ $P(C)=\dfrac{1}{52}$ ។

**៣**. ឧបមាគេបោះគ្រាប់ឡុកឡាក់ធំមួយ និងគ្រាប់ឡុកឡាក់តូចមួយព្រមគ្នា ហើយតាង $x$ ជាចំនួនដែលចេញលើគ្រាប់ឡុកឡាក់ធំ និង$y$ ជាចំនួនដែលចេញលើគ្រាប់ឡុកឡាក់តូច ។ រកប្រូបាបដែល $x^2<4y$ ។

**ចម្លើយ**

រកប្រូបាបដែល $x^2<4y$

តាង $E$ ជាព្រឹត្តិកាណ៍នេះ

| $4y \backslash x^2$ | $1^2$ | $2^2$ | $3^2$ | $4^2$ | $5^2$ | $6^2$ |
|---|---|---|---|---|---|---|
| 4.1 | $(1,4)$ | $(4,4)$ | $(9,4)$ | $(16,4)$ | $(25,4)$ | $(36,4)$ |
| 4.2 | $(1,8)$ | $(4,8)$ | $(9,8)$ | $(16,8)$ | $(25,8)$ | $(36,8)$ |
| 4.3 | $(1,12)$ | $(4,12)$ | $(9,12)$ | $(16,12)$ | $(25,12)$ | $(36,12)$ |
| 4.4 | $(1,16)$ | $(4,16)$ | $(9,16)$ | $(16,16)$ | $(25,16)$ | $(36,16)$ |
| 4.5 | $(1,20)$ | $(4,20)$ | $(9,20)$ | $(16,20)$ | $(25,20)$ | $(36,20)$ |
| 4.6 | $(1,24)$ | $(4,24)$ | $(9,24)$ | $(16,24)$ | $(25,24)$ | $(36,24)$ |

គេបាន ចំនួនករណីស្រប $n(E)=17$

ចំនួនករណីអាច $n(S)=36$

នាំឱ្យ $P(E)=\frac{17}{36}$

ដូចនេះ $P(E)=\frac{17}{36}$ ។

៤. បើ $A$ និង $B$ ជាព្រឹត្តិការណ៍ពីរក្នុងលំហសំណាក $S$ ដែល $P(A)=0.3$ ; $P(B)=0.6$ និង $P(A\cap B)=0.2$ ។ រក

ក. $P(A')$ ខ. $P(B')$ គ. $P(A\cup B)$

ឃ. $P(A'\cap B)$ ង. $P(A'\cup B')$ ច. $P(A'\cap B')$ ។

**ចម្លើយ**

គេមាន $P(A)=0.3$ , $P(B)=0.6$ និង $P(A\cap B)=0.2$

ក. គណនា $P(A')$

គេមាន $P(A')=1-P(A)$

$P(A')=1-0.3$

$P(A')=0.7$

ដូចនេះ $P(A')=0.7$ ។

**ខ.** គណនា $P(B')$

គេមាន $P(B')=1-P(B)$

$=1-0.6=0.4$

ដូចនេះ $P(B')=0.4$

**គ.** គណនា $P(A\cup B)$

តាម $P(A\cup B)=P(A)+P(B)-P(A\cap B)$

$P(A\cup B)=0.3+0.6-0.2$

$=0.7$

ដូចនេះ $P(A\cup B)=0.7$ ។

**ឃ.** គណនា $P(A'\cap B)$

គេមាន $P(A'\cap B)=P(B)-P(A\cap B)$ ព្រោះ

$P(A'\cap B)=0.6-0.2=0.4$

ដូចនេះ $P(A'\cap B)=0.4$




**ង.** គណនា $P(A'\cup B')$

គេមាន $P(A'\cup B')=P(A\cap B)'=1-P(A\cap B)$

$=1-0.2$

$=0.4$

ដូចនេះ $P(A'\cup B')=0.4$

**ច.** គណនា $P(A'\cap B')$

គេមាន $P(A'\cap B')=P(A\cup B)'=1-P(A\cup B)$

$=1-0.7$

$=0.3$

ដូចនេះ $P(A'\cap B')=0.3$

**៥**. គេឱ្យ $A$ និង $B$ ជាព្រឹត្តិការណ៍ពីរមិនទាក់ទងគ្នា ហើយ $P(A\cap B)=0.1$ និង $P(A\cup B)=0.6$ ។ ចូរគណនា $P(A)$ និង $P(B)$ ។

**ចម្លើយ**

គណនា $P(A)$ និង $P(B)$ ចំពោះ $P(A\cup B)=0.6$ និង $P(A\cap B)=0.1$

ករណី $A$ និង $B$ ជាព្រឹត្តការណ៍មិនទាក់ទងគ្នា

នោះ $P(A\cap B)=P(A)\times P(B)$

$$0.1=x\times y \qquad (1)$$

តាង $x=P(A)$ និង $y=P(B)$

ហើយ $P(A\cup B)=P(A)+P(B)-P(A\cap B)$

$0.6=x+y-0.1$

$x+y=0.7 \qquad (2)$

តាម $(1)$ គេបាន $x=\dfrac{0.1}{y}$ ជំនួសក្នុង $(2)$ នោះ

$\dfrac{0.1}{y}+y=0.7$

$0.1+y^2=0.7y$

$1+10y^2=7y$

$10y^2-7y+1=0$

មាន

$\Delta=7^2-4.10.1=9$

$\Rightarrow x_1=\dfrac{7-3}{20}=\dfrac{4}{20}=\dfrac{1}{5}$

$x_2=\dfrac{7+3}{20}=\dfrac{10}{20}=\dfrac{1}{2}$

- ចំពោះ $x=\dfrac{1}{5}$ នោះ $y=\dfrac{1}{10x}=\dfrac{1}{10\times\dfrac{1}{5}}=\dfrac{1}{2}$
- ចំពោះ $x=\dfrac{1}{2}$ នោះ $y=\dfrac{1}{10\times\dfrac{1}{2}}=\dfrac{1}{5}$

ដូចនេះ $P(A)=\dfrac{1}{5}$ និង $P(B)=\dfrac{1}{2}$ ហើយ $P(A)=\dfrac{1}{2}$ និង $P(B)=\dfrac{1}{5}$

៦. គេឱ្យ $A$ និង $B$ ជាព្រឹត្តិការណ៍ពីរដែល $P(A)=0.5$ និង $P(B)=0.4$ ។
ចូរគណនា $P(A\cup B)$ ក្នុងករណីខាងក្រោម ៖

ក. $A$ និង $B$ មិនចុះសំរុងគ្នា

ខ. $A$ និង $B$ មិនទាក់ទងគ្នា ។

**ចម្លើយ**

គណនា $P(A\cup B)$ ដែលមាន $P(A)=0.5$ និង $P(B)=0.4$

ក. $A$ និង $B$ មិនចុះសម្រុងគ្នា មាន $A\cap B=\varnothing$

គេបាន $P(A\cup B)=P(A)+P(B)$

$=0.5+0.4$

$=0.9$

ដូចនេះ $P(A\cup B)=0.9$

ខ. $A$ និង $B$ មិនទាក់ទងគ្នា គេបាន $P(A\cap B)=P(A)\times P(B)$

គេបាន $P(A\cup B)=P(A)+P(B)-P(A\cap B)$

$=0.5+0.4-0.5\times 0.4$

$=0.9-0.2$

$=0.7$

ដូចនេះ $P(A\cup B)=0.7$

៧. $A$ និង $B$ ជាព្រឹត្តិការណ៍ពីរដែល $P(A\cup B)=0.8$ និង $P(A\cap B)=0.15$ ។

ក. តើ $P(A)$ អាចប្រែប្រួលពីណា ដល់ណា ?

ខ. គណនា $P(A)$ និង $P(B)$ ក្នុងករណីដែលព្រឹត្តិការណ៍ទាំងពីរមិនទាក់ទងគ្នា ។

**ចម្លើយ**

ក. តើ $P(A)$ អាចប្រែប្រួលពីណាដល់ណា? ដែល $P(A\cup B)=0.8$ ; $P(A\cap B)=0.15$

គេមាន $A\cap B\subset A\subset A\cup B$

$P(A\cap B)\le P(A)\le P(A\cup B)$

$0.15\le P(A)\le 0.8$

មើលរូប ៖




ដូចនេះ $0.15 \le P(A) \le 0.8$

**ខ.** គណនា $P(A)$ និង $P(B)$ ក្នុងករណីព្រឹត្តិការណ៍ទាំងពីរមិនទាក់ទងគ្នា

គេមាន $P(A)=x$ និង $P(B)=y$

ករណីមិនទាក់ទងគ្នា

$$P(A\cap B)=P(A)\times P(B)$$
$$0.15=xy$$
$$x=\frac{0.15}{y} \qquad (1)$$

ហើយ $P(A\cup B)=P(A)+P(B)-P(A\cap B)$

$$0.8=x+y-0.15$$
$$x+y=0.95 \qquad (2)$$

យក (1) ជំនួសក្នុង (2) នាំឱ្យ

$$\frac{0.15}{y}+y=0.95$$
$$\Leftrightarrow 15+100y^2=95y$$
$$\Leftrightarrow 100y^2-95y+15=0$$
$$\Leftrightarrow 20y^2-19y+3=0$$

មាន $\Delta=19^2-4.20.3$

$$=361-240$$
$$=121$$

$$\Delta=11^2$$
$$y_1=\frac{19-11}{40}=\frac{8}{40}=\frac{1}{5}$$
$$y_2=\frac{19+11}{40}=\frac{30}{40}=\frac{3}{4}$$

ចំពោះ $y_1=\frac{1}{5} \Rightarrow x=\frac{15}{100\times\frac{1}{5}}=\frac{15}{20}=\frac{3}{4}$

ចំពោះ $y_2 = \frac{3}{4} \quad \Rightarrow \quad x = \frac{15}{100 \times \frac{3}{4}} = \frac{15}{75} = \frac{1}{5}$

ដូចនេះ $P(A) = \frac{3}{4}$ និង $P(B) = \frac{1}{5}$ ហើយ $P(A) = \frac{1}{5}$ និង $P(B) = \frac{3}{4}$

**៨**. ថ្នាក់រៀនមួយមានសិស្សប្រុស ១០នាក់ និងសិស្សស្រី ២០នាក់ ដែលក្នុងនោះពាក់កណ្តាលសិស្សប្រុស និងពាក់កណ្តាលសិស្សស្រីមានភ្នែកពណ៌ត្នោត ។ គ្រូហៅសិស្សម្នាក់មកកាន់ក្តារខៀនដោយចៃដន្យ ។ រកប្រូបាបដើម្បីឱ្យគ្រូហៅចំសិស្សប្រុស ឬសិស្សស្រីមានភ្នែកពណ៌ត្នោត ។

**ចម្លើយ**

រកប្រូបាបដើម្បីឱ្យគ្រូហៅចំសិស្សប្រុស ឬសិស្សស្រីមានភ្នែកពណ៌ត្នោត

តាង $B$ ជាព្រឹត្តិការណ៍ហៅចំសិស្សប្រុសមានភ្នែកពណ៌ត្នោត

$G$ ជាព្រឹត្តិការណ៍ហៅចំសិស្សស្រីមានភ្នែកពណ៌ត្នោត

- ចំនួនករណីស្រប $n(B) = C_5^1 = 5$
- ចំនួនករណីស្រប $n(G) = C_{10}^1 = 10$
- ចំនួនករណីអាច $n(S) = C_{30}^1 = 30$

នាំឱ្យ $P(B \cup G) = P(B) + P(G)$

$$= \frac{5}{30} + \frac{10}{30}$$

$$= \frac{15}{30} = \frac{1}{2}$$

ដូចនេះ $P(B \cup G) = \frac{1}{2}$

**៩**. គ្រាប់ឡុកឡាក់ពីរត្រូវបានបោះព្រមគ្នាហើយ គេធ្វើផលបូកលេខដែលនៅមុខខាងលើ ។ រកប្រូបាប ដែលគេបានផលបូកនោះស្មើ ៥ ឬស្មើ៨ ។

**ចម្លើយ**

រកប្រូបាបដែលគេមានផលបូកនោះស្មើ5 ឬ ស្មើ8

តាង $A$ ជាព្រឹត្តិការណ៍បានផលបូកស្មើ5

$B$ ជាព្រឹត្តិការណ៍បានផលបូកស្មើ8

- ចំនួនករណីស្រប $n(A)=4$ ព្រោះផលបូកស្មើ5មាន $(2,3),(3,2),(1,4)$ និង $(4,1)$ ។
- ចំនួនករណីស្រប $n(B)=5$ ព្រោះផលបូកស្មើ8មាន $(2,6),(6,2),(5,3),(3,5)$ និង $(4,4)$ ។
- ចំនួនករណីអាច $n(S)=36$

នាំឱ្យ $P(A\cup B)=P(A)+P(B)$

$$=\frac{4}{36}+\frac{5}{36}$$

$$=\frac{9}{36}$$

ដូចនេះ $P(A\cup B)=\frac{1}{4}$ ។

**១០**. នៅលើក្រដាសកាតុង ១០០ រាងការេប៉ុនគ្នា និងដូចគ្នាមានចុះលេខរៀងពី ១ដល់ ១០០ ។ គេចាប់យកក្រដាសកាតុងនេះ មួយដោយចៃដន្យ ។ គណនាប្រូបាបដើម្បីឱ្យ ៖

**ក.** យកបានក្រដាសកាតុងដែលគ្មានលេខ ៥ ។

**ខ.** យកបានក្រដាសកាតុងដែលមានលេខរៀងចែកដាច់នឹង២ ឬចែកដាច់នឹង៥ ឬចែកដាច់នឹង២ផង ចែកដាច់នឹង ៥ផង ។

**ចម្លើយ**

**ក.** រកប្រូបាបដែលគេយកបានក្រដាសកាតុងដែលគ្មានលេខ5

តាង $C$ ជាព្រឹត្តិការណ៍នេះ

- ចំនួនករណីស្រប $n(C)=90$ ព្រោះមានលេខ5គឺ $5,15,25,35,45,55,65,75,85,95$ ។
- ចំនួនករណីអាច $n(S)=C_{100}^{1}=100$

នាំឱ្យ $P(C)=\frac{90}{100}=\frac{9}{10}$

ដូចនេះ $P(C)=\frac{9}{10}$

**ខ.** រកប្រូបាបដែលចាប់បានក្រដាសកាតុងដែលមានលេខចែកដាច់នឹង $2$ ឬចែកដាច់នឹង $5$ ឬ ចែកដាច់នឹង $2$ ផង ចែកដាច់នឹង $5$ ផង

- តាង $R$ ជាព្រឹត្តិការណ៍យកបានលេខចែកដាច់នឹង $2$

  ចំនួនករណីស្រប $n(B)=50$ ព្រោះលេខគូមាន $50$ ហើយចែកដាច់នឹង $2$

នោះ $P(B)=\frac{50}{100}=\frac{1}{2}$

- តាង $C'$ ជាព្រឹត្តិការណ៍យកបានលេខចែកដាច់នឹង $5$

  គេបាន $P(C')=1-P(C)$

  $$=1-\frac{9}{10}$$

  $$P(C')=\frac{1}{10}$$

- ប្រូបាបដែលចែកដាច់ $2$ នឹង $5$

  ចំនួនករណីស្រប $n(B\cap C')=10$ ព្រោះលេខចែកដាច់ $2$ នឹង $5$ ជាពហុគុណរវាង $2$ នឹង $5$ គឺ $PPCM(2,5)=10$ នោះលេខចែកដាច់នឹង $10$ គឺមាន $10$ លេខ

នាំឱ្យ $P(B\cap C')=\frac{10}{100}=\frac{1}{10}$

គេបាន ប្រូបាបដែលលេខចែកដាច់នឹង $2$ ឬចែកដាច់នឹង $5$ ឬចែកដាច់នឹង $2$ ផង ចែកដាច់នឹង $5$ ផងគឺ

$$P\left[B\cup C'\cup(B\cap C')\right]=P(B)+P(C')+P(B\cap C')$$

$$=\frac{5}{10}+\frac{1}{10}+\frac{1}{10}$$

$$=\frac{7}{10}$$

**ដូចនេះ** $P\left[B\cup C'\cup(B\cap C')\right]=\frac{7}{10}$

**១១**. គេមានកាក់ ៩ដែលចុះលេខពី $1, 2, \dots, 9$ ។ គេចាប់យកកាក់ ៤ដោយចៃដន្យរួចរៀបជាជួរដេក ។ គណនាប្រូបាប ដើម្បីឱ្យគេបានចំនួនគូ ។

**ចម្លើយ**

គណនាប្រូបាបដើម្បីឱ្យគេបានចំនួនគូ

តាង $A$ ជាព្រឹត្តិការណ៍ចាប់បានលេខគូ

$\underline{6}\ \ \underline{7}\ \ \underline{8}\ \ \underline{4} \rightarrow$ លេខគូមាន4 គឺ 2,4,6 និង8

- ខ្ទង់ទី១មាន6 លេខ
- ខ្ទង់ទី២មាន7 លេខ
- ខ្ទង់ទី៣មាន8 លេខ
- ខ្ទង់ទី៤មាន4 លេខ

តាមគោលការណ៍គ្រឹះនៃរាប់

គេបាន $n(A)=6\times7\times8\times4$

ចំនួនករណីអាច $n(S)=9\times8\times7\times6$ ព្រោះ $\underbrace{\underline{9}\ \ \underline{8}\ \ \underline{7}\ \ \underline{6}}_{4\text{ ខ្ទង់}}$

នាំឱ្យ $P(A)=\dfrac{6\times7\times8\times4}{9\times8\times7\times6}=\dfrac{4}{9}$

ដូចនេះ $P(A)=\dfrac{4}{9}$ ។

**១២**. គេហូតយកបៀ ២សន្លឹកដោយចៃដន្យពីក្នុងបៀមួយហ៊ូដែលមាន ៥២សន្លឹក ។ គណនាប្រូបាបដើម្បីឱ្យគេហូតបាន :

**ក**. ជួងទាំងពីរសន្លឹក

**ខ**. ជួងមួយសន្លឹក និងកឺមួយសន្លឹក ។

**ចម្លើយ**

គណនាប្រូបាបដើម្បីហូតបាន

**ក**. ជួងទាំងពីរសន្លឹក

តាង $A$ ជាព្រឹត្តិការណ៍ហូតបានជួងទាំងពីរសន្លឹក

ចំនួនករណីស្រប $n(A)=C_{13}^{2}=\dfrac{12\times13}{2}=48$

ចំនួនករណីស្រប $n(S)=C_{52}^{2}=\dfrac{51\times52}{2}=1326$

នាំឱ្យ $P(A)=\frac{48}{1326}=0.036$

ដូចនេះ $P(A)=0.036$ ។

**ខ.** ជួងមួយសន្លឹកនិង កឺមួយសន្លឹក

តាង $B$ ជាព្រឹត្តិការណ៍នេះ

- ចំនួនករណីស្រប $n(B)=\frac{169}{1326}=0.127$

**ដូចនេះ** $P(B)=0.127$ ។

**១៣**. ក្នុងប្រអប់មួយមានកាត ១០សន្លឹក ដែលចុះលេខរៀងគ្នាពី ១ ដល់ ១០ ។ គេលូកយកកាត ២ សន្លឹកចេញពីក្នុងប្រអប់ដោយចៃដន្យ ។ រកប្រូបាប $P$ ដើម្បីឱ្យផលបូកលេខនៃកាតទាំងពីរជាចំនួនសេសបើ ៖

ក. កាតទាំងពីរសន្លឹកយកព្រមគ្នា ។

ខ. កាតទាំងពីរសន្លឹកយកម្តងមួយៗ ដោយមិនដាក់ចូលវិញ ។

គ កាតទាំងពីរសន្លឹកយកម្តងមួយៗ ដោយដាក់ចូលវិញ ។

**ចម្លើយ**

រកប្រូបាបដើម្បីឱ្យផលបូកលេខនៃកាតទាំងពីរជាចំនួនសេសបើ ៖

**ក.** កាតទាំងពីរសន្លឹកយកព្រមគ្នា

*ចំណាំ* ៖ លេខពី 1 ដប់10 មានសេស5 និងគូ5 ហើយដើម្បីឱ្យផលបូកលេខកាតជាចំនួនសេសលុះត្រាតែយកបានគូមួយ និងសេសមួយ ។

*របៀបទី១៖*

តាង $A$ ជាព្រឹត្តិការណ៍ហួតបានកាតពីរដែលមានផលបូកជាចំនួនសេស

- ចំនួនករណីស្រប $n(A)=C_5^1\times C_5^1=5\times 5=25$
- ចំនួនករណីអាច $n(S)=C_{10}^2=45$

នាំឱ្យ $P(A)=\frac{25}{45}=\frac{5}{9}$

**ដូចនេះ** $P(A)=\frac{5}{9}$

*របៀបទី២៖*

តាង $A$ ជាព្រឹត្តិការណ៍នេះ មានន័យថាយកបានសេសមួយ និងគូមួយ ឬគូមួយ និងសេសមួយ

នាំឱ្យ $P(A)=\frac{5}{10}\times\frac{5}{9}+\frac{5}{10}\times\frac{5}{9}=\frac{50}{90}=\frac{5}{9}$

ដូចនេះ $P(A)=\frac{5}{9}$

**ខ.** កាតទាំងពីរសន្លឹកយកម្តងមួយៗដោយមិនដាក់ចូលវិញ

តាង $B$ ជាព្រឹត្តិការណ៍យកកាតទាំងពីរបានផលបូកជាចំនួនសេស ដោយយកម្តងមួយៗមិនដាក់ចូលវិញ មានន័យថា យកបានសេសមួយ និងគូមួយ ឬគូមួយ និងសេសមួយ

នាំឱ្យ $P(B)=\frac{5}{10}\times\frac{5}{9}+\frac{5}{10}\times\frac{5}{9}=\frac{5}{9}$

ដូចនេះ $P(B)=\frac{5}{9}$

**គ.** កាតទាំពីរសន្លឹកយកម្តងមួយៗ ដោយដាក់ចូលវិញ

តាង $C$ ជាព្រឹត្តិការណ៍នេះ ដោយយកម្តងមួយៗ ហើយដាក់ចូលវិញមានន័យថាយកបានសេសមួយ និងគូមួយ គូមួយ និងសេសមួយ

នាំឱ្យ $P(C)=\frac{5}{10}\times\frac{5}{10}+\frac{5}{10}\times\frac{5}{10}=\frac{50}{100}=\frac{1}{2}$

ដូចនេះ $P(C)=\frac{1}{2}$

**១៤**. គេហូតយកបៀ ៣សន្លឹកចេញពីបៀក្នុងហ៊ូបៀដែលមាន ៥២សន្លឹកដោយចៃដន្យ ។

ក. រកប្រូបាបដើម្បីឱ្យគេហូតបានសន្លឹកបៀតែមួយទឹក ។

ខ. រកប្រូបាបដើម្បីឱ្យគេហូតបានសន្លឹកអាត់យ៉ាងតិចពីរសន្លឹក ។

**ចម្លើយ**

**ក.** រកប្រូបាបដើម្បីឱ្យគេហូតបានសន្លឹកបៀតែមួយតឹក

*របៀបទី១៖*

តាង $A$ ជាព្រឹត្តិការណ៍ហូតបានសន្លឹកបៀតែមួយតឹក មានន័យថាបានការ៉ូទាំងបី ឬកឺទាំងបី ឬជួងទាំងបី ឬភិចទាំងបី

គេបាន $P(A)=\frac{13}{52}\times\frac{12}{51}\times\frac{11}{50}+\frac{13}{52}\times\frac{12}{51}\times\frac{11}{50}+\frac{13}{52}\times\frac{12}{51}\times\frac{11}{50}+\frac{13}{52}\times\frac{12}{51}\times\frac{11}{50}$

$$= 4\times\frac{13}{52}\times\frac{12}{51}\times\frac{11}{50} = \frac{6\times 11}{51\times 25} = \frac{66}{1275} = 0.051$$

**ដូចនេះ** $P(A) = 0.051$

*របៀបទី២៖*

តាង $A$ ជាព្រឹត្តិការណ៍នេះ

- ចំនួនករណីស្រប $n(A) = 4C_{13}^{3} = 4\times\frac{13\times 12\times 11}{3!}$ មានលេខ4 ព្រោះហូតបានតឹកតែមួយ អាចហូតបានកឺទាំងបី ឬជួងទាំងបី ឬភិចទាំងបី ឬការ៉ូទាំងបី
- ចំនួនករណីអាច $n(S) = C_{52}^{3} = \frac{52\times 51\times 50}{3!}$

នាំឱ្យ $P(A) = \frac{4\times 13\times 12\times 11}{52\times 51\times 50} = 0.051$

**ដូចនេះ** $P(A) = 0.051$

**ខ.** រកប្រូបាបដើម្បីឱ្យគេហូតបានសន្លឹកអាត់យ៉ាងតិចពីរសន្លឹក

តាង $B$ ជាព្រឹត្តិការណ៍ហូតបានសន្លឹកអាត់យ៉ាងតិចពីរសន្លឹក មានន័យថាបានអាត់ពីរសន្លឹក ឬបានអាត់ទាំងបីសន្លឹក

* ចំនួនករណីស្រប $n(B) = C_4^2\times C_{48}^1 + C_4^3$
  $= 6\times 48 + 4$
  $= 292$
* ចំនួនករណីអាច $n(S) = C_{52}^{3} = 22100$

នាំឱ្យ $P(B) = \frac{292}{22100} = 0.013$

**ដូចនេះ** $P(B) = 0.013$

**១៥**. ក្នុងប្រអប់មួយមានអំពូលភ្លើងចំនួន ១៥ ក្នុងនោះមានអំពូលខូច(មិនឆេះ) ចំនួន ៥ ។ គេយកអំពូលភ្លើង ៣ចេញពីប្រអប់ដោយចៃដន្យ ។

ក. រកប្រូបាបដែលគេចាប់បានអំពូលល្អទាំង៣

ខ. រកប្រូបាបដែលគេចាប់បានអំពូលខូចតែ១

គ. រកប្រូបាបដែលគេចាប់បានអំពូលខូច មួយយ៉ាងតិច ។

**ចម្លើយ**

**ក**. រកប្រូបាបគេចាប់បានអំពូលល្អទាំងបី

អំពូលសរុប15មានខូច5ហើយចាប់យក3

តាង $D$ ជាព្រឹត្តិការណ៍ចាប់បានអំពូលល្អទាំងបី

- ចំនួនករណីស្រប $n(D)=C_{10}^{3}=\frac{10\times 9\times 8}{6}=120$
- ចំនួនករណីអាច $n(S)=C_{15}^{3}=\frac{15\times 14\times 13}{6}=455$

នាំឱ្យ $P(D)=\frac{120}{455}=0.26$

ដូចនេះ $P(D)=0.26$

**ខ**. រកប្រូបាបដែលគេចាប់បានអំពូលខូចតែមួយ

តាង $E$ ជាព្រឹត្តិការណ៍នេះ មានន័យថាបានអំពូលខូច 1 និងល្អ2

- ចំនួនករណីស្រប $n(E)=C_{5}^{1}\times C_{10}^{2}=5\times\frac{10\times 9}{2}=225$

នាំឱ្យ $P(E)=\frac{225}{455}=0.49$

ដូចនេះ $P(E)=0.49$

**គ**. រកប្រូបាបដែលគេចាប់បានអំពូលខូចយ៉ាងតិចមួយ

តាង $F$ ជាព្រឹត្តិការណ៍ចាប់បានអំពូលខូចយ៉ាងតិចមួយ

គេបាន $P(F)=1-P(D)$

$=1-0.26$

$=0.74$

ដូចនេះ $P(F)=0.74$

**១៦**. ក្នុងថង់មួយមានប៊ូលពណ៌ក្រហម4 ខ្មៅ5 និងពណ៌ស6 ។គេទាញយកប៊ូល2 ព្រមគ្នាពីក្នុងថង់ដោយចៃដន្យ។រកប្រូបាបដែល

ក. ប៊ូលក្រហមយ៉ាងតិចមួយត្រូវគេទាញចេញ។

ខ. ប៊ូលដែលគេទាញចេញមានពណ៌ខុសគ្នា។

**ចម្លើយ**

រកប្រូបាបដែល

**ក**. ប៊ូលក្រហមយ៉ាងតិចមួយត្រូវគេទាញចេញ

តាង $A$ ជាព្រឹត្តិការណ៍ប៊ូលក្រហមយ៉ាងតិចមួយត្រូវគេទាញចេញ

ដោយក្នុងថង់មានប៊ូល15 ហើយគេទាញប៊ូល2 ព្រមគ្នានោះករណីដែលអាចកើតឡើងគឺ

$$n(s)=C(15,2)=\frac{15!}{13!\times 2!}=105$$

ហើយប៊ូលក្រហមយ៉ាងតិចមួយត្រូវគេទាញចេញនោះករណីស្របដែលកើតឡើងគឺ

$$n(A)=C(4,1)\times C(11,1)+C(4,2)=(\frac{4!}{3!\times 1!}\times\frac{11!}{10!\times 1!})+\frac{4!}{2!\times 2!}=(4\times 11)+6=50$$

ដូចនេះ $P(A)=\frac{n(s)}{n(A)}=\frac{50}{105}=\frac{10}{21}$

**ខ**. ប៊ូលដែលគេទាញចេញមានពណ៌ខុសគ្នា

តាង $B$ ជាព្រឹត្តិការណ៍ប៊ូលដែលគេទាញចេញមានពណ៌ខុសគ្នា

នោះប៊ូលដែលទាញចេញអាចជាប៊ូលពណ៌ក្រហមនិងស រឺក្រហមនិងខ្មៅ រឺសនិងខ្មៅ

$$\Rightarrow n(B)=C(4,1)\times C(6,1)+C(4,1)\times C(5,1)+C(5,1)\times C(6,1)=(4\times 6)+(4\times 5)+(5\times 6)=24+20+30=74$$

$$\Rightarrow P(B)=\frac{74}{105}$$

ដូចនេះ $P(B)=\frac{74}{105}$

**១៧**. នៅក្នុងប្រអប់មួយមានប៊ូល 12 ដែលគេសរសេរពី 1 លេខដល់ 5។ គេចាប់យកប៊ូល 3 ចេញពីក្នុងប្រអប់ដោយចៃដន្យ។ រកប្រូបាបនៃព្រឹត្តិការណ៍ខាងក្រោម៖

ក. គេចាប់បានប៊ូលទាំង 3 លេខសុទ្ធតែចែកដាច់និង 3។

ខ. គេចាប់បានប៊ូលតែមួយគត់ដែលលេខចែកដាច់និង 3។

គ. គេចាប់បានប៊ូលមានលេខតាមលំដាប់កើននៃស្វ៊ីតនព្វន្តដែលមានផលសងរួម $d=3$។

ឃ. គេចាប់បានប៊ូលមានលេខតាមលំដាប់បង្កើតបានស្វ៊ីតធរណីមាត្រដែលមានផលធៀបរួម $q=\frac{1}{2}$។

**ចម្លើយ**

រកប្រូបាបនៃព្រឹត្តិការណ៍

**ក.** គេចាប់បានប៊ូលទាំង 3 លេខសុទ្ធតែចែកដាច់និង 3

តាង $A$ ជាព្រឹត្តិការណ៍គេចាប់បានប៊ូលទាំង 3 លេខសុទ្ធតែចែកដាច់និង 3

ដោយ ក្នុងប្រអប់មានប៊ូលចំនួន 12 ចុះលេខ $\{1,2,3,4,5,6,7,8,9,10,11,12\}$ ហើយជ្រើសរើសយក 3 ដោយចៃដន្យ។

នោះគេបាន $n(s)=C(12,3)=\frac{12!}{8!\times 3!}=220$ ហើយពហុគុណនៃ 3 គឺ $\{3,6,9,12\}$

**ដូចនេះ** ប្រូបាបដែលប៊ូលទាំង 3 លេខសុទ្ធតែចែកដាច់និង 3 គឺ $P(A)=\frac{4}{220}=\frac{1}{55}$

**ខ.** គេចាប់បានប៊ូលតែមួយគត់ ដែលលេខចែកដាច់និង 3

តាង $B$ ជាព្រឹត្តិការណ៍ដែលគេចាប់បានប៊ូលតែមួយគត់ដែលលេខចែកដាច់និង 3

នោះគេបាន $n(B)=C(4,1)\times C(8,2)=\frac{4!}{3!\times 1!}\times\frac{8!}{6!\times 2!}=112$

**ដូចនេះ** ប្រូបាបដែលគេចាប់បានប៊ូលតែមួយគត់ដែលលេខចែកដាច់និង 3 គឺ $P(B)=\frac{112}{220}=\frac{28}{55}$

**គ.** គេចាប់បានប៊ូលមានលេខតាមលំដាប់កើននៃស្វ៊ីតនព្វន្តដែលមានផលសងរួម $d=3$

តាង $C$ ជាព្រឹត្តិការណ៍ដែលគេចាប់បានប៊ូលមានលេខតាមលំដាប់កើននៃស្វ៊ីតនព្វន្តដែលមានផលសងរួម $d=3$

ដោយ គេរៀបជាស្វ៊ីតកើនដែលមានផលសងរួម $d=3$ នោះ

គេបាន

$\{1,4,7\},\{2,5,8\},\{3,6,9\},\{4,7,10\},\{5,8,11\},\{6,9,12\}$

ដូចនេះ ប្រូបាបដែលគេចាប់បានប៊ូលមានលេខតាមលំដាប់កើននៃស្វីតនព្វន្តដែលមានផលសងរួម $d=3$ គឺ $P(C)=\frac{6}{220}=\frac{3}{110}$

**ឃ.** គេចាប់បានប៊ូលមានលេខតាមលំដាប់បង្កើតបានស្វីតធរណីមាត្រដែលមានផលធៀបរួម $q=\frac{1}{2}$

តាង $D$ ជាព្រឹត្តិការណ៍ដែលគេចាប់បានប៊ូលមានលេខតាមលំដាប់បង្កើតបានស្វីតធរណីមាត្រ ដែលមានផលធៀបរួម $q=\frac{1}{2}$ ហើយ $a,b,c$ ជាចំនួនតាមលំដាប់ស្វីតធរណីមាត្រ ដែលមានផលធៀបរួម $q=\frac{1}{2}$

នោះគេបាន $b=\frac{1}{2}a$ និង $c=\frac{1}{2}b=\frac{1}{4}a$

គេបាន $a,b,c$ ជាចំនួនគត់ធម្មជាតិដែលជាពហុគុណនៃ $4$ នោះ $a$ អាចយកតម្លៃ $4,8$ និង $12$ ។

យើងបានស្វីត $\{4,2,1\},\{8,4,2\},\{12,6,3\}$

ដូចនេះ ប្រូបាបដែលគេចាប់បានប៊ូលមានលេខតាមលំដាប់បង្កើតបានស្វីតធរណីមាត្រដែលមានផលធៀបរួម $q=\frac{1}{2}$ គឺ $P(D)=\frac{3}{220}$

**១៨**. គេឱ្យ $P(A)=\frac{1}{2}$ , $P(B)=\frac{7}{12}$ , $P(A/B)=\frac{3}{7}$ ។ គណនា $P(A\cup B)$ ។

**ចម្លើយ**

គណនា $P(A\cup B)$

គេមាន $P(A)=\frac{1}{2}$ , $P(B)=\frac{7}{12}$ , $P(A/B)=\frac{3}{7}$

គេបាន $P(A\cap B)=P(A/B)\times P(B)=\frac{3}{7}\times\frac{7}{12}=\frac{1}{4}$

នាំឱ្យ $P(A\cup B)=P(A)+P(B)-P(A\cap B)$

$$=\frac{1}{2}+\frac{7}{12}-\frac{1}{4}$$

$$=\frac{6}{12}+\frac{7}{`2}-\frac{3}{12}=\frac{5}{6}$$

ដូចនេះ $P(A\cup B)=\frac{5}{6}$

**១៩**. គេឱ្យ $P(A)=\frac{3}{5}$ , $P(B)=\frac{3}{10}$ និង $P(A\cup B)=\frac{7}{10}$ ។ គណនា $P(A/B)$ ។

**ចម្លើយ**

គណនា $P(A/B)$

គេមាន $P(A)=\frac{3}{5}$ , $P(B)=\frac{3}{10}$ , $P(A\cup B)=\frac{7}{10}$

គេបាន $P(A\cap B)=P(A)+P(B)-P(A\cup B)$

$$=\frac{3}{5}+\frac{3}{10}-\frac{7}{10}$$

$$=\frac{1}{5}$$

$P(A\cap B)=\frac{1}{5}$

នាំឱ្យ $P(A/B)=\frac{P(A\cap B)}{P(B)}=\frac{\frac{2}{10}}{\frac{3}{10}}=\frac{2}{3}$

ដូចនេះ $P(A/B)=\frac{2}{3}$

**២០**. ថង់មួយមានប៊ូលស3មានលេខខុសគ្នានិងប៊ូលខ្មៅ2មានលេខខុសគ្នា។ គេចាប់យកប៊ូលម្តងមួយៗចំនួន2ដងដោយចៃដន្យចេញពីក្នុងថង់ដោយដាក់ចូលវិញ។

តាង $A$ ជាព្រឹត្តិការណ៍ចាប់លើកទី1បានប៊ូលស

$B$ ជាព្រឹត្តិការណ៍ចាប់លើកទី2 បានប៊ូលខ្មៅ

ក. ចូររកប្រូបាបនៃព្រឹត្តិការណ៍ $A,B$ និង $A\cap B$ ។

ខ. តើព្រឹត្តិការណ៍ $A$ និង $B$ អាស្រ័យគ្នាឬទេ?

គ. គណនា $P(A/B)$ និង $P(B/A)$

**ចម្លើយ**

ដោយក្នុងថង់មានប៊ូលចំនួន 5 ហើយគេចាប់យកប៊ូលម្តងមួយៗចំនួន 2 ដង ដោយចែដន្យចេញពីក្នុងថង់ដោយដាក់ចូលវិញ។ នោះគេបាន លទ្ធផលនិមួយៗជាចម្លាស់ច្រំដែលនោះ គេបានលំហសំណាក $n(s)=5^2=25$ ។ គេចាប់លើកទី1បានប៊ូលសនោះ $n(A)=3^2=9$ ។ គេចាប់លើកទី2 បានប៊ូលខ្មៅនោះ $n(B)=2^2+3\times 2=10$ និងព្រឹត្តិការណ៍នៃ $n(A\cap B)=3\times 2=6$ ។

**ក.** រកប្រូបាបនៃព្រឹត្តិការណ៍ $A,B$ និង $A\cap B$

$$P(A)=\frac{15}{25}=\frac{3}{5}$$

$$P(B)=\frac{10}{25}=\frac{2}{5}$$

$$P(A\cap B)=\frac{6}{25}$$

**ខ.** តើព្រឹត្តិការណ៍ $A$ និង $B$ អាស្រ័យគ្នាឬទេ?

ដោយ $P(A)\times P(B)=\frac{3}{5}\times\frac{2}{5}=\frac{6}{25}$ និង $P(A\cap B)=\frac{6}{25}$

នោះគេបាន $P(A)\times P(B)=P(A\cap B)=\frac{6}{25}$

ដូចនេះ $A$ និង $B$ ជាព្រិត្តិការណ៍ទាក់ទងគ្នា

**គ.** គណនា $P(A/B)$ និង $P(B/A)$

$$P(A/B)=P(A)=\frac{3}{5}$$

$$P(B/A)=P(B)=\frac{2}{5}$$

**២១**. គេឱ្យ $P(A)=\frac{1}{3}$ , $P(A\cup B)=\frac{8}{15}$ និង $P(A\cap B)=\frac{1}{5}$ ។

ក. គណនា $P(B)$

ខ. $P(A'\cup B)$ ។

**ចម្លើយ**

គេមាន $P(A)=\frac{1}{3}$ , $P(A\cup B)=\frac{8}{15}$ , $P(A\cap B)=\frac{1}{5}$

**ក.** គណនា $P(B)$

គេមាន $P(A\cup B)=P(A)+P(B)-P(A\cap B)$

នាំឱ្យ $P(B)=P(A\cup B)+P(A\cap B)-P(A)$

$$=\frac{8}{15}+\frac{1}{5}-\frac{1}{3}$$

$$=\frac{8+3-5}{15}$$

$$=\frac{2}{5}$$

ដូចនេះ $P(B)=\frac{2}{5}$

**ខ.** គណនា $P(A'\cup B)$

គេមាន $P(A'\cup B)=P(A')+P(B)-P(A'\cap B)$

តែ $P(A')=1-P(A)=1-\frac{1}{3}=\frac{2}{3}$

ហើយ $P(A'\cap B)=P(B)-P(A\cap B)$

នាំឱ្យ $P(A'\cup B)=P(A')+P(B)-P(B)+P(A\cap B)$

$$=\frac{2}{3}+\frac{1}{5}=\frac{13}{15}$$

ដូចនេះ $P(A'\cup B)=\frac{13}{15}$




**២២.** បង្ហាញថាបើ $A$ និង $B$ ជាព្រឹត្តិកាណ៍ចៃដន្យ នោះគេបាន $P(A/B)=1-P(A'/B)$ ។

**ចម្លើយ**

បង្ហាញថាបើ $A$ និង $B$ ជាព្រឹត្តិការណ៍ចៃដន្យនោះ $P(A/B)=1-P(A'/B)$

រូបៈ




*របៀបទី១ៈ*

គេមាន $P(A/B)=\frac{P(A\cap B)}{P(B)}$

តែ $P(A\cap B)=P(B)-P(A'\cap B)$

នាំឱ្យ $P(A/B)=\dfrac{P(B)-P(A'\cap B)}{P(B)}$

$$=1-\frac{P(A'\cap B)}{P(B)}$$

$$=1-P(A'/B)$$

ដូចនេះ $P(A/B)=1-P(A'/B)$

របៀបទី២៖

គេមាន $P(A/B)=1-P(A'/B)$

$$\Leftrightarrow P(A/B)+P(A'/B)=1$$

$$\Leftrightarrow \frac{P(A\cap B)}{P(B)}+\frac{P(A'\cap B)}{P(B)}=1$$

$$\Leftrightarrow \frac{P(A\cap B)+P(A'\cap B)}{P(B)}=1$$

$\Leftrightarrow \dfrac{P(B)}{P(B)}=1$ ព្រោះ $B=(A'\cap B)\cup(A\cap B)\Rightarrow P(B)=P(A'\cap B)+P(A\cap B)$

$\Leftrightarrow 1=1$ ពិត

ដូចនេះ $P(A/B)=1-P(A'/B)$

**២៣**. ស្រាយបញ្ជាក់ថា ចំពោះព្រឹត្តិការណ៍ $A, B$ និង $C$ ដែល $A$ និង $B$ មិនចុះសំម្រុងគ្នា នោះ គេបាន $P(A\cup B/C)=P(A/C)+P(B/C)$ ។

**ចម្លើយ**

ស្រាយបញ្ជាក់ថា ចំពោះព្រឹត្តិការណ៍ $A,B$ និង $C$ ដែល $A$ មិនចុះសម្រុងគ្នា

គេបាន $P(A\cup B/C)=P(A/C)+P(B/C)$

គេមាន $P(A\cup B/C)=P\left[(A\cup B)/C\right]$

$$=\frac{P\left[(A\cup B)\cap C\right]}{P(C)}$$

$$=\frac{P\left[(A\cap C)\cup(B\cap C)\right]}{P(C)}$$

$$=\frac{P(A\cap C)+P(B\cap C)}{P(C)}$$
$$=\frac{P(A\cap C)}{P(C)}+\frac{P(B\cap C)}{P(C)}$$
$$=P(A/C)+P(B/C)$$

ដូចនេះ $P(A\cup B/C)=P(A/C)+P(B/C)$

**២៤**. $A$ និង $B$ ជាព្រឹត្តិការណ៍ចៃដន្យ ដែលផ្ទៀងផ្ទាត់លក្ខខណ្ឌ $P(A)=P(B)=\frac{1}{2}$ ។ ស្រាយបញ្ជាក់ថា $P(A\cap B)=P(A'\cap B')$ ។

**ចម្លើយ**

ស្រាយបញ្ជាក់ថា $P(A\cap B)=P(A'\cap B')$

គេមាន $P(A)=P(B)=\frac{1}{2}$

គេបាន $P(A')=P(B')=1-P(A)=1-\frac{1}{2}=\frac{1}{2}$

នាំឱ្យ $P(A\cap B)=P(A)\times P(B)$

$$=\frac{1}{2}\times\frac{1}{2}=\frac{1}{4} \qquad (1)$$

ហើយ $P(A'\cap B')=P(A')\times P(B')$

$$=\frac{1}{2}\times\frac{1}{2}=\frac{1}{4} \qquad (2)$$

តាម $(1)$ និង $(2)$ គេបាន $P(A\cap B)=P(A'\cap B')$

ដូចនេះ $P(A\cap B)=P(A'\cap B')$

**២៥**. គេមានប្រអប់៣ដូចគ្នា ។ ប្រអប់ទី $I$ មានផលិតផល ១០ដែលក្នុងនោះមានផលិតផលល្អ ៨។ ប្រអប់ទី $II$ មានផលិតផល ១៥ដែលក្នុងនោះមានផលិតផលល្អ ១២ , ប្រអប់ទី $III$ មានផលិតផល២០ ដែលក្នុងនោះមានផលិតផលល្អ ១៥ ។ គេយកប្រអប់មួយ រួចគេចាប់យកផលិតផលមួយពីក្នុងប្រអប់នោះដោយចៃដន្យ ។ គណនាប្រូបាបដើម្បីឱ្យគេចាប់បានផលិតផលល្អ ។

**ចម្លើយ**

គណនាប្រូបាប ដើម្បីឱ្យបានផលិតផលល្អ

គេបាន មែកប្រូបាបគឺ




តាង $A$ ជាព្រឹត្តិការណ៍យកបានផលិតផលល្អ

តាមមែកប្រូបាបខាងលើ យើងបាន ៖

$$P(A)=\frac{1}{3}\times\frac{8}{10}+\frac{1}{3}\times\frac{12}{15}+\frac{1}{3}\times\frac{15}{20}$$
$$=0.26+0.26+0.25$$
$$=0.77$$

ដូចនេះ $P(A)=0.77$

**២៦**. សៅ , សែន , សុខ ជាអ្នកប្រមាញ់ដៃត្រង់ខុសៗគ្នា ។ សៅដែលជាអ្នកដៃត្រង់ជាងគេ បាញ់ត្រូវ ៧គ្រាប់ក្នុង ១០គ្រាប់ សែនត្រូវ ៥ដង សុខដែលអន់ភ្នែក ១ដង ក្នុង១០គ្រាប់ ។ អ្នកប្រមាញ់ទាំងបីចេញដំណើរស្មើគ្នា បាញ់ស្មើគ្នា តម្រង់លើទន្សាយតែមួយ ។ គណនាប្រូបាបនៃព្រឹត្តិការណ៍ ខាងក្រោម ៖

ក. ទន្សាយនោះត្រូវគេបាញ់ត្រូវ

ខ. ទន្សាយត្រូវគេបាញ់ត្រូវ តែសុខបាញ់ខុស

គ. សុខតែម្នាក់ឯងបានបាញ់ត្រូវទន្សាយនោះ ។

សម្គាល់ ៖ គេសន្មត់ថាលទ្ធផលនៃអ្នកប្រមាញ់ទាំងបីមិនទាក់ទងគ្នាទេ ។

**ចម្លើយ**

គណនាប្រូបាបនៃព្រឹត្តិការណ៍ខាងក្រោម ៖

យើងបានមែកប្រូបាបនៃព្រឹត្តិការណ៍នេះគឺ




**ក.** គណនាប្រូបាបនៃព្រឹត្តិការណ៍ដែលទន្សាយត្រូវគេបាញ់ត្រូវ

តាង $A$ ព្រឹត្តិការណ៍ដែលទន្សាយត្រូវគេបាញ់ត្រូវ

តាមមែកប្រូបាបខាងលើ គេបាន $P(A)=\frac{1}{3}\times\frac{7}{10}+\frac{1}{3}\times\frac{5}{10}+\frac{1}{3}\times\frac{1}{10}=0.43$

**ដូចនេះ** $P(A)=0.43$

**ខ.** គណនាប្រូបាបនៃព្រឹត្តិការណ៍ដែលទន្សាយត្រូវគេបាញ់ត្រូវ តែសុខបាញ់ខុស

តាង $B$ ព្រឹត្តិការណ៍ដែលទន្សាយត្រូវគេបាញ់ត្រូវ តែសុខបាញ់ខុស

តាមមែកប្រូបាបខាងលើ គេបាន $P(B)=\frac{1}{3}\times\frac{7}{10}+\frac{1}{3}\times\frac{5}{10}+\frac{1}{3}\times\frac{9}{10}=0.69$

**ដូចនេះ** $P(B)=0.69$

**គ.** រកប្រូបាបនៃព្រឹត្តិការណ៍សុខតែម្នាក់ឯងបាញ់ត្រូវទន្សាយ

តាង $C$ ព្រឹត្តិការណ៍សុខតែម្នាក់ឯងបាញ់ត្រូវទន្សាយ

តាមមែកប្រូបាបខាងលើ គេបាន $P(C)=\frac{1}{3}\times\frac{3}{10}+\frac{1}{3}\times\frac{5}{10}+\frac{1}{3}\times\frac{1}{10}=0.3$

**ដូចនេះ** $P(C)=0.3$

**២៧**. គេមានម៉ាស៊ីន $A,B$ និង $C$ ផលិតវត្ថុដូចគ្នា។ ម៉ាស៊ីន $A$ ផលិតបាន 50%, $B$ ផលិតបាន 30% និង $C$ ផលិតបាន 20% ។ គេដឹងថាវត្ថុដែលផលិតដោយម៉ាស៊ីន $A$ មានខូច 3%,ម៉ាស៊ីន $B$ មានខូច 4% និង ម៉ាស៊ីន $C$ មានខូច 4% ។

ក. រកប្រូបាបដែលមានវត្ថុខូច។

ខ. ក្នុងចំណោមវត្ថុ 1000 តើម៉ាស៊ីន $A$ ធ្វើខូចចំនួនប៉ុន្មាន?ម៉ាស៊ីន $B$ ធ្វើខូចចំនួនប៉ុន្មាន? ម៉ាស៊ីន $C$ ធ្វើខូចចំនួនប៉ុន្មាន?

**ចម្លើយ**

តាង $A$ ជាព្រឹត្តិការណ៍ដែលម៉ាស៊ីន $A$ ផលិតវត្ថុ

$B$ ជាព្រឹត្តិការណ៍ដែលម៉ាស៊ីន $B$ ផលិតវត្ថុ

$C$ ជាព្រឹត្តិការណ៍ដែលម៉ាស៊ីន $C$ ផលិតវត្ថុ

$D$ ជាព្រឹត្តិការណ៍ដែលម៉ាស៊ីនផលិតវត្ថុខូច

**ក.** រកប្រូបាបដែលមានវត្ថុខូច

- រកប្រូបាបដែលមានវត្ថុខូចផលិតដោយម៉ាស៊ីន $A$

$P(A\cap D)=P(A)\times P(D/A)$

$P(D/A)=3\%=0.03$, $P(A)=50\%=0.5$

$\Rightarrow P(A\cap D)=0.5\times 0.03=0.015$

❖ រកប្រូបាបដែលមានវត្ថុខូចផលិតដោយម៉ាស៊ីន $B$

$P(B\cap D)=P(B)\times P(D/B)$

$P(D/B)=4\%=0.04$, $P(B)=30\%=0.3$

$\Rightarrow P(B\cap D)=0.3\times 0.04=0.012$

❖ រកប្រូបាបដែលមានវត្ថុខូចផលិតដោយម៉ាស៊ីន $C$

$P(C\cap D)=P(C)\times P(D/C)$

$P(D/C)=4\%=0.04$, $P(C)=20\%=0.2$

$\Rightarrow P(C\cap D)=0.2\times 0.04=0.008$

នោះគេបាន ប្រូបាបដែលមានវត្ថុខូចគឺ

$$P(D)=P(A\cap D)+P(B\cap D)+P(C\cap D)$$
$$=0.015+0.012+0.008$$
$$=0.035$$

**ខ.** ក្នុងចំណោមវត្ថុ 1000 តើម៉ាស៊ីន $A$ ធ្វើខូចចំនួនប៉ុន្មាន?ម៉ាស៊ីន $B$ ធ្វើខូចចំនួនប៉ុន្មាន?ម៉ាស៊ីន $C$ ធ្វើខូចចំនួនប៉ុន្មាន?

❖ រកចំនួនវត្ថុខូចដោយដឹងថាផលិតដោយម៉ាស៊ីន $A$

តាមទ្រឹស្តីបទបាយ៉េសគេបាន

$$P(A/D)=\frac{P(D/A)\times P(A)}{P(D)}$$
$$=\frac{0.03\times 0.5}{0.035}$$
$$=0.428$$

នោះគេបានម៉ាស៊ីន $A$ ធ្វើខូចចំនួន $1000\times 0.428=428$

❖ រកចំនួនវត្ថុខូចដោយដឹងថាផលិតដោយម៉ាស៊ីន $B$

តាមទ្រឹស្តីបទបាយ៉េសគេបាន

$$P(B/D)=\frac{P(D/B)\times P(B)}{P(D)}$$
$$=\frac{0.04\times 0.3}{0.035}=0.34$$

នោះគេបាន ម៉ាស៊ីន $B$ ធ្វើខូចចំនួន $1000\times0.343=343$

❖ រកចំនួនវត្ថុខូចដោយដឹងថាផលិតដោយម៉ាស៊ីន $C$

តាមទ្រឹស្តីបទបាយ៉េសគេបាន

$$P(C/D)=\frac{P(D/C)\times P(C)}{P(D)}$$

$$=\frac{0.04\times0.2}{0.035}$$

$$=0.229$$

នោះគេបាន ម៉ាស៊ីន $C$ ធ្វើខូចចំនួន $1000\times0.229=229$

**២៨**. នៅក្នុងការចុះស្រង់ទិន្នន័យស្តីពីអ្នកកើតជម្ងឺគ្រុនចាញ់នៅប្រទេសកម្ពុជាបានអោយដឹងថា មនុស្សប្រុសកើតជម្ងឺដែលជាក្មេងមាន $5\%$ វ័យជំទង់មាន $7.5\%$ និង មនុស្សចាស់មាន $10\%$ ។ គេដឹងថា ក្នុងចំណោមមនុស្សប្រុសទាំងអស់មានក្មេង $30\%$ វ័យជំទង់ $25\%$ និង មនុស្សចាស់ $45\%$ ។

តើមនុស្សប្រុសនៅកម្ពុជាប៉ុន្មានភាគរយកើតជម្ងឺគ្រុនចាញ់?

**ចម្លើយ**

រកចំនួនមនុស្សប្រុសនៅកម្ពុជាដែលកើតជម្ងឺគ្រុនចាញ់

តាង $B$ ជាព្រឹត្តិការណ៍មនុស្សកើតជម្ងឺគ្រុនចាញ់

$A_1$ ជាព្រឹត្តិការណ៍នៃក្មេងប្រុស $\Rightarrow P(A_1)=30\%=0.3$

$A_2$ ជាព្រឹត្តិការណ៍នៃវ័យជំទង់ $\Rightarrow P(A_2)=25\%=0.25$

$A_3$ ជាព្រឹត្តិការណ៍នៃមនុស្សចាស់ $\Rightarrow P(A_3)=45\%=0.45$

ដោយ $P(A_1)+P(A_2)+P(A_3)=0.3+0.25+0.45=1$ ដែលព្រឹត្តិការណ៍ $A_1, A_2, A$ ជាបំណែកនៃសំណុំព្រឹត្តិការណ៍មនុស្សប្រុស។ ម្យ៉ាងទៀតមនុស្សប្រុសកើតជម្ងឺដែលជាក្មេងមាន $5\%$ វ័យជំទង់មាន $7.5\%$ និង មនុស្សចាស់មាន $10\%$

$\Rightarrow P(B/A_1)=0.05$

$P(B/A_2)=0.075$

$P(B/A_3)=0.1$

$$\Rightarrow P(B)=P(B/A_1)\times P(A_1)+P(B/A_2)\times P(A_2)+P(B/A_3)\times P(A_3)$$

$$=(0.05\times0.3)+(0.075\times0.25)+(0.1\times0.45)$$

$$=0.07875$$

$$=7.875\%$$

ដូចនេះ មនុស្សប្រុសកើតជម្ងឺមាន 7.875%

**២៩**. ប្រូបាបដែលជើងយន្តហោះមួយចេញដំណើរទាន់ពេលកំណត់គឺ $P(D)=0.83$ ប្រូបាបដែលវាមកទាន់ពេលកំណត់ គឺ $P(A)=0.82$ និង ប្រូបាបដែលវាចេញដំណើរ និង មកទាន់ពេលកំណត់គឺ $P(A\cap D)=0.78$ ។ រកប្រូបាបដែលយន្តហោះ ៖

ក. មកទាន់ពេលកំណត់ក្នុងលក្ខខណ្ឌដែលវាចេញដំណើរទាន់ពេលកំណត់។

ខ. ចេញដំណើរទាន់ពេលក្នុងលក្ខខណ្ឌដែលវាមកទាន់ពេលកំណត់។

**ចម្លើយ**

រកប្រូបាប

បម្រាប់ $P(D)=0.83$, $P(A)=0.82$, $P(A\cap D)=0.78$

**ក.** មកទាន់ពេលកំណត់ក្នុងលក្ខខណ្ឌដែលវាចេញដំណើរទាន់ពេលកំណត់

ប្រូបាបនៃ $A$ ក្រោមលក្ខខណ្ឌ $D$ កំណត់ដោយ

$$P(A/D)=\frac{P(A\cap D)}{P(D)}$$

$$=\frac{0.78}{0.83}=0.94$$

**ខ.** ចេញដំណើរទាន់ពេលក្នុងលក្ខខណ្ឌដែលវាមកទាន់ពេលកំណត់

ប្រូបាបនៃ $D$ ក្រោមលក្ខខណ្ឌ $A$ កំណត់ដោយ

$$P(D/A)=\frac{P(A\cap D)}{P(A)}=\frac{0.78}{0.82}=0.95$$

**៣០**. រោងចក្រ បីផលិតម្ជូបកំប៉ុង ។ រោងចក្រទី1 ទី2 ទី3 ផលិតបាន ២៥% , ៣៥% , ៤០% នៃផលិតផលម្ជូបកំប៉ុងសរុប ដែលស្តុកទុកក្នុងឃ្លាំងមួយ ។ អត្រាម្ជូបកំប៉ុងខូចរបស់រោងចក្រទាំង៣ ស្មើរៀងគ្នានឹង ២% , ១% , ១.៥% ។ គេយកម្ជូបកំប៉ុងមួយកំប៉ុងពីឃ្លាំង ។

ក. គណនាប្រូបាប ដើម្បីឱ្យគេយកបានម្ជូបកំប៉ុងដែលខូចគុណភាព

ខ. បើគេយកម្ជូបកំប៉ុងខូចគុណភាព ។ តាមគំនិតរបស់អ្នក តើម្ជូបកំប៉ុងដែលខូច គុណភាពនេះជារបស់រោងចក្រមួយណា ?

**ចម្លើយ**

យើងបាន មែកប្រូបាបនៃការផលិតម្ជូបកំប៉ុងគឺ




**ក.** គណនាប្រូបាប ដើម្បីឱ្យគេយកបានម្ជូបកំប៉ុងដែលខូចគុណភាព

តាង $A$ ព្រឹត្តិការណ៍យកបានម្ជូបកំប៉ុងដែលខូចគុណភាព

តាមមែកប្រូបាប គេបាន

$$P(A) = 25\% \times 2\% + 35\% \times 1\% + 40\% \times 1.5\%$$
$$= \frac{25}{100} \times \frac{2}{100} + \frac{35}{100} \times \frac{1}{100} + \frac{40}{100} \times \frac{15}{100}$$
$$= 0.0145$$

**ដូចនេះ** $P(A) = 0.0145$

**ខ.** តាមគំនិតខ្ញុំ ម្ជូបកំប៉ុងដែលខូចគុណភាព ជារបស់រោងចក្រទី៣ ព្រោះភាគរយនៃការខូចរបស់រោងចក្រទី៣មាន 0.6% ធំជាងភាគរយនៃការខូចរបស់រោងចក្រទី១ និងទី២មាន 0.5% និង 0.35% ។

**៣១**. រោងចក្រពីរផលិតអំពូលអគ្គីសនី 220$V$ ដូចគ្នា ។ ទិន្នផលនៃរោងចក្រទី $II$ ស្មើនឹង៣ដង ទិន្នផលរោងចក្រទី $I$ ។ អត្រាខូចរបស់អំពូលដែលផលិតដោយរោងចក្រទី $I$ និងទី $II$ គឺ 0,1% និង 0.2% ។ ឧបមាថា អំពូលដែលដាក់លក់នៅលើទីផ្សារ ជាអំពូលដែលផលិតដោយ រោងចក្រទាំងពីរនេះ ។ គេទិញអំពូលមួយដោយចៃដន្យ ។

ក. គណនាប្រូបាបដែលនាំឱ្យគេទិញប៉ះអំពូលខូច

ខ. ប្រសិនបើគេទិញប៉ះអំពូលខូច តាមយោបល់របស់អ្នក តើអំពូលខូចនេះជាផលិតផលរបស់រោងចក្រមួយណា ?

**ចម្លើយ**

មែកប្រូបាបនៃព្រឹត្តិការណ៍ ផលិតអំពូលអគ្គីសនី របស់រោងចក្រទាំងពីរ គឺ




**ក**. គណនាប្រូបាប ដែលនាំឱ្យទិញប៉ះអំពូលខូច

តាង $A$ ព្រឹត្តិការណ៍ ទិញប៉ះអំពូលខូច

តាមមែកប្រូបាប គេបាន

$$P(A) = 25\% \times 0.1\% + 75\% \times 0.2\%$$
$$= 0.00025 + 0.0015$$
$$= 0.00175$$

**ដូចនេះ** $P(A) = 0.00175$

**ខ**. តាមយោបល់ខ្ញុំ ប្រសិនបើគេទិញប៉ះអំពូលខូចអំពូលខូច នោះជាផលិតផលរបស់រោងចក្រទី $II$ ព្រោះភាគរយខូចរបស់រោងចក្រទី $II$ មាន 0.15% ច្រើនជាងភាគរយខូចរបស់រោងចក្រទី $I$ មាន 0.025% ។

**៣២**. សុខ និង សៅ ចូលសម្ភាសន៍ ដើម្បីជ្រើសរើសកន្លែងធ្វើការពីកន្លែងដែលមានមុខតំណែងដូចគ្នា ។ ប្រូបាបដែលជ្រើសរើសសុខ គឺ $\frac{1}{7}$ និងប្រូបាបដែលជ្រើសរើសសៅ មាន$\frac{1}{5}$។

រកប្រូបាបដែល ៖

ក. អ្នកទាំងពីរនឹងត្រូវជ្រើសរើស

ខ. តែម្នាក់គត់ចំណោមពីរនាក់នឹងត្រូវជ្រើសរើស ។

គ. គ្មាននណាម្នាក់ ចំណោមពីរនាក់នឹងត្រូវជ្រើសរើស ។

ឃ. យ៉ាងតិចម្នាក់ក្នុងចំណោមពីរនាក់ នឹងត្រូវជ្រើសរើស

**ចម្លើយ**

រកប្រូបាបដែល

**ក.** អ្នកទាំងពីរនឹងត្រូវជ្រើសរើស

យើងមាន ប្រូបាបដែលជ្រើសរើសសុខគឺ $\frac{1}{7}$

ប្រូបាបដែលជ្រើសរើសសៅគឺ$\frac{1}{5}$

តាង $A$ ព្រឹត្តិការណ៍ដែលសុខនិងសៅត្រូវបានជ្រើសរើស

យើងបាន ប្រូបាបដែលអ្នកទាំងពីរត្រូវបានជ្រើសរើសគឺ $P(A)=\frac{1}{7}\times\frac{1}{5}=\frac{1}{35}=0.028$

**ដូចនេះ** $P(A)=0.028$

**ខ.** តែម្នាក់ ក្នុងចំណោមអ្នកទាំងពីរ ត្រូវជ្រើសរើស

តាង $B$ ព្រឹត្តិការណ៍ដែលម្នាក់ក្នុងចំណោមអ្នកទាំងពីរ ត្រូវជ្រើសរើស

យើងបាន បើគេជ្រើសរើសម្នាក់ នោះអាចជ្រើសរើសសុខ ឬសៅ ។

-បើរើសសុខ នោះសៅមិនត្រូវបានរើស

-បើរើសសៅ នោះសុខមិនត្រូវបានរើស

ដោយ ប្រូបាបជ្រើសរើសសុខ $\frac{1}{7}$ នោះប្រូបាបមិនជ្រើសរើសសុខមាន $1-\frac{1}{7}=\frac{6}{7}$

តែ ប្រូបាបជ្រើសរើសសៅ$\frac{1}{5}$ នោះប្រូបាបមិនជ្រើសរើសសៅមាន $1-\frac{1}{5}=\frac{4}{5}$

នាំឱ្យ $P(B)=\frac{1}{7}\times\frac{4}{5}+\frac{1}{5}\times\frac{6}{7}=0.28$

ដូចនេះ $P(B)=0.28$

**គ.** គ្មានអ្នកណាម្នាក់ នឹងត្រូវជ្រើសរើស

តាង $C$ ព្រឹត្តិការណ៍គ្មានអ្នកណាម្នាក់ នឹងត្រូវជ្រើសរើស

បើគ្មានអ្នកណាម្នាក់ នឹងត្រូវជ្រើសរើសនោះ សុខ និងសៅនឹងមិនត្រូវមានគេជ្រើសរើស

នាំឱ្យ $P(C)=\frac{6}{7}\times\frac{4}{5}=0.685$

ដូចនេះ $P(C)=0.685$

**ឃ.** យ៉ាងតិចម្នាក់ក្នុងចំណោមពីរនាក់ នឹងត្រូវជ្រើសរើស

តាង $D$ ព្រឹត្តិការណ៍យ៉ាងតិចម្នាក់ក្នុងចំណោមពីរនាក់ នឹងត្រូវជ្រើសរើស

គេបាន $D$ ព្រឹត្តិការណ៍ផ្ទុយពីព្រឹត្តិការណ៍ $C$

នាំឱ្យ $P(D)=1-P(C)$

$=1-0.685$

$=0.315$

ដូចនេះ $P(D)=0.315$

**៣៣.** ក្នុងប្រអប់ $A, B$ និង $C$ មានបាល់ពណ៌ស និងបាល់ពណ៌ខ្មៅ ។ ប្រអប់ $A$ មានបាល់ពណ៌ស ២ និង បាល់ពណ៌ខ្មៅ ៣ ហើយ ប្រអប់ $B$ មានបាល់ពណ៌ស ១ និងបាល់ពណ៌ខ្មៅ ៤ និង ប្រអប់ $C$ មានបាល់ពណ៌កស ៣ និង បាល់ពណ៌ខ្មៅ១ ។ យើងរើសប្រអប់មួយដោយ ចៃដន្យ ហើយចេញពីប្រអប់នេះ យើងរើសយកបាល់មួយ ។ ឧបមាថា យកបានបាល់ពណ៌ស ។

រកប្រូបាបដែលបាល់ចេញពីប្រអប់ $A$ ។

**ចម្លើយ**

តាង $W$ ជាបាល់ពណ៌ស

| ប្រអប់ $A$ | ប្រអប់ $B$ | ប្រអប់ $C$ |
|---|---|---|
| ●●●○○ | ●●●●○ | ○○○● |

យើងបាន $P(A)=P(B)=P(C)=\frac{1}{3}$ និង $P(W/A)=\frac{2}{5}$ , $P(W/B)=\frac{1}{5}$ , $P(W/C)=\frac{3}{4}$

ដូចនេះ តាមរូបមន្ត *Bayes* គឺ $P(A/W)=\dfrac{P(A).P(W/A)}{P(A).P(W/A)+P(B).P(W/B)+P(C).P(W/C)}$

$$=\frac{\frac{1}{3}\times\frac{2}{5}}{\frac{1}{3}\times\frac{2}{5}+\frac{1}{3}\times\frac{1}{5}+\frac{1}{3}\times\frac{3}{4}}=\frac{8}{27}$$

ដូចនេះ $P(A/W)=\dfrac{8}{27}$

**៣៤**. តើគេត្រូវទំលាក់គ្រាប់ឡុកឡាក់យ៉ាងតិចប៉ុន្មានដើម្បីអោយប្រូបាបមានយ៉ាងតិចគ្រាប់ឡុកឡាក់មួយចេញលេខ $6$ ធំជាងឬស្មើ $0.9$ ?

**ចម្លើយ**

ចំនួនគ្រាប់ឡុកឡាក់ដែលត្រូវទំលាក់

តាង $n$ ជាចំនួនគ្រាប់ឡុកឡាក់ដែលត្រូវទំលាក់ $(n\in IN)$

$A=$ "មានយ៉ាងតិចគ្រាប់ឡុកឡាក់មួយចេញលេខ $6$"

$A_i=$ "គ្រាប់ឡុកឡាក់ទី $i$ ចេញលេខ $6$" $(i=\overline{1,n})$

$\overline{A}$ និង $\overline{A_i}$ ជាព្រឹត្តិការណ៍ផ្ទុយរបស់ $A$ និង $A_i$

$\Rightarrow \overline{A}=\bigcap_{i=1}^{n}\overline{A_i}$ ($\overline{A_i}$ មិនទាក់ទងគ្នា) ដែល $P(\overline{A_i})=\dfrac{5}{6}$

ដូច្នេះ $P(\overline{A})=P(\bigcap_{i=1}^{n}\overline{A_i})=\prod_{i=1}^{n}P(\overline{A_i})=(\dfrac{5}{6})^n$

$\Rightarrow P(A)=1-P(\overline{A})=1-(\dfrac{5}{6})^n$

តែ $P(A)\geq 0.9\Leftrightarrow 1-(\dfrac{5}{6})^n\geq 0.9$

$$\Leftrightarrow (\frac{5}{6})^n\leq 0.1\Leftrightarrow n.\log\frac{5}{6}\leq\log 0.1$$

$$\Leftrightarrow n(\log 5-\log 6)\leq -1$$

$$\Rightarrow n\geq\frac{-1}{\log 5-\log 6}=12.65$$

ដូចនេះ ដើម្បីអោយប្រូបាបមានយ៉ាងតិចគ្រាប់ឡុកឡាក់មួយចេញលេខ $6$ ធំជាងឬស្មើនិង $0.9$ គេត្រូវទំលាក់គ្រាប់ឡុកឡាក់យ៉ាងតិចបំផុតចំនួន $n=13$ គ្រាប់។

**៣៥**. គេមានប្រអប់ 3 ដូចគ្នា។ ប្រអប់ទី $I$ មានផលិតផល 10 ដែលក្នុងនេះមានផលិតផលល្អ 8 ។ ប្រអប់ទី $II$ មានផលិតផល 15 ដែលក្នុងនេះមានផលិតផលល្អ 12 ។ ប្រអប់ទី $III$ មានផលិតផល 20 ដែលក្នុងនេះមានផលិតផលល្អ 15 ។ គេយកប្រអប់មួយរួចគេចាប់យកផលិតផលមួយពីក្នុងប្រអប់នេះដោយចៃដន្យ។ គណនាប្រូបាបដើម្បីអោយគេយកបានផលិតផលល្អ។

**ចម្លើយ**

តាង $A$="យកបានផលិតផលល្អ"

$B_1$ = "យកបានប្រអប់ទី $I$"

$B_2$ = "យកបានប្រអប់ទី $II$"

$B_3$ = "យកបានប្រអប់ទី $III$"

$P(A)$ ជាប្រូបាបដែលត្រូវរក

គេបាន : $P(B_1)=P(B_2)=P(B_3)=\frac{1}{3}$

តាមរូបមន្ត ប្រូបាបសរុប

$P(A)=P(B_1).P(A/B_1)+P(B_2).P(A/B_2)+P(B_3).P(A/B_3)$

គេបាន $P(A)=(\frac{1}{3}\times\frac{8}{10})+(\frac{1}{3}\times\frac{12}{5})+(\frac{1}{3}\times\frac{15}{20})=\frac{47}{60}$

$P(A)=0.7833$

**៣៦**. យុវជន 3 នាក់បាញ់កាំភ្លើងម្នាក់មួយគ្រាប់តំរង់ទៅគោលដៅមួយ។ ប្រូបាប៊ីលិតេដែលនាំអោយអ្នកទី 1 ទី 2 និងទី 3 បាញ់ត្រូវគោលដៅស្មើរៀងគ្នានិង $0.7;0.8;0.5$ ។ គណនាប្រៅបាប៊ីលីតេដើម្បីអោយ ៖

a. មានមួយគ្រាប់ចំគោលដៅ។

b. មាន 2 គ្រាប់ចំគោលដៅ។

c. បាញ់ខុសទាំង 3 គ្រាប់។

d. មានមួយគ្រាប់យ៉ាងតិចចំគោលដៅ។

e. គ្រាប់ទី 1 បាញ់ត្រូវដោយដឹងថាមាន 2 គ្រាប់ចំគោលដៅ។

**ចម្លើយ**

តាង $A_i$ = អ្នកទី $i$ បាញ់ចំគោលដៅ $i=\overline{1,3}$

($A_i$ ជាព្រឹត្តការណ៍មិនទាក់ទងគ្នា)

គេបាន $P(A_1)=0.7$ $P(A_2)=0.8$ $P(A_3)=0.5$

$P(\overline{A_1})=0.3$ $P(\overline{A_2})=0.2$ $P(\overline{A_3})=0.5$

a. មានមួយគ្រាប់ចំគោលដៅ

តាង $A$=″មានមួយគ្រាប់បាញ់ចំគោលដៅ″

គេបាន $A=(A_1\cap\overline{A_2}\cap\overline{A_3})\cup(\overline{A_1}\cap A_2\cap\overline{A_3})\cup(\overline{A_1}\cap\overline{A_2}\cap A_3)$

ប្រូបាបដែលនាំអោយមានមួយគ្រាប់ចំគោលដៅគឺ

$$P(A)=P(A_1\cap\overline{A_2}\cap\overline{A_3})+P(\overline{A_1}\cap A_2\cap\overline{A_3})+P(\overline{A_1}\cap\overline{A_2}\cap A_3)$$

$$=P(A_1)P(\overline{A_2})P(\overline{A_3})+P(\overline{A_1})P(A_2)P(\overline{A_3})+P(\overline{A_1})P(\overline{A_2})P(A_3)$$

$$=(0.7\times0.2\times0.5)+(0.3\times0.8\times0.5)+(0.3\times0.2\times0.5)$$

$$=0.22$$

b. មាន $2$ គ្រាប់ចំគោលដៅ

តាង $B$=″មាន $2$ គ្រាប់បាញ់ចំគោលដៅ″

គេបាន $B=(A_1\cap A_2\cap\overline{A_3})\cup(A_1\cap\overline{A_2}\cap A_3)\cup(\overline{A_1}\cap A_2\cap A_3)$

ប្រូបាបដែលនាំអោយមានមួយគ្រាប់ចំគោលដៅគឺ

$$P(B)=P(A_1\cap A_2\cap\overline{A_3})+P(A_1\cap\overline{A_2}\cap A_3)+P(A_1\cap A_2\cap\overline{A_3})$$

$$=P(A_1)P(A_2)P(\overline{A_3})+P(A_1)P(\overline{A_2})P(A_3)+P(\overline{A_1})P(A_2)P(A_3)$$

$$=(0.7\times0.8\times0.5)+(0.7\times0.2\times0.5)+(0.3\times0.8\times0.5)$$

$$=0.47$$

c. បាញ់ខុសទាំង $3$ គ្រាប់

ប្រូបាបដែលនាំអោយបាញ់ខុសទាំងបីគ្រាប់គឺ

$$P(\overline{A_1}\cap\overline{A_2}\cap\overline{A_3})=P(\overline{A_1})P(\overline{A_2})P(\overline{A_3})$$

$$=0.3\times 0.2\times 0.5$$

$$=0.03$$

d. មានមួយគ្រាប់យ៉ាងតិចចំគោលដៅ

ប្រូបាបនេះគឺ $P(A_1\cup A_2\cup A_3)=1-P(\overline{A_1\cup A_2\cup A_3})=1-P(\overline{A_1}\cap\overline{A_2}\cap\overline{A_3})$

$$=1-0.3=0.97$$

e. គ្រាប់ទី 1 បាញ់ត្រូវដោយដឹងថាមាន 2 គ្រាប់ចំគោលដៅ

ប្រូបាបនេះគឺ $$P(A_1/B)=\frac{P(A_1\cap B)}{P(B)}\qquad (1)$$

ប៉ុន្តែ $$A_1\cap B=A_1\cap\left[(A_1\cap A_2\cap\overline{A_3})\cup(A_1\cap\overline{A_2}\cap A_3)\cup(\overline{A_1}\cap A_2\cap A_3)\right]$$

$$=(A_1\cap A_2\cap\overline{A_3})\cup(A_1\cap\overline{A_2}\cap A_3)$$

$$(1)\Rightarrow P\left(A_1/B\right)=\frac{P(A_1\cap A_2\cap\overline{A_3})+P(A_1\cap\overline{A_2}\cap A_3)}{P(B)}$$

$$=\frac{P(A_1)P(A_2)P(\overline{A_3})+P(A_1)P(\overline{A_2})P(A_3)}{P(B)}$$

$$=\frac{0.27+0.07}{0.47}=0.7447$$

**៣៧**. ប្រអប់មួយមានឃ្លីខ្មៅ 4 ឃ្លីស 6 ។រកប្រូបាបដែលនាំអោយ :

a. យកឃ្លី 3 ព្រមគ្នាបានឃ្លីខ្មៅទាំងអស់។

b. យកឃ្លី 3 ព្រមគ្នាបានឃ្លី 2 មានពណ៌ដូចគ្នា។

c. យកឃ្លី 3 (ចាប់យកម្តងមួយរួចដាក់វិញ)បានឃ្លីពណ៌ខ្មៅ។

d. គេចុះលេខ 1 ដល់លេខ 10 លើឃ្លីទាំងនេះ។គេចាប់យកឃ្លី(ចាប់យកម្តងមួយដោយមិនដាក់វិញ)មករៀបតាមលំដាប់។ រកប្រូបាបដើម្បីអោយឃ្លីទាំង 3 រៀបបានចំនួន 132 ។

**ចម្លើយ**

a. យកឃ្លី 3 ព្រមគ្នាបានឃ្លីខ្មៅទាំងអស់

តាង $A=$″យកឃ្លីពណ៌ខ្មៅ3″

$P(A)$ ជាប្រូបាបដែលត្រូវរក

គេបាន $P(A)=\frac{C_4^3}{C_{10}^3}=\frac{4}{120}=0.0333$

b. យកឃ្លី 3 ព្រមគ្នាបានឃ្លី 2 មានពណ៌ដូចគ្នា

ឃ្លី 2 មានពណ៌ដូចគ្នាមានន័យថា"ខ្មៅ2 ស1 ឬ ខ្មៅ 1 ស2"

តាង $B=$យកបានឃ្លី 2 មានពណ៌ដូចគ្នា

គេបាន $P(A)=\frac{C_4^2\times C_6^1+C_4^1\times C_6^2}{C_{10}^3}=\frac{96}{120}=0.8$

c. យកឃ្លី 3 (ចាប់យកម្តងមួយរួចដាក់វិញ)បានឃ្លីពណ៌ខ្មៅ

តាង $C_i=$ "យកបានឃ្លីខ្មៅនៅលើកទី $i$ " $(i=\overline{1,3})$

$C_i$ ជាព្រឹត្តិការណ៍មិនទាក់ទងគ្នា

ប្រូបាបដែលនាំអោយគរយកបាបឃ្លីខ្មៅ 3គឺ

$$P(\bigcap_{i=1}^{3}C_i)=P(C_1)\times P(C_2)\times P(C_3)=\frac{4}{10}\times\frac{4}{10}\times\frac{4}{10}=0.064$$

d. រកប្រូបាបដើម្បីអោយឃ្លីទាំង 3 រៀបបានចំនួន 132

តាង $D=$ "យកបានឃ្លីបីរៀបបានលេខ 132 "

$D_j=$ "យកបានឃ្លីដែលមានលេខ $j$ " $(j=\overline{1,10})$

$D_j$ ជាព្រឹត្តិការណ៍ដែលទាក់ទងគ្នា

ដូច្នេះ ប្រូបាបដែលនាំអោយឃ្លីបានលេខ 132គឺ

$$P(D)=P(D_1)\times P(D_3/D_1)\times P(D_2/D_1D_3)=\frac{1}{10}\times\frac{1}{9}\times\frac{1}{8}$$

$$P(D)=\frac{1}{720}$$

**៣៨**. ប្រូបាបដែលនាំអោយម៉ាស៊ីនខូចបន្ទាប់ពីដំណើរការផលិតបានមួយថ្ងៃស្មើនិង $\alpha$ ($\alpha$ ចំនួនវិជ្ជមានតូចបំផុតដែលការរបស់វាអាចចោលបាន)។ គណនាប្រូបាបដែលនាំអោយម៉ាស៊ីននេះដំណើរការផលិត5ថ្ងៃមិនខូច។

**ចម្លើយ**

តាង $A_i =$ "ម៉ាស៊ីនខូចនៅថ្ងៃទី $i$ ( $A_i$ មិនទាក់ទងគ្នា)

$\overline{A_i}$ "ម៉ាស៊ីនមិនខូចថ្ងៃទី $i$ "

$A =$ "ម៉ាស៊ីនមិនខូចបន្ទាប់ពីដំណើរផលិតបានថ្ងៃ5"

គេបាន $A = \overline{A_1} \cap \overline{A_2} \cap \overline{A_3} \cap \overline{A_4} \cap \overline{A_5}$

តាមសម្មិតកម្ម $P(A_i) = \alpha \Rightarrow P(\overline{A_i}) = 1 - P(A_i) = 1 - \alpha$

ប្រូបាបដែលនាំអោយម៉ាស៊ីនំណើរការផលិតបាន5ថ្ងៃមិនខូចគឺ

$$P(A) = P(\overline{A_1} \cap \overline{A_2} \cap \overline{A_3} \cap \overline{A_4} \cap \overline{A_5}) = \prod_{i=1}^{5} P(A_i)$$

$$= \left[P(A_i)\right]^5 = (1-\alpha)^5 = 1 - 5\alpha + 10\alpha^2 - 10\alpha^3 + 5\alpha^4 - \alpha^5$$

$$= 1 - 5\alpha + \alpha^2(10 - 10\alpha + 5\alpha^2 - \alpha^3)$$

$= 1 - 5\alpha$ ( $\alpha^2$ ព្រោះអាចចោលបាន)

**ដូចនេះ** $P(A) = 1 - 5\alpha$

**៣៩**. រោងចក្រពីរផលិតអំពូលអគ្គីសនី $220V$ ដូចគ្នា។ ទិន្នផលនៃរោងចក្រទី $II$ ស្មើនិង $3$ ដងទិន្នផលនៃរោងចក្រទី $I$ ។ អត្រាខូចរបស់អំពូលដែលផលិតដោយរោងចក្រទី $I$ និងទី $II$ គឺ $0.1\%$ និង $0.2\%$ ។ ឧបមាថាអំពូលដែលផលិតដាក់លក់នៅលើទីផ្សារជាអំពូលដែលផលិតដោយរោងចក្រទាំងពីរនេះ។ គេទិញអំពូលមួយដោយចៃដន្យ។

a. គណនាប្រូបាប៊ីលីតេដែលនាំអោយគេទិញប៉ះអំពូលខូច។

b. បើគេទិញប៉ះអំពូលខូចតាមយោបល់របស់អ្នកតើអំពូលនេះផលិតផលរបស់រោងចក្រណា?

**ចម្លើយ**

a. គណនាប្រូបាប៊ីលីតេដែលនាំអោយគេទិញប៉ះអំពូលខូច

តាង $A_i =$ "ទិញប៉ះអំពូលខូចដែលផលិតដោយរោងចក្រទី $i$ "

$B =$ "ទិញប៉ះអំពូលខូច "

តាមសម្មតិកម្ម $P(A_1) = \dfrac{1}{4}$ ; $P(A_2) = \dfrac{3}{4}$

តាមរូបមន្តប្រូបាបប៊ីលីតេសរុបប្រូបាបដែលនាំអោយទិញប៉ះអំពូលខូចគឺ

$$P(B)=P(A_1)\times P(B/A_1)+P(A_2)\times P(B/A_2)$$

$$\frac{1}{4}\times 0.1\%+\frac{3}{4}\times 0.2\%=\frac{0.007}{4}=0.00175$$

b. បើគេទិញប៉ះអំពូលខូចតើវាជារបស់រោងចក្រណា?

ប្រូបាបដែលនាំអោយអំពូលនេះជារបស់រោងចក្រទី $I$

$$P(A_1/B)=\frac{P(A_1)\times P(B/A_1)}{P(B)}=\frac{\frac{1}{4}\times 0.1\%}{0.00175}=0.14285$$

ប្រូបាបដែលនាំអោយអំពូលនេះជារបស់រោងចក្រទី $II$

$$P(A_2/B)=\frac{P(A_2)\times P(B/A_2)}{P(B)}=\frac{\frac{3}{4}\times 0.2\%}{0.00175}=0.85714$$

តាមលទ្ធផលខាងលើបញ្ជាក់ថាជាទូទៅអំពូលខូចនេះជាផលិតផលរបស់រោងចក្រទី $II$

**៤០**. ក្នុងចំណោមរថយន្តទេសចរណ៍ និង រថយន្តដឹកទំនិញដែលបើកបរឆ្លងកាត់ស្ថានីយ៍ $X$ មាន 60% ជារថយន្តដឹកទំនិញ។ ប្រូបាបដែលនាំអោយរថយន្តទេសចរណ៍ចូលចាក់សាំងក្នុងស្ថានីយ៍ $X$ ស្មើនិង 0.2 ចំណែកឯរថយន្តដឹកទំនិញស្មើរនិង 0.1 ។ រថយន្តមួយចូលចាក់សាំងក្នុងស្ថានីយ៍នេះ។គណនាប្រូបាបដែលនាំអោយរយន្តដឹកនេះជារថយន្តដឹកទំនិញ។

**ចម្លើយ**

តាង $A=$ "រថយន្តដែលបើកតាត់ស្ថានីយ៍ជារថយន្តទេសចរណ៍"

$\bar{A}$"រថយន្តដែលបើកកាត់ស្ថានីយ៍ជារថយន្តដឹកទំនិញ"

$B=$"ចូលចាក់សាំង"

តាមសម្មតិកម្ម $P(\overline{A})=60\%=0.6$ ; $P(A)=0.4$ ; $P(B/A)=0.2$ ; $P(B/\overline{A})=0.1$

ប្រូបាបដែលនាំអោយរថយន្តដែលចូលចាក់សាំងជារថយន្តដឹកទំនិញគឺ

$$P(\overline{A}/B)=\frac{P(\overline{A}\cap B)}{P(B)}=\frac{P(A)\times P(B/\overline{A})}{P(A)\times P(B/A)+P(A)\times P(B/\overline{A})}\quad (Bayes)$$

$$=\frac{0.6\times 0.1}{0.4\times 0.2+0.6\times 0.1}=0.4286=\frac{0.6\times 0.1}{0.4\times 0.2+0.6\times 0.1}=0.4286$$

**៤១**. ប្រូបាបដែលនាំអោយយុទ្ធជនម្នាក់បាញ់ត្រូវបច្ចាមិត្តស្មើរនិង $p$ ថេរ។ យុទ្ធជននេះបាញ់តំរង់ទៅគោលដៅ។ ឧបមាថាការបាញ់ក្នុងមួយគ្រាប់ៗមិនរងឥទ្ធិពលទៅវិញទៅមកទេ។

a. បន្ទាប់ពីបាញ់អស់ $n$ គ្រាប់ ចូររកប្រូបាបដែលនាំអោយគាត់បាញ់ត្រូវគោលដៅយ៉ាងតិចមួយគ្រាប់។

b. តើត្រូវជ្រើសរើស $n$ បែបណាដើម្បីអោយប្រូបាប(ក្នុងសំណួរទី $a$ )ធំជាងតម្លៃ $r(0<r<1)$ ?

c. គេអោយ $p=0.2$ ។ តើគាត់ត្រូវបាញ់យ៉ាងហោចណាស់ប៉ុន្មានគ្រាប់ដើម្បីអោយប្រូបាបបាញ់ត្រូវគោលដៅយ៉ាងតិចមួយគ្រាប់ធំជាងតម្លៃ $r=0.9$ ?

**ចម្លើយ**

a. ប្រូបាបបាញ់ត្រូវមួយគ្រាប់យ៉ាងតិច

តាង $A=$ "បាញ់ត្រូវបច្ចាមិត្រយ៉ាងតិចមួយគ្រាប់"

$\overline{A}=$ "បាញ់ខុសទាំងអស់"

$A_i=$ "គ្រាប់ទី $i$ បាញ់ត្រូវ" $\Rightarrow \overline{A_i}=$ "គ្រាប់ទី $i$ បាញ់ខុស"

គេបាន $\overline{A}=\bigcap_{i=1}^{n}\overline{A_i}$

តាមសម្មតិកម្ម $P(A_i)=p \Rightarrow P(\overline{A_i})=1-P(A_i)=1-p$

ប្រូបាបបាញ់ខុសទាំងអស់គឺ $P(\overline{A})=P(\bigcap_{i=1}^{n}\overline{A_i})=\prod_{i=1}^{n}P(\overline{A_i})=(1-p)^n$

ប្រូបាបបាញ់ត្រូវមួយគ្រាប់យ៉ាងតិចគឺ $P(A)=1-P(\overline{A})=1-(1-p)^n$

b. កំណត់ $n$ ដើម្បីអោយ $P(A)>r(0<r<1)$

$$P(A)>r \Leftrightarrow 1-(1-p)^n>r$$

$$\Leftrightarrow (1-p)^n<1-r \Leftrightarrow n.\lg(1-p)<\lg(1-r)$$

$$\Rightarrow n>\frac{\lg(1-r)}{\lg(1-p)} \quad (\text{ព្រោះ } 0<1-r<1 \Rightarrow \lg(1-r)<0)$$

ដូចនេះ គេត្រូវយក $n>\dfrac{\lg(1-r)}{\lg(1-p)}$

c. អនុវត្តន៍ $p=0.2$

ក្នុងករណីនេះ $n>\dfrac{\lg(1-r)}{\lg(1-0.2)}=\dfrac{\lg(1-r)}{\lg 0.8}$

ចំពោះ $r=0.9\Rightarrow n>\frac{\lg(1-0.9)}{\lg(0.8)}=\frac{\lg(0.1)}{\lg(0.8)}=\frac{-1}{-0.0969}=10.32$

ដើម្បីអោយប្រូបាបបាញ់ត្រូវមួយគ្រាប់យ៉ាងតិចធំជាង $r=0.9$ គេត្រូវបាញ់យ៉ាងតិចបំផុតចំនួន $n=11$ គ្រាប់។

**៤២**. តាមការអង្កេតបានអោយដឹងថាមានតែសិស្ស 40% ប៉ុណ្ណោះដែលបានរំលឹកមេរៀនមុនទៅសាលា។ ថ្ងៃនោះគេហៅសិស្ស 5 នាក់សួរដោយចៃដន្យ។គណនាប្រូបាបដើម្បីអោយមានសិស្ស $k$ នាក់រំលឹកមេរៀន។ អនុវត្តន៍: $k=0;k=1;k=2;k=5$ ។

**ចម្លើយ**

ប្រូបាបដើម្បីអោយមានសិស្ស $k$ នាក់ បានរំលឹកមេរៀន

តាមសម្មតិកម្មមានសិស្ស 40% បានរំលឹកមេរៀនដូចនេះ

$$p=40\%=0.4\Rightarrow q=1-p=1-0.4=0.6$$

ប្រូបាបដើម្បីអោយមានសិស្ស $k(0\le k\le 5)$ នាក់បានរំលឹកមេរៀនគឺ

$$P(k)=C_5^k p^k q^{5-k}=\frac{5!}{k!(5!-k!)}\times(0.4)^k\times(0.6)^{5-k}$$

អនុវត្តន៍

$$k=0: P(0)=\frac{5!}{0!5!}\times(0.4)^0\times(0.6)^5=0.07776$$

$$k=1: P(1)=\frac{5!}{1!4!}\times(0.4)^1\times(0.6)^4=0.2592$$

$$k=2: P(2)=\frac{5!}{2!3!}\times(0.4)^2\times(0.6)^3=0.3456$$

$$k=5: P(5)=\frac{5!}{0!5!}\times(0.4)^5\times(0.6)^0=0.01024$$

**៤៣**. តាមរបាយការណ៍បានអោយដឹងថាក្នុងចំណោមទូរទស្សនិកជនទាំងអស់មាន 20% ចូលចិត្តទស្សនាកម្មវិធីពត៌មាន។ គេជ្រើសរើសទស្សនិកជន 100 នាក់ដោយចៃដន្យ។

a. គណនាប្រូបាបប៊ីលីតេដើម្បីអោយមាន 24 នាក់ចូលចិត្តកម្មវិធីពត៌មាន។

b. គណនាប្រូបាបដើម្បីអោយមានមិនលើសពី 12 នាក់ចូលចិត្តកម្មវិធីពត៌មាន។

**ចម្លើយ**

a. គណនាប្រូបាបប៊ីលីតេដើម្បីអោយមាន 24 នាក់ចូលចិត្តកម្មវិធីពត៌មាន

តាមសម្មតិកម្ម $p=20\%=0.2 \Rightarrow q=1-p=0.8$ ; $n=100$

$np=100\times 0.2=20 \quad k=24$

$\Rightarrow \sqrt{npq}=\sqrt{100\times 0.2\times 0.8}=4$

គេបាន $X_k=\frac{k-np}{\sqrt{npq}}=\frac{24-20}{4}=1$

តាមតារាង $\varphi(X_k)=\varphi(1)=0.2420$

ប្រូបាបប៊ីលីតេដែលនាំអោយអោយមាន 24 នាក់ចូលចិត្តកម្មវិធីពត៌មានគឺ

$P(24)\approx\frac{\varphi(X_k)}{\sqrt{npq}}=\frac{0.2420}{4}=0.0605$

b. គណនាប្រូបាបដើម្បីអោយមានមិនលើសពី 12 នាក់ចូលចិត្តកម្មវិធីពត៌មាន

គេបាន $k_1=0 \;\; k_2=12$

ដូចនេះ $\alpha=\frac{k_1-np}{\sqrt{npq}}=\frac{0-20}{4}=-5\Rightarrow\varphi(-5)=-\varphi(5)=-0.49999997$

$\beta=\frac{k_2-np}{\sqrt{npq}}=\frac{12-20}{4}=-2\Rightarrow\varphi(-2)=-\varphi(2)=-0.47725$

ប្រូបាបដើម្បីអោយមានមិនលើសពី 12 នាក់ចូលចិត្តកម្មវិធីពត៌មានគឺ

$P(0\le k\le 12)\approx\varphi(-2)-\varphi(-5)=0.49999997-0.47725=0.02275$

**៤៤**. តាមពត៌មានពីក្រុមហ៊ុន *MOBITEL* បានអោយដឹងថាក្នុងមួយម៉ោងមានអតិថិជន 300 នាក់បានទូរស័ព្ទទៅសួរអំពីរទឹកប្រាក់ក្នុគណនីរបស់ខ្លួន។ គណនាប្រូបាបដើម្បីអោយក្នុង 1 នាទីមានអតិថិជន 2 នាក់ទូរស័ព្ទទៅសួរអំពីរទឹកប្រាក់ក្នុងគណនីរបស់ខ្លួន។

**ចម្លើយ**

ប្រូបាបដែលនាំអោយមានអតិថិជន 2 នាក់ទូរស័ព្ទទៅសួរអំពីរទឹកប្រាក់ក្នុងគណនីរបស់ខ្លួន

តាមសម្មតិកម្មក្នុងមួយនាទីមានអ្នកសួរ $\frac{300}{60}=5$ នាក់

គេបាន $\lambda=5 \;\; k=2$

ប្រូបាបដែលនាំមានអតិថិជន 2 នាក់ទូរស័ព្ទទៅសួរអំពីរទឹកប្រាក់ក្នុងគណនីរបស់ខ្លួនគឺ

$$P(2) \approx \frac{e^{-5}5^2}{2!} = 0.084$$

**៤៥**. ការផ្ញើឥវ៉ាន់តាមយន្តហោះមួយកំរបាត់ណាស់ ។ តាមការធ្វើគំរូសាកល្បងទៅលើចំនួន 1000 ជើងហោះហើរ គេរកឃើញថាមានឥវ៉ាន់ចំនួន 300 បានបាត់ ។

ចូររកប្រូបាបដែលឥវ៉ាន់មិនបាត់

**ចម្លើយ**

គេមាន ទំហំគំរូ $n = 1000$

ប្រូបាបដែលមិនបាត់គឺ $p = 0.7$

មធ្យម និងវ៉ារ្យង់គឺ $E(X) = V(X) = 0.3 = \mu$

តាមរូបមន្ត $P(X = k) = \frac{\mu^k e^{-\mu}}{k!}$ នាំឱ្យ

$$P(X = 0) = \frac{(0.3)^0 e^{-0.3}}{0!} = 0.7408$$

ដូចនេះ $P(X = 0) = 74.08\%$ ដែលឥវ៉ាន់មិនបាត់ ។

សម្គាល់ ៖ កាលណា $n$ មានតម្លៃកាន់តែធំ ហើយ $p$ មានតម្លៃតូចដែល $np = \lambda$ ថេរនោះ

$$P_n(k) \simeq \frac{e^{-\lambda}\lambda^k}{k!}$$

**៤៦**. ផលិតផលខូចដែលផលិតដោយម៉ាស៊ីនមួយមានប្រូបាប 0.005 ។ គេប្រើម៉ាស៊ីននេះផលិត 1000 ផលិតផល ។ គណនាប្រូបាបដើម្បីឱ្យមាន :

ក. ផលិតផលខូចមួយ

ខ. ផលិតផលខូចមិនលើសពី២

គ. បើគេផលិត 2000 ផលិតផល តើមានផលិតផលខូចជាមធ្យមប៉ុន្មាន ?

**ចម្លើយ**

តាមសម្មតិកម្ម :

- ចំនួនគំរូពិត $n = 1000$
- ប្រូបាបឈ្នះគឺ $p = 0.005$
- មធ្យម $\mu = np = 1000 \times 0.005 = 5$

យើងបាន $P(X = k) = \dfrac{e^{-\mu}\mu^k}{k!} \quad , \; k = 0,1,2,...$

ក. រកប្រូបាបផលិតផលខូចមួយ

យើងបាន $P(X = 1) = \dfrac{e^{-5}5^1}{1!} = 0.0337$

ដូចនេះ ប្រូបាបផលិតផលខូចមួយគឺ 3.37%

ខ. ប្រូបាបផលិតផលខូចមិនលើសពី២

យើងមាន $P(X \le 2) = P(X = 0) + P(X = 1) + P(X = 2)$

$$= \frac{e^{-5}5^0}{0!} + \frac{e^{-5}5^1}{1!} + \frac{e^{-5}5^2}{2!}$$

$$= 0.1247$$

ដូចនេះ ប្រូបាបផលិតផលខូចមិនលើសពី២ គឺ 12.47%

គ. រកចំនួនផលិតផលខូចជាមធ្យម

យើងមាន មធ្យម $\mu = 0.005$ និងចំនួនផលិតផលសរុប $N = 2000$

នាំឱ្យ $\mu' = NP = 2000 \times 0.005 = 10$

ដូចនេះ ផលិតផលធ្វើខូចជាមធ្យមគឺ 10 គ្រឿង ។

**៤៧**. មេធាវីមួយក្រុមមានជំនឿជាក់ថា រាល់ពេលគាត់ការពារកូនក្តីរបស់គាត់មួយលើកៗ ប្រូបាប ដែលនាំឱ្យគាត់ទទួលបានជោគជ័យ ( ដោះស្រាយបញ្ហាឱ្យកូនក្តី ) ស្មើនឹង 0.6 ។ ឧបមាថាគាត់ការពារកូនក្តីរបស់គាត់ ៤លើក ។ តាង $X$ ជាចំនួនដងដែលគាត់ទទួលបានជោគជ័យ ។ រកបំណែងចែកប្រូបាបនៃ $X$ ។

**ចម្លើយ**

ដោយ $P(X=x)$ : ប្រូបាបនៃចំនួនដងដែលគាត់ទទួលបានជោគជ័យជាប្រូបាបទ្វេធា ដែលមាន $n=4$ និង $P=0.6$ ។

$$\Rightarrow P(X=x)=\binom{4}{x}(0.6)^x(0.4)^{4-x} \text{ ចំពោះ } x=0,1,2,3,4$$

- ករណី $x=0$ : $P(X=0)=\binom{4}{0}(0.6)^0(0.4)^4=0.026$
- ករណី $x=1$ : $P(X=1)=\binom{4}{1}(0.6)^1(0.4)^3=0.115$
- ករណី $x=2$ : $P(X=2)=\binom{4}{2}(0.6)^2(0.4)^2=0.346$
- ករណី $x=3$ : $P(X=3)=\binom{4}{3}(0.6)^3(0.4)^1=0.346$
- ករណី $x=4$ : $P(X=4)=\binom{4}{4}(0.6)^4(0.4)^0=0.130$

**៤៨**. ក្នុងថង់មួយមានប៊ូលក្រហម 4 និងពណ៌ខៀវ 6 ។ គេចាប់យកប៊ូល 2 ពីក្នុងថង់ ម្តងមួយៗ ដោយដាក់ចូលវិញ ។ តាង $X$ ជាចំនួនប៊ូលពណ៌ក្រហមគេចាប់បាន ។ រកសង្ឃឹមគណិត, វ៉ារ្យង់ និង គំលាតស្តង់ដានៃ $X$ ។

**ចម្លើយ**

ដោយ $X$ : ជាអថេរចៃដន្យទ្វេធាដែលមាន $n=2$ និង $p=\frac{4}{10}=0.4$

- សង្ឃឹមគណិតនៃ $X$

  $E(X)=\mu=np=2\times 0.4=0.8$
- វ៉ារ្យង់ $\sigma^2(X)=np(1-p)=2.(0.4)(0.6)=0.48$
- គំលាតស្តង់ដា $\sigma(X)=\sqrt{\sigma^2(X)}=\sqrt{0.48}=0.69$

**៤៩**. ក្នុងក្រុមហ៊ុនមួយ គេត្រូវការជ្រើសរើសបុគ្គលិកបម្រើការងារ នៅតាមអង្គភាពផ្សេងៗ ។ បុគ្គលិកដែលដាក់ $C.V$ មកជាមធ្យមមានចំនួន $4$ ក្នុងមួយសប្តាហ៍ ។ រកបំណែងចែកប្រូបាបនៃអថេរចៃដន្យ $X$ តាងអោយចំនួនបុគ្គលិកដែលបានដាក់ $C.V$ មកក្នុងមួយសប្តាហ៍នេះ ។

តើប្រូបាបដែលមានបុគ្គលិកចំនួន $6$ នាក់ដាក់ $C.V$ មកនៅក្នុងសប្តាហ៍នេះស្មើនឹងប៉ុន្មាន ?

**ចម្លើយ**

☆ បំណែងចែកប្រូបាប :

ដោយ $X$ តាងអោយចំនួនបុគ្គលិកដែលបានដាក់ $C.V$ មកជាអថេរចៃដន្យព័រសុង ដែលមាន $\mu=4$

ដូចនេះ $P(X,4)=\dfrac{e^{-4}4^X}{X!}$ ចំពោះ : $X=0,1,2,3,\dots$

☆ ចំនួនបុគ្គលិកដាក់ $C.V$ មកចំនួន $6$ នាក់

នោះ $X=6$ គេបាន :

$$P(6,4)=\frac{e^{-4}4^6}{6!}=\sum_{X=0}^{6}P(X,4)-\sum_{X=0}^{5}P(X,4)$$
$$=0.8893-0.7851$$
$$=0.1042$$

ដូចនេះ $P(6,4)=0.1042$

**៥០**. ក្នុងស្បោងមួយមានឃ្លី 30 ដែលចុះលេខពី១ ដល់លេខ៣០ ។ គេលូកយកឃ្លីហើយ កត់លេខវារួចដាក់ចូលក្នុងស្បោងវិញ ។ $A$ ជាព្រឹត្តិការណ៍លូកបាន ឃ្លីចុះលេខជាពហុគុណនៃ3។ គេលូកយកឃ្លី 4 បន្តបន្ទាប់គ្នា ។

ក. រកប្រូបាបដែលលូកបានឃ្លីជាពហុគុណនៃ3 ចំនួន 4 គ្រាប់ , 3គ្រាប់ , 2 គ្រាប់ , 1 គ្រាប់ និងមិនបានសោះ ។

ខ. សង់តារាងបំណែងចែកប្រូបាប

គ. គណនាសង្ឃឹមគណិត , វ៉ារ្យង់ និង គំលាតស្តង់ដានៃអថេរចៃដន្យ តាងឱ្យព្រឹត្តិការណ៍ $A$ ខាងលើ ។

**ចម្លើយ**

ក. រកប្រូបាបដែលលូកបានឃ្លីជាពហុគុណនៃ3 ចំនួន 4 គ្រាប់ , 3គ្រាប់ , 2 គ្រាប់ ,1 គ្រាប់ និងមិនបានសោះ

តាង $X$ ជាអថេរចៃដន្យនៃព្រឹត្តិការណ៍លូកចាប់បានឃ្លីចុះលេខជាពហុគុណនៃ3

យើងបាន $X = 0,1,2,3,4$ ដោយលូកឃ្លី 4 ដងនោះ $n = 4$

ដោយ ឃ្លី30 មានឃ្លី10 ជាពហុគុណនៃ3 គឺ $3,6,9,12,15,18,21,24,27,30$ ហើយការលូកយកឃ្លីមួយដាក់ចូលវិញ បានប្រូបាបដូចគ្នាជាមួយនឹង ការលូកម្តងៗ គឺ តាមច្បាប់ទ្វេធាគេបាន

$$P = \frac{10}{30} = \frac{1}{3}$$

តាមរូបមន្ត $P(X = x) = C_n^x p^x (1-p)^{n-x}$

- $P(X=4) = C_4^4 \left(\frac{1}{3}\right)^4 \left(1-\frac{1}{3}\right)^0 = \frac{1}{81}$
- $P(X=3) = C_4^3 \left(\frac{1}{3}\right)^3 \left(1-\frac{1}{3}\right)^1 = \frac{8}{81}$
- $P(X=2) = C_4^2 \left(\frac{1}{3}\right)^2 \left(1-\frac{1}{3}\right)^2 = \frac{24}{81}$
- $P(X=1) = C_4^1 \left(\frac{1}{3}\right)^1 \left(1-\frac{1}{3}\right)^3 = \frac{32}{81}$
- $P(X=0) = C_4^0 \left(\frac{1}{3}\right)^0 \left(1-\frac{1}{3}\right)^4 = \frac{16}{81}$

ខ. សង់តារាងបំណែងចែកប្រូបាប

| $X$ | 0 | 1 | 2 | 3 | 4 |
|---|---|---|---|---|---|
| $P(X=x)$ | $\frac{16}{81}$ | $\frac{32}{81}$ | $\frac{24}{81}$ | $\frac{8}{81}$ | $\frac{1}{81}$ |

គ. គណនា

☆ សង្ឃឹមគណិត

តាមរូបមន្ត $E(X)=np$

ដោយ $n=4$ , $p=\frac{1}{3}$ $E(X)=4\times\frac{1}{3}=\frac{4}{3}$

ដូចនេះ $E(X)=\frac{4}{3}$

☆ គណនាវ៉ារ្យង់

តាមរូបមន្ត $V(X)=npq$ ដែល $q=1-p=1-\frac{1}{3}=\frac{2}{3}$ , $n=4$

$$V(X)=4\times\frac{1}{3}\times\frac{2}{3}=\frac{8}{9}$$

ដូចនេះ $V(X)=\frac{8}{9}$

☆ គំលាតស្តង់ដា

$$\sigma=\sqrt{V(X)}=\sqrt{\frac{8}{9}}=\frac{2\sqrt{2}}{3}$$

ដូចនេះ $\sigma=\frac{2\sqrt{2}}{3}$

**៥១**. ប្រូបាបនៃរោងចក្រមួយផលិតអំពូលខូចគុណភាពស្មើនឹង 0.002 ។ គណនាប្រូបាប ដែលនាំឱ្យ 1000 អំពូលមាន ៖

ក. 4 អំពូលយ៉ាងច្រើនខូចគុណភាព

ខ. 4 អំពូលយ៉ាងតិចខូចគុណភាព

**ចម្លើយ**

ក. គណនាប្រូបាបដែលមាន 4 អំពូលយ៉ាងច្រើនខូចគុណភាព

តាង $X$ ជាអថេរចៃដន្យនៃរោងចក្រមួយផលិតអំពូលខូចគុណភាព

ប្រូបាបនៃរោងចក្រផលិតអំពូលខូចគុណភាព គឺ $p=0.002$

ក្នុងចំណោម $n=1000$ អំពូល , $x\le 4$ ឬ $0\le x\le 4$

$\Rightarrow P(0\le X\le 4)=P(X=0)+P(X=1)+P(X=2)+P(X=3)+P(X=4)$

តាមច្បាប់ព័រសុង គេបាន $P(X=x)=\dfrac{e^{-\mu}\mu^{x}}{x!}$

ដោយ $\mu=np=1000\times 0.002=2$

នោះ $P(X=0)=\dfrac{e^{-2}2^{0}}{0!}=e^{-2}$

☆ $P(X=1)=\dfrac{e^{-2}2^{1}}{1!}=2e^{-2}$

☆ $P(X=2)=\dfrac{e^{-2}2^{2}}{2!}=2e^{-2}$

☆ $P(X=3)=\dfrac{e^{-2}2^{3}}{3!}=\dfrac{4}{3}e^{-2}$

☆ $P(X=4)=\dfrac{e^{-2}2^{4}}{4!}=\dfrac{2}{3}e^{-2}$

គេបាន $P(0\le X\le 4)=e^{-2}+2e^{-2}+2e^{-2}+\dfrac{4}{3}e^{-2}+\dfrac{2}{3}e^{-2}=7e^{-2}$

ដូចនេះ ប្រូបាបដែលមាន 4 អំពូលយ៉ាងច្រើនខូចគុណភាព គឺ $P(0\le X\le 4)=7e^{-2}$

ខ. គណនាប្រូបាបដែលមាន 4 អំពូលយ៉ាងតិចខូចគុណភាព គឺ $X\ge 4$

គេបាន $P(X\ge 4)=1-P(0\le X\le 3)$

$$=1-\left[P(X=0)+P(X=1)+P(X=2)+P(X=3)\right]$$

$$=1-\left(e^{-2}+2e^{-2}+2e^{-2}+\frac{4}{3}e^{-2}\right)$$

$$=\frac{3-19e^{-2}}{3}$$

ដូចនេះ ប្រូបាបដែលមាន 4 អំពូលយ៉ាងតិចខូចគុណភាព គឺ $P(X\ge 4)=\dfrac{3-19e^{-2}}{3}$

# ឯកសារយោង


- ☆ សៀវភៅប្រូបាប រៀបរៀងដោយគរុនិស្សិតជំនាន់ទី ១៨,១៩,២០ នៃវិទ្យាស្ថានជាតិអប់រំ
- ☆ ស្ថិតិ ( វិទ្យាសាស្ត្រពិត ) ឆ្នាំ ២០១១ - ២០១២ និពន្ធដោយ សាស្ត្រាចារ្យ លី ស្រួច ( RUPP )
- ☆ សៀវភៅលំហាត់គណិតវិទ្យាសំរាប់គ្រូ និងសិស្ស មធ្យមសិក្សាទុតិយភូមិ របស់វិទ្យាស្ថានជាតិអប់រំ ( ភាគទី១-១៥ )
- ☆ សៀវភៅគណិតវិទ្យារបស់ក្រសួងអប់រំ យុវជន និងកីឡា ថ្នាក់ទី១០ ,១១ និង១២ បោះពុម្ពឆ្នាំ ២១០៤
- ☆ *Introduction to Probability , Leif Mejlbro , 2009*
- ☆ *Royal University of Agriculture Statistics by Leng Bunhor*
- ☆ *Multifactorial from Wolfram Mathworld ( Mathworld.wolfram.com ,Double Factorial )*